# ក្រមរដ្ឋប្បវេណី

## ភាគ ១

បោះពុម្ពនៅក្នុងខែ មីនា ឆ្នាំ ២០១២

# អារម្ភកថា

សៀវភៅនេះ ត្រូវបានចងក្រងឡើង តាមផ្នែកនៃ "**ក្រមរដ្ឋប្បវេណី**" ហើយ នេះ គឺជាសៀវភៅភាគទី ៦ ដែលគ្របដណ្តប់លើ ***មូលដ្ឋាននៃញាតិ និង សន្តតិកម្ម***។

សៀវភៅនេះ ត្រូវបានបង្កើតឡើងដោយសមាជិកក្រុមការងារដែលរួមមានអនាគតគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម ដោយមានការឧបត្ថម្ភគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃវិទ្យាស្ថានស្រាវជ្រាវ និង បណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន (ICD) ។

សមាជិកនៃក្រុមការងារមានដូចខាងក្រោម:

| | | |
|---|---|---|
| លោក **អ៊ិន វ៉ាន់វិបុល** | លោកស្រី **ចាំង ស៊ីណាត** | លោកស្រី **សែម សក្តិភូឡា** |
| លោក **សេង នាង** | លោក **ម្លង់ សំណាង** | លោក **តាំង ស៊ុនឡាយ** |
| លោក **យូ ប៊ុនណា** | លោក **ខូន រតនា** | លោក **គង់ តារាឆាត** |
| លោក **ម៉ុង មុនីសោភា** | លោក **ឃួត ហ៊ាង** | លោក **ជា សុខហៀង** |
| លោក **ហេង សុខណា** | លោកស្រី **យ៉េត ម៉ូលីន** | លោក **ខូន វុទ្ធី** |
| កញ្ញា **ថ្លាង ផារ៉ែណែត** | លោកស្រី **ស្រ៊ុន ឈន់វលក្ខណ៍** | កញ្ញា **សឺ លីនណា** |
| លោក **កេត សុជាតិ** | លោក **ចំន្ទ រស្មី** | លោកស្រី **ខៀវ សុខា** |
| លោក **រស់ ពិសិដ្ឋ** | លោក **ស៊ិន សុវណ្ណរ័ត្ន** | លោក **ហេង ចន្ទស៊ីបូរិន** |
| លោក **ឆែ វិរៈ** | លោក **អ៊ី ថាវរៈ** | លោក **កេង សុម៉ារិទ្ធ** |
| លោក **ឈុន ចំន្ទសីហា** | លោក **យាប់ មេត្តា** | លោក **ឆែ វិវឌ្ឍនៈ** |
| លោកស្រី **វ៉ា សត្ថា** | លោក **សំម ឫទ្ធីវាសនា** | |

សមាជិកក្រុមការងារទាំងអស់ សង្ឃឹមថា កំរងភាគនីមួយ ៗ នៃ "ក្រមរដ្ឋប្បវេណី" នេះ អាចនឹងជួយដល់អ្នកអានអោយយល់ដឹង និង សិក្សាអំពីមូលដ្ឋាននៃក្រមរដ្ឋប្បវេណីនាពេលបច្ចុប្បន្ន។

**កំណត់សំគាល់ :** ខ្លឹមសារនៃសៀវភៅនេះ ត្រូវបានចងក្រងឡើង ដោយសមាជិកក្រុមការងារ និង មិនបានឆ្លុះបញ្ចាំងពីទស្សនៈផ្លូវការរបស់អាជ្ញាធរពាក់ព័ន្ធណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ។

សៀវភៅនេះ បោះពុម្ពលើកទី ១ នៅក្នុងខែ មីនា ឆ្នាំ ២០១២។

# មាតិកា

ទំព័រ


**ជំពូកទី ៨ ញាតិ** ..................................................... ១

**ផ្នែកទី ១ និយមន័យនៃញាតិ** ..................................................... ១

១. ញាតិមាន ៣ ប្រភេទ ..................................................... ១

២. ទំហំនៃញាតិ..................................................... ១

២.១ វិធីគណនាថ្នាក់ញាតិ ..................................................... ១

២.២ ទំហំញាតិ ..................................................... ២

២.៣ ពាក្យពេចន៍..................................................... ២

៣. ការកើតមានឡើង និង ការរលត់នូវទំនាក់ទំនងញាតិភាព..................................................... ២

៣.១ ការកើតមានឡើង និងការរលត់នូវទំនាក់ទំនងញាតិដោយការសុំកូន ..................................................... ២

៣.២ ការរលត់ទំនាក់ទំនងញាតិពន្ធ..................................................... ៣

**ផ្នែកទី ២ កំថាប់ពាក្យ**..................................................... **៤**

១. អត្ថន័យ និង លក្ខខណ្ឌនៃការបង្កើត ..................................................... ៤

២. អានុភាព ..................................................... ៤

៣. អំឡុងពេលនៃការទាមទារ..................................................... ៥

**ផ្នែកទី ៣ ឪពុកម្តាយ និង កូន**..................................................... **៦**

១. ឪពុកម្តាយ និង កូន..................................................... ៦

២. ទំនាក់ទំនងឪពុកម្តាយ និង កូនបង្កើត ..................................................... ៦

២.១ បទប្បញ្ញត្តិទូទៅ ..................................................... ៦

២.២ ការសម្រេចអំពីបុត្តភាព..................................................... ៧

៣. សុំកូន..................................................... ១១

៣.១ អត្ថន័យនៃរបបសុំកូន ..................................................... ១១

៣.២ សុំកូនធម្មតា..................................................... ១២

៣.៣ សុំកូនពេញលេញ..................................................... ១៦

**ផ្នែកទី ៤ ការលែងលះ**..................................................... **១៩**

១. សេចក្តីផ្តើម ..................................................... ១៩

២. ការលែងលះ មានពីរប្រភេទ ..................................................... ១៩

២.១ ការលែងលះ ( ករណីមានការព្រមព្រៀង) ........................................................ ១៩
២.២ ការលែងលះ ( ករណីគ្មានការព្រមព្រៀង) ........................................................ ១៩
៣. ការទទួលខុសត្រូវចំណាយក្នុងពេលអាពាហ៍ពិពាហ៍........................................................២៥
៣.១ អ្វីទៅជាការទទួលខុត្រូវចំណាយក្នុងពេលអាពាហ៍ពិពាហ៍ ?........................................២៥
៣.២ ទំនាក់ទំនងរវាងការទទួលខុសត្រូវសោហ៊ុយចំណាយក្នុងពេលអាពាហ៍ពិពាហ៍នឹងរឿងក្តីសុំលែងលះ........................................................................................................២៥
៣.៣ វិធីគណនាទឹកប្រាក់នៃការទទួលខុសត្រូវចំណាយក្នុងពេលអាពាហ៍ពិពាហ៍......................២៦
៤. ទំនាក់ទំនងដោយគ្មានខាន់ស្លា ........................................................................២៦
៤.១ អ្វីទៅគឺជា ទំនាក់ទំនងដោយគ្មានខាន់ស្លា ? ...............................................២៦
៤.២ ទំហំនៃការអនុវត្តបញ្ញត្តិស្តីពីអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់.........................................២៦
**ជំពូកទី ៩ សន្តតិកម្ម**.........................................................................................**២៩**
**ផ្នែកទី ១ ការបែងចែកមតិក**...............................................................................**២៩**
១. សេចក្តីផ្តើម ............................................................................................២៩
២. អ្នកណាខ្លះ គឺជាសន្តតិជននៃមតកជន?........................................................................២៩
៣. តើសន្តតិជនម្នាក់ៗ បានទទួលចំណែកមតិកប៉ុន្មាន ? .................................................... ៣០
៤. ភាពគ្រប់លក្ខណៈសម្បត្តិជាសន្តតិជន ................................................................... ៣១
៥. ទំហំមតិក.................................................................................................... ៣១
៦. ការវាយតំលៃមតិក........................................................................................ ៣២
៧. ការកែតម្រូវនូវចំណែកមតិក ចំពោះសន្តិជនដែលទទួលផលប្រយោជន៍ពិសេស ...................... ៣២
៧.១ គោលគំនិត ............................................................................................ ៣២
៧.២ កត្តាដែលត្រូវពិចារណា................................................................................ ៣២
៨. ភាគនៃវិភាគទាន.........................................................................................៣៣
៨.១ ប្រភេទនៃវិភាគទាន...................................................................................... ៣៤
៨.២ កំណត់ចំណាំមួយចំនួន ................................................................................ ៣៤
៩. សេចក្តីសម្រេចអំពីវិធីបែងចែកជាក់ស្តែង ................................................................ ៣៤
៩.១ វិធីបែងចែកមតិក ...................................................................................... ៣៥
៩.២ កត្តាដែលត្រូវពិចារណា ................................................................................ ៣៥
៩.៣ ស្តីពីកាតព្វកិច្ច .......................................................................................... ៣៥
៩.៤ ទម្រង់នៃការបែងចែកមតិក............................................................................ ៣៥

**ផ្នែកទី ២ មតកសាសន៍** ........................................ ៣៥
១. អត្ថន័យ និង លក្ខណៈនៃមតកសាសន៍ ........................................ ៣៦
១.១ និយមន័យ ........................................ ៣៦
១.២ លក្ខណៈនៃមតកសាសន៍ ........................................ ៣៦
២. សមត្ថភាពធ្វើមតកសាសន៍ ........................................ ៣៧
៣. វិធីធ្វើមតកសាសន៍ ........................................ ៣៧
៣.១ គោលគំនិត ........................................ ៣៧
៣.២ ប្រភេទនៃវិធីធ្វើមតកសាសន៍ ........................................ ៣៨
៤. ចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍ ........................................ ៤១
៥. ការលុបចោលនូវមតកសាសន៍ ........................................ ៤២
៥.១ ការលុបចោលដោយមតកសាសន៍ ........................................ ៤២
៥.២ ការលុបចោលដែលច្បាប់កំណត់ ........................................ ៤២
៥.៣ អានុភាពនៃការលុបចោល ........................................ ៤៣
៦. អានុភាពនៃមតកសាសន៍ ........................................ ៤៣
៦.១ អានុភាពនៃមតកសាសន៍ ........................................ ៤៣
៦.២ មោឃភាព និង ការលុបចោលនូវមតកសាសន៍ ........................................ ៤៤
៧. អច្ច័យទាន ........................................ ៤៤
៧.១ អត្ថន័យ លក្ខណៈពិសេស ពេលដែលបង្កើតអានុភាព ........................................ ៤៤
៧.២ ស្តីពីអច្ច័យលាភី ........................................ ៤៥
៧.៣ ការបោះបង់ ការទទួលស្គាល់នូវអច្ច័យទាន ជាអាទិ៍ ........................................ ៤៥
៧.៤ អច្ច័យទានដែលភ្ជាប់បន្ទុក ........................................ ៤៥
៨. ការអនុវត្តមតកសាសន៍ ........................................ ៤៦
៨.១ អត្ថន័យនៃការអនុវត្តមតកសាសន៍ ........................................ ៤៦
៨.២ នីតិវិធីត្រៀមដើម្បីអនុវត្តមតកសាសន៍ (ការពិនិត្យបញ្ជាក់ និង ការបើកលិខិតមតកសាសន៍). ៤៦
៨.៣ ការប្រតិបត្តិមតកសាសន៍ និង អ្នកប្រតិបត្តិមតកសាសន៍ ........................................ ៤៧
**ឧទាហរណ៍នៃមតកសាសន៍** ........................................ ៤៩
**ផ្នែកទី ៣ ភាគបំរុង** ........................................ ៥៥
**ផ្នែកទី ៤ ការបោះបង់សន្តតិកម្ម និង ការយល់ព្រមដោយមានកំរិត** ........................................ ៦៥

**ផ្នែកទី ៥ ឥទ្ធិភាពនៃសន្តតិជន ....................................................................................................................៦៧**

**ជំពូកទី ១០ ច្បាប់នីតិវិធីដែលត្រូវអនុវត្តចំពោះរឿងក្ដីគ្រួសារ ..........................................................................៦៨**

**ផ្នែកទី ១ ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនិងឋានៈបុគ្គល..................................................................................៦៨**

១. តួនាទី និង វិសាលភាពនៃការអនុវត្ត ..........................................................................................................៦៨

២. ចំណុចខុសគ្នានឹងបណ្ដឹងរដ្ឋប្បវេណី......................................................................................................................៦៨

២.១ ភាពខុសគ្នា .................................................................................................................................................៦៨

២.២ បញ្ហាផ្សេង ៗ ...........................................................................................................................................៦៩

២.៣ ការដោះស្រាយតាមរយៈការជំជែកគ្នា - ស្ថានភាពនៅជប៉ុន.............................................................................៦៩

**ផ្នែកទី ២ ច្បាប់ស្ដីពីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង.........................................................................................៧១**

១. រឿងក្ដីដែលត្រូវអនុវត្ត...................................................................................................................................... ៧១

២. លក្ខណៈពិសេសនៃនីតិវិធី.................................................................................................................................. ៧១

៣. ការដោះស្រាយវិវាទតាមរយៈការជំជែកគ្នា ................................................................................................ ៧១

**ផ្នែកទី ៣ សមត្ថកិច្ចនៃតុលាការអន្តរជាតិ ...................................................................................................... ៧៣**

១. រឿងក្ដីសុំលែងលះ............................................................................................................................................ ៧៣

២. រឿងក្ដីបែងចែកមតិក......................................................................................................................................... ៧៣

៣. ច្បាប់ដែលត្រូវអនុវត្តតាម.................................................................................................................................. ៧៣

៣.១ រឿងក្ដីសុំលែងលះគ្នា...................................................................................................................................... ៧៣

៣.២ រឿងក្ដីបែងចែកមតិក .........................................................................................................................................៧៤

# ជំពូកទី ៤

# ញាតិ

## ផ្នែកទី ១

## និយមន័យនៃញាតិ

### ១. ញាតិមាន បី ប្រភេទ

ញាតិលោហិត ត្រូវបានបែងចែកជាបី គឺមានដូចជា :

- ញាតិលោហិតធម្មតា : គឺជាទំនាក់ទំនងញាតិលោហិតផ្ទាល់ និង ទំនាក់ទំនងសាខាញាតិលោហិត ឧទាហរណ៍ : រវាងឪពុកម្តាយ និង កូនបង្កើត, រវាងបងប្អូនបង្កើត

- ញាតិលោហិតដែលច្បាប់កំណត់ : ញាតិលោហិតដែលកំណត់ដោយច្បាប់ អោយមានទំនាក់ទំនងដូចញាតិលោហិតដែរ ឧទាហរណ៍ : ទំនាក់ទំនងកូនស្មុំ និង ឪពុកម្តាយចិញ្ចឹម, ទំនាក់ទំនងរវាងកូនស្មុំ និង កូនរបស់ឪពុកម្តាយចិញ្ចឹម

- ញាតិពន្ធ : ជាទំនាក់ទំនងកើតឡើងដោយសារចំណងអាពាហ៍ពិពាហ៍ ឧទាហរណ៍ ញាតិខាងប្រពន្ធ គឺជាញាតិពន្ធរបស់ប្តី ។

### ២. ទំហំនៃញាតិ

ដោយសារញាតិទាំងមូល វា មានលក្ខណៈទូលាយ និង មានទំហំធំ ដូច្នេះទើប ក្រមរដ្ឋប្បវេណី បានកំណត់យកតែមួយផ្នែកនៃញាតិ ដែលមានទំនាក់ទំនងជិតស្និតប៉ុណ្ណោះ តាមមាត្រា៩៣៨ បុគ្គលដែលបានកំណត់ជាញាតិមានដូចជា:

- ញាតិលោហិត ៦ ថ្នាក់
- ញាតិពន្ធ ៣ ថ្នាក់
- សហព័ទ្ធ

### ២.១ វិធីគណនាថ្នាក់ញាតិ

ក. ការគណនាថ្នាក់ញាតិផ្ទាល់ : ថ្នាក់ញាតិត្រូវកំណត់ដោយគណនាចំនួននៃតំណពូជរវាងញាតិ ។

ខ. ការគណនាថ្នាក់សាខាញាតិ ៖ ដើម្បីកំណត់ថ្នាក់ញាតិនៃសាខាញាតិ ត្រូវគណនាចំនួននៃតំណពូជ គិតចាប់ពីជននោះ ឬ សហព័ទ្ធរបស់ជននោះ ឡើងទៅដល់បុព្វជនដូចគ្នា និង ចំនួននៃតំណពូជ គិតចាប់ពីបុព្វជនរបស់ជននោះ ចុះរហូតមកដល់ជនម្នាក់ទៀត ។

## ២.២ ទំហំញាតិ

យោងតាមមាត្រា ៩៣៨ បុគ្គល ដែលបានកំណត់ជាញាតិ គឺ

- ញាតិលោហិត ៦ ថ្នាក់
- ញាតិពន្ធ ៣ ថ្នាក់
- សហព័ទ្ធ

## ២.៣ ពាក្យបច្ចេកទេស

**ក.** ញាតិផ្ទាល់ ៖ គឺជាញាតិដែលមានឈាមជ័រជាមួយគ្នា ដូចជា ឪពុកម្តាយ និងកូន ។

**ខ.** សាខាញាតិ ៖ ញាតិដែលមានបុព្វជនរួមគ្នា ដូចជាបងប្អូនបង្កើត បងប្អូនជីដូនមួយ ឬ បងប្អូនជីទួតមួយ ។

**គ.** បុព្វញាតិ ៖ ជនដែលស្ថិតក្នុងលំដាប់ថ្នាក់ញាតិខ្ពស់ជាងខ្លួន ។

**ឃ.** បច្ឆាញាតិ ៖ ញាតិក្រោយ ឬ ជនដែលកើតពីជនមួយពួកទៀត ។

**ង.** ញាតិពន្ធ ៖ ចំណងគតិយុត្តរវាងសហព័ទ្ធម្ខាង និងញាតិលោហិត របស់សហព័ទ្ធម្ខាងទៀត ដូចជា ឪពុកម្តាយក្មេក និង កូនប្រសារ ។

## ៣. ការកើតមានឡើង និង ការរលត់នូវទំនាក់ទំនងញាតិភាព

## ៣.១ ការកើតមានឡើង និងការរលត់នូវទំនាក់ទំនងញាតិដោយការសុំកូន

ទំនាក់ទំនងចំពោះការសុំកូន មិនមានទំនាក់ទំនងទៅដល់ញាតិដទៃផ្សេងទៀតរបស់កូនដែលត្រូវបានសុំទេ ប៉ុន្តែ វានាំអោយមានទំនាក់ទំនងចំពោះ ញាតិដោយចំណងអាពាហ៍ពិពាហ៍ និង កូនចៅរបស់អ្នកសុំកូន ។

ដោយសារកូនសុំ មានទំនាក់ទំនងញាតិដូចកូនបង្កើត ដូច្នេះហើយនាំអោយកូនសុំ ក៏មានឋានៈស្មើរនឹងកូនបង្កើតដែរ ( មាត្រា ៩៤០) ។ ប៉ុន្តែទំនាក់ទំនងនេះវាត្រូវរលត់ទៅវិញ បើកូនចិញ្ចឹមនោះ ត្រូវបានកាត់កាលចោល ឬ លែងទទួលស្គាល់ តាមមាត្រា ៩៤២ ។

ផ្ទុយទៅវិញបើកូនសុំ មានប្រពន្ធកូន ក្រោយការសុំ នោះទំនាក់ទំនងញាតិដោយការសុំ មានតែចំពោះបុគ្គល ដែលបានសុំប៉ុណ្ណោះ ។

**៣.២ ការរលត់ទំនាក់ទំនងញាតិពន្ធ**

- តាមរយៈការលែងលះ មាត្រា៩៤១ កថាខណ្ឌទី ១ : ពេលសហព័ទ្ធ ត្រូវបានលែងលះ ឬ ផ្ដាច់ចំណង អាពាហ៍ពិពាហ៍ ទំនាក់ទំនងញាតិពន្ធ ក៏ត្រូវរលាយដែរ ព្រោះទំនាក់ទំនងនេះ កើតឡើងដោយសារចំណង អាពាហ៍ពិពាហ៍ ដូច្នេះ បើចំណងអាពាហ៍ពិពាហ៍ ត្រូវរលាយ នាំអោយទំនាក់ទំនងក៏ត្រូវរលាយដែរ។

- តាមរយៈសហព័ទ្ធម្ខាងស្លាប់ មាត្រា៩៤១ កថាខណ្ឌទី ២ : ករណីសហព័ទ្ធម្ខាងស្លាប់ ហើយសហព័ទ្ធ ម្ខាងទៀតនៅរស់មិនទាន់រៀបអាពាហ៍ពិពាហ៍ថ្មី នោះទំនាក់ទំនងរវាងញាតិពន្ធ ក៏មិនទាន់រលាយដែរ ប៉ុន្តែសហព័ទ្ធ ម្ខាងទៀតនៅរស់ ក៏អាចដាក់ពាក្យស្នើរសុំឱ្យបញ្ចប់ចំណងញាតិពន្ធបានដែរ ដោយមិនចាំបាច់រៀបអាពាហ៍ពិពាហ៍ ថ្មី។

# ផ្នែកទី ២
# កំជាប់ពាក្យ

តាមទំនៀមទំលាប់ប្រទេសជាច្រើន ក៏ដូចជាប្រទេសកម្ពុជា មុនឈានដល់ការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ គឺតែងតែឆ្លងកាត់ពិធីកំជាប់ពាក្យ នៅក្នុងករណីជាច្រើន។

ទោះបីជាក្រមរដ្ឋប្បវេណី មិនបានតំរូវឱ្យមានកំជាប់ពាក្យ នៅមុនការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ក៏ដោយ ក៏ វា ត្រូវមានអានុភាពតាមផ្លូវច្បាប់ នៅពេលដែលកំជាប់ពាក្យនោះ ត្រូវបានធ្វើឡើងនៅមុនពេលរៀបអាពាហ៍ពិពាហ៍ តាមផ្លូវច្បាប់។

## ១. អត្ថន័យ និង លក្ខខណ្ឌនៃការបង្កើត

មាត្រា ៩៤៤ នៃក្រមរដ្ឋប្បវេណី បានចែងថា "កំជាប់ពាក្យ" គឺជាសេចក្តីសន្យារវាងបុរស និង នារី ថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត និង ដោយធ្វើពិធីកំជាប់ពាក្យ។ តាមន័យនៃមាត្រានេះ បុរស និង នារី ដែលមានបំណងរៀបអាពាហ៍ពិពាហ៍នឹងគ្នា អាចបង្ហាញឆន្ទៈដោយសេរីក្នុងការបង្កើតកំជាប់ពាក្យ ហើយបើគ្រាន់តែមានសេចក្តីសន្យារវាងបុរស និង នារី ថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលខាងមុខ វា មិនគ្រប់គ្រាន់នៅឡើយទេ។ ដើម្បីឱ្យកំជាប់ពាក្យមានសុពលភាពទេ វា ចាំបាច់ត្រូវមានធ្វើពិធីកំជាប់ពាក្យតាមប្រពៃណីបន្ថែមទៀត។

## ២. អានុភាព

ជាទំលាប់ នៅពេលមានពិធីកំជាប់ពាក្យ គឺតែងតែមានការជូនជាជំនូន អាចភាគីខាងប្រុសជាអ្នកជូន ឬក៏អាចភាគីខាងស្រីជាអ្នកជូនដែរ។ ជំនូននៅទីនេះ អាចជាប្រាក់កាស និង ជាទ្រព្យផ្សេងៗ។ កំជាប់ពាក្យ ត្រូវបានបង្កើត ក៏ប៉ុន្តែដោយសារហេតុផលអ្វីមួយ ធ្វើអោយកំជាប់ពាក្យត្រូវរលាយទៅវិញ តើការរលាយនៃកំជាប់ពាក្យនេះ មានអានុភាពយ៉ាងណាដែរ ចំពោះគូភាគី?

ក. ភាគីអាចទាមទារឱ្យសងជំនូន : ភាគី ដែលបានលើកជំនូននៅពេលកំជាប់ពាក្យ ដោយការសង្ឃឹមថាខ្លួននឹងបានរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែកំជាប់ពាក្យ ត្រូវបានរលាយទៅវិញ ភាគីនោះ អាចទាមទារអោយភាគីម្ខាងទៀត សងជំនូនមកវិញបាន ( មាត្រា ៩៤៥ នៃក្រមរដ្ឋប្បវេណី) ។ តាមខ្លឹមសារនៃមាត្រា ៩៤៥ នៃក្រមរដ្ឋប្បវេណីនេះ ទោះបីជាភាគី ដែលលើកជំនូនមានកំហុស ឬ គ្មានកំហុសក្នុងការរលាយកំជាប់ពាក្យក៏ដោយ ក៏ ភាគីនោះ អាចទាមទារអោយភាគីម្ខាងទៀតសងជំនូនមកវិញបានដែរ។

ខ. ភាគី អាចទាមទារឱ្យសងសំណងនៃការខូចខាត ៖ កំជាប់ពាក្យ គឺជាដំណើរការសង្គម ដែលជាមូលដ្ឋាននៃអាពាហ៍ពិពាហ៍តាមច្បាប់ ហើយ មានអត្ថន័យតាមផ្លូវច្បាប់លើសពីអ្វី ដែលគ្រាន់តែជាកិច្ចព្រមព្រៀងសាមញ្ញ។ ហេតុដូចនេះ បើចេះតែឱ្យភាគី អាចរំលាយកំជាប់ពាក្យបានដោយសេរី ទោះបីជាភាគី ដែលសុំរំលាយ មានកំហុសនោះ វា អាចប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ និង ទំនៀមទំលាប់ល្អរបស់សង្គម ដូចនេះ ទើបក្រមរដ្ឋប្បវេណី បានបញ្ញត្តិមាត្រា ៩៤៦ នៃក្រមរដ្ឋប្បវេណី ដែលដាក់កំរិតចំពោះភាគី ដែលមានកំហុសក្នុងការរំលាយកំជាប់ពាក្យ ត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាត។ វា មានន័យថាបើភាគីម្ខាង បដិសេធកំជាប់ពាក្យ ដោយគ្មានមូលហេតុត្រឹមត្រូវ ភាគីម្ខាងទៀតនៃកំជាប់ពាក្យ អាចទាមទារសំណងនៃការខូចខាតដែលកើតឡើង ដោយសារការបដិសេធចោលនោះបាន ដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច ឬ អំពើអនីត្យានុកូល។

## ៣. អំឡុងពេលនៃការទាមទារ

ការទាមទារអោយសងជំនូន (មាត្រា ៩៤៥ នៃក្រមរដ្ឋប្បវេណី) និង ការទាមទារសំណងនៃការខូចខាត (មាត្រា ៩៤៦ នៃក្រមរដ្ឋប្បវេណី) អ្នកដែលមានបំណងទាមទារ ត្រូវដាក់ពាក្យបណ្តឹងទៅតុលាការ ក្នុងអំឡុងពេល ០១ ឆ្នាំ គិតចាប់ពីថ្ងៃកំជាប់ពាក្យបានរលាយ។

ករណីសិក្សា ៖

**ក** បានភ្ជាប់ពាក្យជាមួយ **ខ** ដោយ **ក** បានជូនឡានម៉ាកកាមេរីមួយគ្រឿង និង លុយ ៥០០០ ដុល្លា ជាជំនូនក្នុងពិធីកំជាប់ពាក្យនោះ។ បន្ទាប់ពីកំជាប់ពាក្យ បានរយៈពេល ១ខែ ស្រាប់តែ **ខ** ដឹងថា **ក** មានប្រពន្ធហើយ **ខ** និង **ក** ក៏មានការឈ្លោះប្រកែកគ្នាយ៉ាងខ្លាំង រហូតព្រមព្រៀងគ្នារលាយកំជាប់ពាក្យ។ ក្រោយពីរលាយកំជាប់ពាក្យ **ក** ក៏ដាក់ពាក្យបណ្តឹងទៅតុលាការទាមទារជំនូន (ឡានម៉ាកកាមេរីមួយគ្រឿង និង លុយ ៥០០០ ដុល្លា) ពី **ខ** មកវិញ ហើយ **ខ** ក៏បានដាក់ពាក្យបណ្តឹងទាមទារសំណងការខូចខាតពី **ក** ដែរ។ តើ **ក** អាចទាមទារជំនូនបានដែរ ឬ ទេ? ហើយតើ **ខ** អាចទាមទារសំណងការខូចខាតបានដែរ ឬ ទេ?

ចំលើយ ៖

តាមមាត្រា ៩៤៥ នៃក្រមរដ្ឋប្បវេណី នៅពេលកំជាប់ពាក្យបានរលាយ **ក** អាចប្តឹងទាមទារឡានម៉ាកកាមេរីមួយគ្រឿង និង លុយ ៥០០០ ដុល្លា ពី **ខ** បាន។

តាមមាត្រា ៩៤៦ នៃក្រមរដ្ឋប្បវេណី នៅពេលកំជាប់ពាក្យបានរលាយ **ខ** អាចប្តឹងទាមទារសំណងការខូចខាតពី **ក** បាន។

## ផ្នែកទី ៣

## ឪពុកម្តាយ និង កូន

ទំនាក់ទំនងឪពុកម្តាយ និងកូន គឺជាទំនាក់ទំនងរវាងមនុស្សប្រុស និងមនុស្សស្រីនៅក្នុងគ្រួសារ ដែលជាកោសិកាតូចៗ នៅក្នុងសង្គម ។

### ១. ឪពុកម្តាយ និង កូន

ទំនាក់ទំនងឪពុកម្តាយ និងកូននេះ ត្រូវបានបែងចែកជាពីរប្រភេទ គឺ :

**ក.** ទំនាក់ទំនងរវាងឪពុកម្តាយបង្កើត និង កូនបង្កើត

**ខ.** ទំនាក់ទំនងរវាងឪពុកម្តាយបង្កើត និង កូនសុំ

### ២. ទំនាក់ទំនងឪពុកម្តាយ និង កូនបង្កើត

ជាសត្យានុម័ត ដើម្បីមានកូនបានលុះត្រាតែមានឪពុក និងម្តាយ ជាអ្នកបង្កើតកូន ទើបកូននោះ អាចកើតមានរូបរាងឡើងបាន ។

**តើអ្នកណាជាឪពុកម្តាយរបស់កូន ? តើត្រូវកំណត់ដោយផ្អែកលើអង្គហេតុអ្វីខ្លះ ?**

ឪពុកម្តាយរបស់កូន គឺជាបុរស និង ស្ត្រីដែលបានបង្កើតកូន។ ចំពោះម្តាយ មានភាពងាយស្រួលក្នុងការកំណត់ ព្រោះម្តាយ គឺជាអ្នកបង្កើតកូនដោយផ្ទាល់ ឯឪពុកវិញ មានភាពលំបាកជាងម្តាយក្នុងការកំណត់ភាពជាឪពុកនេះ ព្រោះ ឪពុក មិនមែនជាអ្នកបង្កើតកូនដោយផ្ទាល់នោះទេ ដូច្នេះ ក្រមរដ្ឋប្បវេណី កំណត់អំពីទំនាក់ទំនងឪពុក និង កូន ដោយផ្អែកលើទំនាក់ទំនងម្តាយ និង កូន ឬ ដោយផ្អែកលើការទទួលស្គាល់ពីបុរសនេះ។

**លក្ខខ័ណ្ឌ និង អង្គហេតុដែលអាចកំណត់ពីភាពជាឪពុកបាន :**

**ក.** ជាដំបូងគេ ត្រូវពិនិត្យមើលពីទំនាក់ទំនងរវាងម្តាយ និង កូនសិន បន្ទាប់មកទើបគេ ពិនិត្យពីទំនាក់ទំនងរបស់បុរសជាមួយស្ត្រី ដែលជាម្តាយនោះ រួចទើបអាចកំណត់ និង សន្មតបានថា បុរសនោះ ជាឪពុករបស់កូននោះ។

**ខ.** មានការទទួលស្គាល់ពីបុរស ដែលជាឪពុកដោយផ្ទាល់ ហើយនិង មានការយល់ព្រមពីស្ត្រីជាម្តាយផងដែរ ទើបអាចកំណត់ និង សន្មតបានថា បុរសនោះ គឺជាឪពុករបស់កូន។

### ២.១ បទប្បញ្ញត្តិទូទៅ

**ការសុំចុះសំបុត្រកំណើត**

ក្រមរដ្ឋប្បវេណី មាត្រា ៩៨៥ បានចែងថា ឪពុក ឬ ម្តាយរបស់កូន ត្រូវសុំចុះសំបុត្រកំណើតរបស់កូន នៅសាលាឃុំ សង្កាត់នៃលំនៅដ្ឋានរបស់ឪពុក ឬ ម្តាយ ក្នុងអំឡុងពេល ៣០ ថ្ងៃគិតចាប់ពីថ្ងៃ ដែលកូននោះកើត។ ប្រសិនបើឪពុក ឬ ម្តាយ មិនអាចសុំចុះបានទេ ញាតិជានីតិជនដែលរស់នៅជាមួយឪពុកម្តាយនៃកូន ត្រូវសុំចុះសំបុត្រកំណើតរបស់កូននោះ ឱ្យបានឆាប់រហ័ស ។

ក្នុងករណីដែលឪពុកម្តាយ ធ្វេសប្រហែស ក្នុងការបំពេញករណីយកិច្ច ដែលបានកំណត់នៅក្នុងកថាខ័ណ្ឌទី ១ ខាងលើដោយគ្មានមូលហេតុត្រឹមត្រូវ ពួកគាត់ នឹងត្រូវពិន័យស៊ីវិលជាប្រាក់មិនលើសពី ១០,០០០ ៛ ( មួយម៉ឺនរៀល) ។

## ២.២ ការសម្រេចអំពីបុត្តភាព

### ២.២.១ មាតុភាព

ក្រមរដ្ឋប្បវេណីមាត្រា ៩៨៧ បានចែងថា ស្ត្រី ដែលបានសម្រាលកូន គឺជាម្តាយរបស់កូន។ ក្នុងស្មារតីនៃមាត្រានេះ ចង់បញ្ជាក់អំពីភាពច្បាស់លាស់មួយ ដែលមិនអាចប្រកែកបាន ហើយមានលក្ខណៈសមហេតុផលបំផុត ដូច្នេះ អង្គហេតុមួយ ដែលស្ត្រីជាម្តាយបានសម្រាលកូន គឺកូននោះឯង ត្រូវតែជាកូនរបស់ស្ត្រីនោះ។ ហើយម្យ៉ាងទៀត ចំពោះអង្គហេតុសម្រាលកូននេះ មិនត្រឹមតែអាចកំណត់អំពីចំណងមាតុភាព ដែលកើតជំណាលពេល និង ចំណងបុត្តភាពនោះទេ អាចឱ្យគេនឹកឃើញពីចំណងបិតុភាពផងដែរ ចំពោះបុរស ដែលមានទំនាក់ទំនងនឹងម្តាយនោះ។

ការកំណត់ក្នុងមាត្រានេះ ដែលលើកពីអង្គហេតុសម្រាលកូនក្នុងការសន្មត អំពីមាតុភាព អាចនឹងមានបញ្ហានាពេលអនាគតផងដែរ ប្រសិនបើការសម្រាលកូនតាមបែបសិប្បនិម្មិត បង្កើតឡើងតាមរយៈបច្ចេកវិជ្ជា ដោយបុរស និង ស្ត្រី បានព្រមព្រៀងយកមេជីវិតរបស់ខ្លួនឱ្យទៅស្ត្រីផ្សេងជាអ្នកពរពោះជំនួស ដូច្នេះ គឺវាផ្ទុយនឹងមាត្រានេះអំពីការសន្មត មាតុភាព។ ក៏ប៉ុន្តែបញ្ហានេះ យើងនឹងមិនធ្វើការបកស្រាយលម្អិតឡើយ ដោយសារតែប្រទេសខ្លះ បដិសេធមិនឱ្យមានការសម្រាលកូនតាមបែបសិប្បនិម្មិតនេះ ហើយស្ថានភាពនៅប្រទេសកម្ពុជា ក៏មិនទាន់មាន និង ក៏មិនមែនជាបញ្ហាចំពោះមុខ ដែរ ។

### ២.២.២ បិតុភាព

ក្រមរដ្ឋប្បវេណីមាត្រា ៩៨៨ បានចែងថា :

១. ទារកនៅក្នុងគភ៌ប្រពន្ធ ដែលមាននៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ត្រូវសន្មតថាជាកូនរបស់ប្តី។

**២**. កូនដែលបានកើតនៅក្រោយអំឡុងពេល ១៨០ ( មួយរយប៉ែតសិប ) ថ្ងៃ គិតចាប់ពីថ្ងៃ ដែលអាពាហ៍ពិពាហ៍ ត្រូវបានបង្កើត ឬ លុបចោលអាពាហ៍ពិពាហ៍ ត្រូវសន្មតថា មានគភ៌នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍នោះ ។

**៣**. ក្នុងករណីដែលស្ត្រីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៥០ ( អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ) នៃក្រមនេះ បានបង្កើតកូន ប្រសិនបើមិនអាចកំណត់ឪពុករបស់កូននោះដោយ យោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ និងទី២ ខាងលើនេះទេ ត្រូវសន្មតថា កូនជាកូនរបស់ប្តី ដែលបានរៀបអាពាហ៍ពិពាហ៍ក្រោយ ។

កថាខណ្ឌទី១ នៃមាត្រានេះ ចែងអំពីការមានគភ៌របស់ប្រពន្ធ ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ត្រូវសន្មតថា ជាកូនរបស់ប្តី ។

មូលហេតុដែលកំណត់ដូច្នេះ គឺមានន័យថា ដោយសារតែប្តី និង ប្រពន្ធ បានធ្វើការរួមរស់នៅជាមួយគ្នា ដែលប្តី និង ប្រពន្ធនោះ បានរួមរក្សគ្នាក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ។

ដោយផ្អែកលើគោលការណ៍នេះ ទើបប្រើពាក្យ "សន្មត" ប៉ុន្តែបើមានករណី ដែលឪពុក មានការអះអាងផ្សេង ដែលបង្ហាញថា ខ្លួនមិនមែនជាឪពុក បុរសនោះ អាចដាក់ពាក្យសុំបដិសេធបិតុភាព ទៅតុលាការបាន ដោយផ្អែកលើមាត្រា ៩៨៩ ការបដិសេធបិតុភាព នៃក្រមរដ្ឋប្បវេណីបាន ។

**ឧទាហរណ៍ :** ឆ្នាំ ១៩៤៦ **ក** និង **ខ** រៀបអាពាហ៍ពិពាហ៍ជាមួយគ្នា

១៩៤៩ **ក** និង **ខ** បានរស់នៅបែកគ្នា

១៩៥០ **ខ** និង **គ** មានទំនាក់ទំនងផ្លូវភេទជាមួយគ្នា

១៩៥១ **ខ** បង្កើតបានកូន **ឃ** ម្នាក់

១៩៥២ **ក** និង **ខ** បានលែងលះគ្នា

នៅក្នុងករណីនេះ ទោះបី **ក** និង **ខ** បានរស់នៅបែកគ្នាក៏ដោយ ហើយ ទោះបីជាឈាមរបស់ **ក** និង **ឃ** ខុសគ្នាក៏ដោយ តើលោក លោកស្រី គួរសន្មត ដោយផ្អែកលើមាត្រា ៩៨៨ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ថា **ក** ជាឪពុករបស់ **ឃ** ដែរ ឬ ទេ ?

**២.២.៣ ការបដិសេធបិតុភាព**

- ការបដិសេធបិតុភាពមានចែងក្នុងមាត្រា ៩៨៩
- វិធីបដិសេធបិតុភាពមានចែងក្នុងមាត្រា ៩៩០ , ៩៩១

- អំឡុងពេលនៃការដាក់ពាក្យបណ្ដឹងបដិសេធបិតុភាពមាត្រា ៩៩០ កថាខណ្ឌទី១ . ៩៩១ កថាខណ្ឌទី ៣
- អានុភាពប្រតិសកម្មនៃបណ្ដឹងបដិសេធបិតុភាពមាត្រា ៩៩២

**២.២.៤ កថាភាគទី៣ ការទទួលស្គាល់បិតុភាព**

**២.២.៤.១ ការទទួលស្គាល់ដោយស្ម័គ្រចិត្ត ( មាត្រា ៩៩៣)**

ឪពុករបស់កូន អាចទទួលស្គាល់កូននោះបាន។ ប៉ុន្តែ ប្រសិនបើកូននោះ មានឪពុកតាមផ្លូវច្បាប់រួចហើយ ពុំអាចទទួលស្គាល់បានឡើយ ។

ក្នុងស្មារតីមាត្រា ៩៩៣ នេះ ការទទួលស្គាល់ដោយស្ម័គ្រចិត្ត អាចធ្វើបាន ប៉ុន្តែមិនអាចធ្វើបានឡើយ ក្នុងករណីដែលកូននោះ មានឪពុកតាមផ្លូវច្បាប់រួចហើយ ដោយយោងមាត្រា ៩៩៨ កថាខណ្ឌទី ១។

មានន័យថា ការទទួលស្គាល់នេះ ទោះបីជាធ្វើឡើងដោយឪពុកបង្កើតរបស់កូននោះ ក៏ដោយ ក៏មិនអាចធ្វើបានដែរ។

**ឧទាហរណ៍ : ក** ត្រូវបានសន្មតថាជាឪពុករបស់ **ឃ** ដែលមាន **ខ** ជាម្ដាយ។ ក្រោយមក **គ** បានអះអាងថា ខ្លួនជាឪពុករបស់ **ឃ** ហើយ មានបំណងចង់ទទួលស្គាល់កូននោះ។

ករណីនេះអាច :

**ឃ** អាចដាក់ពាក្យបណ្ដឹងបដិសេធបិតុភាពចំពោះ **ក** បាន

**ខ** អាចដាក់ពាក្យបណ្ដឹងបដិសេធបិតុភាពចំពោះ **ក** បាន

ប៉ុន្តែ **គ** មិនអាចដាក់ពាក្យបណ្ដឹងបដិសេធបិតុភាពចំពោះ **ក** បានទេ ប្រសិនបើ **ឃ** និង **ខ** មិនដាក់ពាក្យបណ្ដឹងបដិសេធបិតុភាពចំពោះ **ក** ។

**ស្ដីពីការទទួលស្គាល់កូន**

**ក.** កូនជាអនីតិជន : ឪពុក អាចទទួលស្គាល់កូនជាអនីតិជនបាន ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកណាឡើយ ។ ( មាត្រា ៩៩៥ កថាខណ្ឌទី១ )

**ខ.** ទារកនៅក្នុងគភ៌ : ឪពុក អាចទទួលស្គាល់ទារកនៅក្នុងគភ៌ថាជាកូនបាន លុះត្រាតែមានការយល់ព្រមពីម្ដាយរបស់កូននោះ ។( មាត្រា ៩៩៥ កថាខណ្ឌទី២ )

**គ.** កូនជានីតិជន : ឪពុក អាចទទួលស្គាល់កូនជានីតិជនបាន លុះត្រាតែមានការយល់ព្រមពីកូននោះ។ ( មាត្រា ៩៩៦ កថាខណ្ឌទី១)

នីតិវិធី និង ទម្រង់នៃការទទួលស្គាល់កូន មានចែងក្នុងមាត្រា ៩៩៧ កថាខណ្ឌទី១ ដែលបានបញ្ញត្តថា :

**ក.** ការទទួលស្គាល់ នឹងត្រូវធ្វើឡើងដោយការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន។ ការទទួលស្គាល់ ក៏អាចធ្វើតាមមតកសាសន៍ក៏បានដែរ ។

**ខ.** ការយល់ព្រមរបស់ម្តាយ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៩៩៥ ( ការទទួលស្គាល់របស់ឪពុក ) ខាងលើនេះ អាចធ្វើបាន ដោយចុះហត្ថលេខាលើលិខិតទទួលស្គាល់នោះ ។

អានុភាពនៃការទទួលស្គាល់កូនមានចែងក្នុងមាត្រា :

- មាត្រា ៩៩៨ អានុភាពនៃការចុះកំណើតនៅក្នុងសៀវភៅកំណើត និងការទទួលស្គាល់
- មាត្រា ៩៩៩ អានុភាពប្រតិសកម្មនៃការទទួលស្គាល់
- មាត្រា ១000 ការហាមឃាត់មិនឱ្យដកការទទួលស្គាល់ចេញ

(ន័យក្នុងមាត្រា ១000 នេះ ប្រើបានត្រឹមតែអាជ្ញាធរប៉ុណ្ណោះ គឺឪពុក ដែលបានទទួលស្គាល់កូនហើយមិនអាចដកការទទួលស្គាល់នោះបានទេ តែបើឪពុកនោះ ដាក់ពាក្យបណ្តឹងទៅតុលាការ នោះអាចដកការទទួលស្គាល់នោះបាន ប្រសិនបើមានមូលហេតុ និងភស្តុតាង។

### ២.២.៤.២ បណ្តឹងទាមទារឱ្យទទួលស្គាល់

ការទទួលស្គាល់ដោយបង្ខំ អាចធ្វើបានដោយមានចែងក្នុងមាត្រា ១00១ នៃក្រមរដ្ឋប្បវេណី ។

### ២.២.៤.៣ បណ្តឹងទាមទារបញ្ជាក់អំពីអត្ថិភាពនៃបុត្តភាព ( *ការបដិសេធបិតុភាព*)

អ្នកដែលមានសិទ្ធិដាក់ពាក្យបណ្តឹង មានដូចខាងក្រោម :

- កូន មាត្រា ១00២ កថាខណ្ឌទី ១
- ឪពុក មាត្រា ១00២ កថាខណ្ឌទី ២
- ម្តាយ មាត្រា ១00២ កថាខណ្ឌទី ៣

មានករណី 0៣ យ៉ាង ដែលមិនអាចដាក់ពាក្យបណ្តឹងបាន មានចែងក្នុងមាត្រា ១00២ កថាខណ្ឌទី ៤ គឺ :

- ឪពុក ឬ ម្តាយដែលបានទទួលស្គាល់កូនរួចហើយដោយចេតនា
- ឪពុក ឬ ម្តាយដែលមានកំហុសធ្ងន់ធ្ងរ ដែលបានចុះឈ្មោះរួចហើយក្នុងសៀវភៅកំណើតរបស់កូន
- អំឡុងពេល ២០ ឆ្នាំ បានកន្លងផុត គិតចាប់ពីថ្ងៃកំណើតរបស់កូន ឬ ថ្ងៃដែលអនុភាពនៃការទទួលស្គាល់កូនបានកើតឡើង។

### ២.២.៤.៥ បណ្តឹងទាមទារឱ្យបញ្ជាក់អត្ថិភាពនៃមាតុភាព

មានចែងក្នុងមាត្រា ១០០៤ និង ១០០៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

- កូនអាចដាក់ពាក្យបណ្តឹងបានតាមមាត្រា ១០០៤

- ម្តាយអាចដាក់ពាក្យបណ្តឹងបានតាមមាត្រា ១០០៥

អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព មានចែងក្នុងមាត្រា ១០០៦ ដែលអានុភាព នេះ មាន ទំនាក់ទំនងសំខាន់ចំពោះសន្តិកម្ម ។

## ៣. សុំកូន

### ៣.១ អត្ថន័យនៃរបបសុំកូន

របបសុំកូន គឺជារបបទទួលស្គាល់ឱ្យជន ដែលគ្មានទំនាក់ទំនងសាច់ញាតិ បង្កើតនូវទំនាក់ទំនងជាឪពុកម្តាយ និង កូន ដូចឪពុកម្តាយនិងកូនបង្កើតដែរ ។

គោលបំណងនៃរបបសុំកូន គឺ :

**ក.** អ្នកដែលគ្មានអ្នកណាស្នង អាចរកអ្នកស្នងបានតាមរយៈសុំកូន (ឱ្យស្នងអាជីវកម្ម)

**ខ.** គ្រួសារ, សន្តតិកម្ម ទ្រព្យសម្បត្តិ ជាអាទិ៍ ។

**គ.** ចំពោះអ្នកដែលគ្មានកូន អាចរកកូនបាន (ដើម្បីឱ្យកូនផ្គត់ផ្គង់អាហារកិច្ច នៅពេលដែលខ្លួនចាស់ ជាអាទិ៍)

**ឃ.** រកឪពុកម្តាយសំរាប់កុមារកំព្រា

ចំពោះចំណុច ក និង ខ គឺជា "សុំកូនសំរាប់ស្នងគ្រួសារ" ឬ "សុំកូនសំរាប់ឪពុកម្តាយ" រីឯចំណុច គ និង ឃ វិញ គឺជា "សុំកូនសំរាប់កូន" ។

នៅកម្ពុជា ក្រមរដ្ឋប្បវេណី មានចែងអំពីរបបសុំកូនពីរ គឺសុំកូនពេញលេញ (ពីមាត្រា ១០០៧ ទៅ) និង សុំកូនធម្មតា (ពីមាត្រា ១០២០ ទៅ) ។ សុំកូនធម្មតា គឺជារបបសុំកូន ក្នុងគោលបំណង "សុំកូនសំរាប់ស្នងគ្រួសារ" និង "សុំកូនសំរាប់ឪពុកម្តាយ" ។ រីឯសុំកូនពេញលេញ គឺជារបបសុំកូនក្នុងគោលបំណង "សុំកូនសំរាប់កូន" ។

ក្នុងករណីដែលមានទំនាក់ទំនងដូចឪពុកម្តាយ និង កូនបង្កើត តាមរយៈសុំកូន ទំនាក់ទំនងគតិយុត្តិរវាងឪពុកម្តាយ និង កូន ត្រូវបានបង្កើតឡើង រវាងកូនសុំ និង ឪពុកម្តាយចិញ្ចឹមនោះ ។ ទស្សនៈស្តីពីទំនាក់ទំនងរវាងឪពុកម្តាយ និង កូនសុំ មានពីរបែប គឺ ១. ទំនាក់ទំនងឪពុកម្តាយ និង កូនបង្កើត មានអត្ថិភាពតាមផ្លូវច្បាប់ ២. ទំនាក់ទំនងឪពុកម្តាយ និង កូនបង្កើត ត្រូវរលត់តាមផ្លូវច្បាប់ ។

របបស្មុំកូនពេញលេញក្នុងក្រមរដ្ឋប្បវេណីកម្ពុជា គឺមានគោលគំនិតបង្កើតទំនាក់ទំនងរវាងឪពុកម្តាយ និង កូន ដូចឪពុកម្តាយ និង កូនបង្កើតដែរ ហេតុនេះហើយ ពេលដែលបានសុំកូន ទំនាក់ទំនងរវាងឪពុកម្តាយ និង កូនបង្កើត ត្រូវរលត់តាមផ្លូវច្បាប់ ( មាត្រា ១០១៤)

### ៣.២ ស្មុំកូនធម្មតា

ស្មុំកូនធម្មតា អាចបង្កើតឡើងតាមរយៈកិច្ចសន្យា រវាងភាគីទាំងសងខាង ក្នុងគោលបំណងបង្កើតនូវអានុភាពដូចគ្នានឹងរវាងឪពុកម្តាយ និង កូនបង្កើតធម្មជាតិ ។

ខ្លឹមសារនេះ គឺជាខ្លឹមសារ ដែលច្បាប់កំណត់ ដូច្នេះ មិនអាចដាក់លក្ខខណ្ឌ ឬ កំណត់អំឡុងពេលបានឡើយ ។ ម្យ៉ាងទៀត មិនអនុញ្ញាតឱ្យបង្កើតប្រការពិសេស ដែលផ្ទុយនឹងអ្វី ដែលច្បាប់កំណត់ទេ (ឧទាហរណ៍ ប្រការពិសេស ដែលមានខ្លឹមសារ "ផ្តល់អាហារកិច្ច តែមិនផ្តល់សិទ្ធិសន្តតិកម្ម") ។

#### ៣.២.១ លក្ខខណ្ឌដើម្បីបង្កើតស្មុំកូនធម្មតា

ដើម្បីស្មុំកូនធម្មតា ត្រូវស្របនឹងលក្ខខណ្ឌទម្រង់ (ការដាក់ពាក្យសុំទៅតុលាការ និង ដីកាសំរេចរបស់តុលាការ) ផង និង លក្ខខណ្ឌជាសារធាតុ ( លក្ខខណ្ឌដើម្បីឱ្យតុលាការ ចេញដីកាសំរេចបង្កើតស្មុំកូននោះ) ផង ។

##### ៣.២.១.១ លក្ខខណ្ឌទំរង់

ដើម្បីបង្កើតស្មុំកូនធម្មតា ត្រូវដាក់ពាក្យសុំទៅតុលាការ ( មាត្រា ១០២០) ហើយ តុលាការ នឹងចេញដីកាសំរេច ( មាត្រា ១០២៣ ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង មាត្រា ៣ កថាខណ្ឌទី ១ និង ទី ២, តារាងឧបសម្ព័ន្ធ ផ្នែកទី ៤ ចំណុចទី ៩) នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង ។

មានន័យថា អ្នកដែលនឹងក្លាយទៅជាឪពុកម្តាយចិញ្ចឹម និង អ្នកដែលនឹងក្លាយទៅជាកូនសុំ ត្រូវដាក់ពាក្យសុំទៅតុលាការ ដើម្បីបង្កើតស្មុំកូនធម្មតា ហើយ តុលាការ នឹងចេញដីកាសំរេចឱ្យបង្កើតស្មុំកូន ។ ពេលនោះ ស្មុំកូនធម្មតា ក៏ត្រូវបានបង្កើតឡើង ។

##### ៣.២.១.២ លក្ខខណ្ឌជាសារធាតុ

ប្រសិនជាការដាក់ពាក្យស្មុំកូនធម្មតា មិនស្របទៅនឹងលក្ខខណ្ឌ ដូចខាងក្រោមនេះទេ តុលាការ នឹងមិនអនុញ្ញាតឱ្យបង្កើតទេ ។

ក. ទាល់តែភាគីទាំងសង មានឆន្ទៈស្មុំកូន ( មាត្រា ១០២៣)

ចាំបាច់ត្រូវមានឆន្ទៈសុំកូនពិតប្រាកដ ក្នុងការបង្កើតសុំកូន រវាងភាគីទាំងសង។

ក្នុងករណី ដែលមានការប្រើសិទ្ធិដោយបំពាន ក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍ (រវាងអ្នកមានភេទខុសគ្នា ឬ រវាងអ្នកមានភេទដូចគ្នា) តុលាការ មិនអនុញ្ញាតឱ្យបង្កើតសុំកូនឡើយ។

**ខ.** អ្នកដែលនឹងក្លាយទៅជាឪពុកម្ដាយ ត្រូវមានអាយុ ២៥ ឆ្នាំ ឡើងទៅ (មាត្រា ១០២០ កថាខណ្ឌទី ១)

**គ.** អ្នកដែលនឹងក្លាយទៅជាកូនសុំ មិនត្រូវជាបុព្វញាតិ ឬក៏មានអាយុច្រើនជាងអ្នក ដែលនឹងក្លាយទៅជាឪពុកម្ដាយចិញ្ចឹមបានឡើយ (មាត្រា ១០២០ កថាខណ្ឌទី ១)

**ឃ.** សុំកូន ដោយអ្នកដែលមានសហព័ទ្ធ (មាត្រា ១០២១, មាត្រា ១០២២)

ជនដែលមានសហព័ទ្ធ ដើម្បីសុំកូនដែលជាអនីតិជន ត្រូវដាក់ពាក្យសុំកូនជាមួយសហព័ទ្ធ (មាត្រា ១០២១)

ជនដែលមានសហព័ទ្ធ ដើម្បីសុំកូនធម្មតា ត្រូវមានការយល់ព្រមពីសហព័ទ្ធ (មាត្រា ១០២២)

នេះ គឺដោយសារតែ តាមរយៈសុំកូននេះ អាចមានឥទ្ធិពលទៅលើជីវភាពរស់នៅ ជាក់ស្ដែង ដូចជា សន្តតិកម្ម អាហារកិច្ច ត្រកូល ជាដើម។

**ង.** សុំកូនដែល កូននោះជាអនីតិជន (មាត្រា ១០២៤)

បើសិនជាអ្នកដែលនឹងក្លាយទៅជាកូនសុំ ជាអនីតិជន តុលាការ ទទួលស្គាល់នូវសុំកូននេះ តែក្នុងករណីដែលមានភាពចាំបាច់ ដើម្បីការពារផលប្រយោជន៍របស់អនីតិជននេះ ប៉ុណ្ណោះ។

បើសិនជាអ្នក ដែលនឹងក្លាយជាកូនសុំ មានអាយុ ១៥ ឆ្នាំ ឬក៏បើសិនជាអ្នកនោះ អាចបង្ហាញឆន្ទៈបាន តុលាការ ត្រូវសួរមតិរបស់អ្នកនោះ។

**ច.** សុំកូនរវាងអ្នកអាណាព្យាបាល និង អ្នកនៅក្រោមអាណាព្យាបាល (មាត្រា ១០២៥)

តុលាការ អាចទទួលស្គាល់បាន តែក្នុងករណី ដែលបានអនុវត្តត្រឹមត្រូវក្នុងការគ្រប់គ្រងថែរក្សា ជននៅក្រោមអាណាព្យាបាល និង ការគ្រប់គ្រងទ្រព្យសម្បត្តិប៉ុណ្ណោះ។

### ៣.២.២ អានុភាពនៃសុំកូនធម្មតា (មាត្រា ១០២៦, មាត្រា ១០២៧)

#### ៣.២.២.១ អានុភាពនៃសុំកូនធម្មតា

ទោះបីជាបានបង្កើតសុំកូនក៏ដោយ ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ត្រូវបន្តនូវអត្ថិភាពដដែល (មាត្រា ១០២៦)។ ស្ដីពីសន្តតិកម្ម អ្នកទាំងពីរនៅតែមានសិទ្ធិធ្វើសន្តតិកម្មគ្នា ទៅវិញទៅមកដែរ ហើយ ត្រូវមានបន្ទុកនូវសិទ្ធិ និង កាតព្វកិច្ចអាហារកិច្ចទៅវិញទៅមក។

ស្តីពីទំនាក់ទំនងរវាងឪពុកម្តាយចិញ្ចឹមវិញ បើសិនជាបានបង្កើតស្មុំកូនធម្មតាទៅ កូនសុំនោះ នឹងមានឋានៈបុគ្គលដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនោះដែរ ហើយ នឹងមានសិទ្ធិ និង កាតព្វកិច្ចពាក់ព័ន្ធនឹងឪពុកម្តាយដូចគ្នានឹងកូនបង្កើតដែរ ( មាត្រា ១០២៧ កថាខណ្ឌទី ១, មាត្រា ១០១៥ កថាខណ្ឌទី ១) ។ ម្យ៉ាងទៀត កូនសុំនោះ អាចយកត្រកូលរបស់ឪពុកម្តាយចិញ្ចឹមក៏បាន ឬក៏អាចទុកត្រកូលចាស់ដដែលក៏បាន ។

បើសិនជាបានបង្កើតស្មុំកូនធម្មតាហើយ ត្រូវសរសេរអំពីស្មុំកូនធម្មតា នៅលើវិមទំព័រនៃបញ្ជីកំណើតដើមរបស់កូននោះ ( មាត្រា ១០៣៣) ។

| |
|---|
| ឧទាហរណ៍<br>ក្នុងករណី ដែលកូនបង្កើត A របស់ឪពុកម្តាយបង្កើត A1 និង A2 បានក្លាយជាកូនសុំ តាមរយៈស្មុំកូនធម្មតា របស់ឪពុកម្តាយចិញ្ចឹម B1 និង B2 ។<br>A នឹងមានទំនាក់ទំនងជាសាច់ញាតិនឹង A1 និង A2 ដដែលផង ហើយនឹងមានឋានៈ ដូចជាកូនបង្កើតនឹង B1 និង B2 ផង ។ ដូច្នេះ A នឹងមានទំនាក់ទំនងសន្តតិកម្ម និង អាហារកិច្ចទៅវិញទៅមក ជាមួយនឹង A1 និង A2 ផង និង B1 B2 ផង ។<br>ម្យ៉ាងទៀត តាមរយៈស្មុំកូននេះ ក្រៅពីទំនាក់ទំនងញាតិលោហិតនឹង A1 A2 កូនបង្កើត A ក៏មានទំនាក់ទំនងញាតិលោហិតនឹង B1 B2 ដែរ គឺ "B1 គឺជាឪពុករបស់ A" "B2 គឺជាម្តាយរបស់ A" "A គឺជាកូនបង្កើតរបស់ B1 B2 " ( មាត្រា ៩៤០) ។ ផ្ទុយទៅវិញ រវាង B1 B2 និង A1 A2 គ្មានទំនាក់ទំនងជាញាតិភាពទេ ( ការបកស្រាយផ្ទុយនឹងមាត្រា ៩៤០) ។ |

### ៣.២.២.២ អានុភាពនៃស្មុំកូនធម្មតា ដែលមានវិការៈ

ទោះបីជាមានវិការៈ ក្នុងការដាក់ពាក្យស្មុំកូនក៏ដោយ (ឧទាហរណ៍ មានការភាន់ច្រឡំ ជាដើម) បើសិនជាតុលាការ បានចេញដីកាសំរេចឱ្យបង្កើតស្មុំកូនធម្មតា ហើយ ដីកាសំរេចនោះ បានចូលជាស្ថាពរ អានុភាពនៃស្មុំកូន ត្រូវកើតមានឡើង ។

ក៏ប៉ុន្តែ បើសិនជាមាននីតិវិធីជំនុំជំរះសាជាថ្មី ហើយតុលាការ បានលុបចោលនូវដីកាសំរេចនោះ ដោយផ្អែកលើ (ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង មាត្រា ៤២, ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៣១៧ កថាខណ្ឌទី ១) ជាដើម អានុភាពនៃស្មុំកូននោះ ត្រូវរលត់ ។

### ៣.២.៣ ការលុបចោលស្មុំកូនធម្មតា

ស្មុំកូនធម្មតា នឹងត្រូវរលត់តាមរយៈការកាត់កាល់ ។

អាចមានករណីកាត់កាល់ តាមការព្រមព្រៀងរវាងភាគី ( មាត្រា ១០២៨) និង ការកាត់កាល់តាមផ្លូវតុលាការ តាមរយៈបណ្តឹង ( មាត្រា ១០៣១) ។

### ៣.២.៣.១ លក្ខខណ្ឌនៃការកាត់កាល់តាមការព្រមព្រៀង

ការកាត់កាល់តាមការព្រមព្រៀង គឺជាការកាត់កាល់ ដែលភាគីទាំងសងខាង ( ឪពុកម្តាយចិញ្ចឹម និង កូនសុំ) បានព្រមព្រៀង ហើយ បានដាក់ពាក្យសុំទៅតុលាការ ហើយ តុលាការ បានធ្វើការវិនិច្ឆ័យឱ្យកាត់កាល់ ( មាត្រា ១០៣០, ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណី មិនមែនជាបណ្តឹង មាត្រា ៣ កថាខណ្ឌទី ១ និង ទី ២ តារាងឧបសម្ព័ន្ធផ្នែកទី ៤ ចំណុចទី ៩ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង) ។

ក្នុងករណីដែលបានពិនិត្យទៅឃើញថា ភាគីទាំងសងខាង មានឆន្ទៈពិតប្រាកដចង់រំលាយចោលនូវទំនាក់ទំនងជាឪពុកម្តាយចិញ្ចឹម និង កូនសុំ តុលាការ ត្រូវសំរេចឱ្យកាត់កាល់ ។

### ៣.២.៣.២ លក្ខខណ្ឌនៃការកាត់កាល់តាមផ្លូវតុលាការ

ការកាត់កាល់តាមផ្លូវតុលាការ គឺជាការកាត់កាល់ ដែលពុំមានការព្រមព្រៀងរវាងភាគី ស្តីពីការកាត់កាល់ ហើយ ភាគីណាម្ខាង បានដាក់ពាក្យបណ្តឹងទាមទារឱ្យកាត់កាល់ភាគីម្ខាងទៀត ហើយ តុលាការ បានចេញសាលក្រមកាត់កាល់ ។

ការកាត់កាល់នេះ គឺជាការកាត់កាល់ដោយបង្ខំ ចំពោះភាគីម្ខាងទៀត ដែលគ្មានបំណងចង់កាត់កាល់ ដូច្នេះ ទាល់តែមានមូលហេតុធ្ងន់ធ្ងរ ទើបអាចទទួលស្គាល់បាន។ ក្រមរដ្ឋប្បវេណី មានចែងអំពីមូលហេតុនៃការកាត់កាល់នេះ នៅក្នុងមាត្រា ១០៣១ កថាខណ្ឌទី ១ ដូចតទៅ :

**ក.** ករណីដែលមានការបោះបង់ដោយទុច្ចរិត

**ខ.** ករណីដែលមិនដឹងថា នៅរស់ ឬ ទទួលមរណភាព ក្នុងអំឡុងពេលមួយឆ្នាំ ឡើងទៅ

**គ.** ករណី ដែលមានហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលធ្វើអោយពិបាកក្នុងការបន្តសុំកូន

ម្យ៉ាងទៀត បណ្តឹងទាមទារនូវការកាត់កាល់ គឺជាបណ្តឹងដែលត្រូវអនុវត្តតាមច្បាប់នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ( ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មាត្រា ៣ ចំណុច ឈ.) ហេតុនេះ ហើយ នីតិវិធីនៃបណ្តឹងនេះ មានភាពខុសគ្នាបន្តិចនឹងនីតិវិធីបណ្តឹងធម្មតា ដូចជា ការកែសំរួលនូវគោលការណ៍នៃការទាញហេតុផលដោយផ្ទាល់មាត់ ( ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់តុលាការ) ឬ ការទាញហេតុផលដោយផ្ទាល់មាត់ ដែលមិនធ្វើជាសាធារណៈ ជាដើម ។

### ៣.២.៣.៣ អានុភាពនៃការកាត់កាល់ ( មាត្រា ១០៣២)

ក្នុងករណីដែលបានកាត់កាល់ ដោយការព្រមព្រៀង ឬ បានកាត់កាល់តាមផ្លូវតុលាការ អានុភាពនៃសុំកូន ត្រូវបានបញ្ចប់ឆ្ពោះទៅអនាគត តាមរយៈការកាត់កាល់នេះ។

កូនសុំ អាចប្រើត្រកូលរបស់ខ្លួន ដែលមានមុនពេលសុំកូនក៏បាន ឬក៏ប្រើត្រកូលដែលមានក្រោយពេលសុំកូនក៏បាន។

## ៣.៣ សុំកូនពេញលេញ

សុំកូនពេញលេញ គឺជារបបសម្រាប់ផ្តល់នូវគ្រួសារសុខដុមរមនាមួយ ចំពោះកុមារអភ័ព្វ ក្នុងគោលបំណងចិញ្ចឹមកូននោះ ឱ្យមានសុខភាពល្អ ហើយដែលជារបបមួយ ប្រហាក់ប្រហែលនឹងឪពុកម្តាយបង្កើត ជាងសុំកូនធម្មតា។

### ៣.៣.១ លក្ខខណ្ឌដើម្បីសុំកូនពេញលេញ

សុំកូនពេញលេញ ត្រូវស្របនឹងលក្ខខណ្ឌទំរង់ (ដាក់ពាក្យសុំទៅតុលាការ ហើយ បានទទួលនូវដីកាសំរេចពីតុលាការ) ព្រមទាំងលក្ខខណ្ឌជាសារធាតុ (លក្ខខណ្ឌដែលចាំបាច់ដើម្បីឱ្យតុលាការចេញដីកាសំរេច) ដូចសុំកូនធម្មតាដែរ។

#### ៣.៣.១.១ លក្ខខណ្ឌទំរង់

បុគ្គល ដែលនឹងក្លាយទៅជាឪពុកម្តាយ ត្រូវដាក់ពាក្យសុំបង្កើតសុំកូនពេញលេញ ទៅតុលាការ (មាត្រា ១០០៧) ហើយ តុលាការ នឹងចេញដីកាសំរេចបង្កើតសុំកូននោះ (មាត្រា ១០១២, ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង មាត្រា ៣ កថាខណ្ឌទី ១, តារាងឧបសម្ព័ន្ធផ្នែកទី ៤ ចំណុចទី ៧ នៃច្បាប់ដដែរនេះ)។

#### ៣.៣.១.២ លក្ខខណ្ឌជាសារធាតុ

ដើម្បីសំរេចបង្កើតសុំកូន តុលាការ ត្រូវពិនិត្យមើលថាតើ ស្របនឹងលក្ខខណ្ឌខាងក្រោមនេះ ឬ ទេ។ នេះគឺខុសនឹងសុំកូនធម្មតា ដោយសារតែត្រូវផ្តាច់នូវទំនាក់ទំនងរវាងកូនបង្កើត និង ឪពុកម្តាយបង្កើត ជាអាទិ៍ ដែលជាអានុភាពមួយដ៏ធ្ងន់ធ្ងរ ម្ល៉ោះហើយ ចាំបាច់ត្រូវមានលក្ខខណ្ឌតឹងរឹងណាស់។

ក. សុំកូនដោយសហការរវាងប្តីប្រពន្ធ (មាត្រា ១០០៨)

ជាគោលការណ៍ បុគ្គលដែលនឹងក្លាយជាឪពុកឬម្តាយចិញ្ចឹម ត្រូវតែមានសហព័ទ្ធ ហើយ ប្តីប្រពន្ធ ត្រូវសហការគ្នា ដើម្បីក្លាយទៅជាឪពុកម្តាយចិញ្ចឹម ។

នេះ គឺដោយសារតែ របបសុំកូនពេញលេញនេះ មានគោលគំនិតផ្តល់នូវគ្រួសារមួយ ដែលមានឪម្តាយទាំងពីរ ហើយ មានស្នេហភាពដល់កុមារអភ័ព្វ ។

**ខ.** អាយុរបស់ឪពុកម្តាយចិញ្ចឹម និង កូនសុំ ( មាត្រា ១០០៩, មាត្រា ១០១០)

ឪពុកម្តាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ ឆ្នាំ ឡើងទៅ ហើយ ត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងតិច ២០ ឆ្នាំ ។

ជាគោលការណ៍ កូនសុំ ត្រូវមានអាយុតិចជាង ៨ ឆ្នាំ ។

នេះ គឺដើម្បីធ្វើអោយទំនាក់ទំនងដូចគ្នានឹងឪពុកម្តាយ និង កូនបង្កើត ម្ល៉ោះហើយបានជាតំរូវអោយមានគំលាតអាយុ ដូចឪពុកម្តាយ និង កូនបង្កើតដែរ ។ ម្យ៉ាងទៀត ទាល់តែកូនសុំនោះនៅតូច ទើបអាចបង្កើតជាទំនាក់ទំនងរវាងឪពុកម្តាយ និង កូនសុំ ដូចឪពុកម្តាយ និង កូនបង្កើតដែរ ។

**គ.** ការយល់ព្រមរបស់ឪពុកម្តាយ ( មាត្រា ១០១១)

ត្រូវមានការយល់ព្រមពីឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យាបាលសំរាប់អនីតិជនរបស់កុមារ ដែលនឹងក្លាយជាកូនសុំនោះ ។

នេះ គឺដោយសារតែបើសិន ជាបានបង្កើតសុំកូនពេញលេញទៅ ទំនាក់ទំនងរវាងឪពុកម្តាយ និង កូនបង្កើត ឬ ញាតិនោះ នឹងត្រូវរលត់ ។

**ឃ.** ភាពចាំបាច់នៃសុំកូន ( មាត្រា ១០១២)

សុំកូនពេញលេញ អាចបង្កើតឡើងបានទាល់តែជាករណីដែលមានការពិបាកយ៉ាងខ្លាំង ឬ មិនសមរម្យ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ដោយឪពុកម្តាយបង្កើត ឬ មានស្ថានភាពពិសេសផ្សេងៗ ទៀត ដែលចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កូននោះ ។

**ង.** អំឡុងពេលសាកល្បងចិញ្ចឹម ( មាត្រា ១០១៣)

ស្តីពីការសុំកូនពេលលេញ ត្រូវធ្វើការវិនិច្ឆ័យ យ៉ាងប្រុងប្រយ័ត្ន ហេតុនេះហើយ ជាគោលការណ៍ តុលាការត្រូវត្រួតពិនិត្យមើលបុគ្គល ដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម និង កូនសុំនោះ ក្នុងអំឡុងពេលយ៉ាងតិច ៦ ខែ ហើយ វិនិច្ឆ័យនូវការសុំកូននោះ ដោយពិចារណាដល់ស្ថានភាពនោះ ។

### ៣.៣.២ អានុភាពនៃសុំកូនពេញលេញ

#### ៣.៣.២.១ អានុភាពនៃសុំកូនពេញលេញ

ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើតនោះ ត្រូវបញ្ចប់ ដោយសុំកូនពេញលេញ ( មាត្រា ១០១៤) ។

រវាងកូនសុំពេញលេញ និង ឪពុកម្ដាយចិញ្ចឹម កូនសុំនេះ ត្រូវទទួលឋានៈដូចគ្នា ទៅនឹងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹមនោះដែរ ( មាត្រា ១០១៥) ។

ស្ដីពីត្រកូល កូនសុំ អាចប្រើនាមត្រកូលមុនសុំកូនក៏បាន នាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹមក៏បាន ។

កូនសុំ ត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម ។

ពេលណាបានបង្កើតសុំកូនពេញលេញហើយ ត្រូវចុះបញ្ជីកំណើតរបស់កូនសុំជាថ្មី ។ ក៏ប៉ុន្ដែ នៅក្នុងសំបុត្រកំណើត មិនត្រូវសរសេរចំណុចស្ដីពីសុំកូនទេ ( មាត្រា ១០១៨) ។

ក្នុងករណី ដែលកូនសុំពេញលេញ ដែលបានក្លាយជានីតិជន ចង់ដឹងអំពីកំណើតរបស់ខ្លួន កូននោះ អាចទាមទារឱ្យបង្ហាញព័ត៌មាននោះ តាមរយៈតុលាការបាន ( មាត្រា ១០១៩) ។ នៅក្នុងករណីនេះ ត្រូវធ្វើតាមច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីមិនមែនជាបណ្ដឹង (ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីមិនមែនជាបណ្ដឹង មាត្រា ៣ កថាខណ្ឌទី ១, តារាងឧបសម្ព័ន្ធផ្នែកទី ៤ ចំណុចទី ៨) ។

### ៣.៣.២.២ អានុភាពនៃសុំកូនពេញលេញ ដែលមានវិការៈ

ត្រូវគិតដូចគ្នានឹងសុំកូនធម្មតា ដែលមានវិការៈដែរ ។

### ៣.៣.៣ ការរំលាយសុំកូនពេញលេញ

ដោយសារតែសុំកូនពេញលេញ ជាការបង្កើតទំនាក់ទំនងឪពុកម្ដាយចិញ្ចឹម និង កូនតែមួយគត់ ដូចទំនាក់ទំនងឪពុកម្ដាយ និង កូនបង្កើតដែរ ហេតុនេះហើយ ជាគោលការណ៍ មិនអនុញ្ញាតឱ្យកាត់កាល់បានឡើយ ។ ក៏ប៉ុន្ដែផ្ទុយទៅវិញ មិនត្រូវទុកបន្តនូវសុំកូន រហូតដល់ពេលមានការខូចខាតផលប្រយោជន៍យ៉ាងធ្ងន់ធ្ងររបស់កូនសុំទេ ។ ដូច្នេះហើយ មានតែករណីដែលមានការធ្វើបាប ដោយឪពុកម្ដាយចិញ្ចឹម ជាអាទិ៍ ទើបមានការទទួលស្គាល់នូវការកាត់កាល់តាមរយៈបណ្ដឹង ( មាត្រា ១០១៦, ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណី ដែលមិនមែនជាបណ្ដឹង មាត្រា ៣ ចំណុច ជ) ។

ក្នុងករណីដែលមានការទទួលស្គាល់នូវការកាត់កាល់ ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើតនោះ ដែលត្រូវបានបញ្ចប់ដោយសុំកូនពេញលេញ ត្រូវកើតឡើងវិញ ( មាត្រា ១០១៧) ។

# ផ្នែកទី ៤

# ការលែងលះ

## ១. សេចក្តីផ្តើម

អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាពិសេសមួយ ដែលខុសពីកិច្ចសន្យាធម្មតា។ ចំពោះកិច្ចសន្យាធម្មតា អោយតែសំណើ និងស្ទីការត្រូវគ្នា គឺកិច្ចសន្យាត្រូវបានបង្កើតឡើង ថាតើធ្វើជាលាយលក្ខណ៍អក្សរ ឬមិនធ្វើជាលាយលក្ខណ៍អក្សរក៏ដោយ ក៏ប៉ុន្តែកិច្ចសន្យាក្នុងរឿងអាពាហ៍ពិពាហ៍ ត្រូវតែធ្វើឱ្យប្រិតប្រៀងបំផុត និងត្រូវគោរព តាមមាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី មានន័យថា កិច្ចសន្យាក្នុងរឿងអាពាហ៍ពិពាហ៍ មិនអាចធ្វើដោយផ្ទាល់មាត់បានទេ ថ្វីបើសំណើសុំរៀបអាពាហ៍ពិពាហ៍ ត្រូវគ្នាជាមួយនឹងស្ទីការរៀបអាពាហ៍ពិពាហ៍ក៏ដោយ។ ហើយបើ មិនគោរពតាមលក្ខខណ្ឌនៃមាត្រា ៩៥៥ ទេ កិច្ចសន្យាអាពាហ៍ពិពាហ៍ មិនត្រូវបានបង្កើតឡើយ។

ការលែងលះ គឺជាការរំលាយកិច្ចសន្យាអាពាហ៍ពិពាហ៍នេះ។

## ២. ការលែងលះ មានពីរប្រភេទ

### ២.១ ការលែងលះ ( ករណីមានការព្រមព្រៀង)

ប្រសិនបើគូភាគី (ប្តីប្រពន្ធ) ព្រមព្រៀងគ្នាថា ពួកគេ មិនអាចរួមរស់នៅជាមួយគ្នាតទៅទៀតបាន បញ្ញត្តិមាត្រា ៩៧៩ អនុញ្ញាតអោយភាគីអាចដាក់ពាក្យបណ្តឹងលែងលះទៅតុលាការបាន ហើយបើតុលាការ រកឃើញថា ភាគី មានឆន្ទៈព្រមព្រៀងគ្នាពិតប្រាកដ ក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ តុលាការ ត្រូវតែសំរេចឱ្យភាគីលែងលះគ្នាតាម**ដីកាសំរេចលែងលះ** (មាត្រា ៣-២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនបណ្តឹង)។ ការលែងលះ នាំឱ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងនូវទំនាក់ទំនងឋានៈបុគ្គល ដូចនេះទោះ ជាមានការព្រមព្រៀងគ្នារវាងភាគីក្នុងការលែងលះ ភាគី មិនអាចបង្កើតកិច្ចសន្យាលែងលះក្រៅផ្លូវតុលាការ ឬគ្រាន់តែប្រើវិធីដាក់លិខិតជូនដំណឹងទៅសាលាឃុំ-សង្កាត់បានទេ ចាំបាច់ត្រូវតែ មានសេចក្តីសំរេចរបស់តុលាការ ទើបការលែងលះ មានអានុភាពតាមផ្លូវច្បាប់ ។

### ២.២ ការលែងលះ ( ករណីគ្មានការព្រមព្រៀង)

#### ២.២.១ មូលហេតុនៃការលែងលះ

ប្រសិនបើភាគី មិនមានឆន្ទៈព្រមព្រៀងគ្នាលែងលះទេ នៅពេលដែល មានបណ្តឹងចូលមកតុលាការ តុលាការ ត្រូវតែស្វែងរកមូលហេតុ ដែលនាំឱ្យភាគីលែងលះតាមផ្លូវច្បាប់បាន។ មូលហេតុទាំងនោះ គឺមានកំណត់ នៅក្នុងមាត្រា ៩៧៨ :

**ក.** ករណីប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ទ្ធ : យុត្តិសាស្ត្រប្រទេសជប៉ុន បានឱ្យនិយមន័យ "អំពើផិតក្បត់" ថាគឺជាការមានចំណងផ្លូវភេទនឹងបុគ្គលផ្សេង ក្រៅពីសហព័ទ្ធ។ និយមន័យនៃយុត្តិសាស្ត្រប្រទេសជប៉ុននេះ គឺមានន័យដូចនិយមន័យនៃមាត្រា ៧ នៃច្បាប់ស្តីពីឯកពន្ធភាព នៅប្រទេសកម្ពុជាដែរ "អំពើផិតក្បត់" គឺជាការរួមសវនកិច្ចរវាងបុរស ដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬ ការរួមសវនកិច្ចរវាងស្ត្រី ដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្តីរបស់ខ្លួន។

**ខ.** ករណីមានការបោះបង់ចោលសហព័ទ្ធដោយគ្មានមូលហេតុត្រឹមត្រូវ

**គ.** ករណីមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬ រស់ អស់រយៈពេលជាង ០១ ឆ្នាំ

**ឃ.** ករណីសហព័ទ្ធ បានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ០១ ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ : ការរស់នៅឆ្ងាយដោយសារការងារ មិនចាត់ចូលនៅក្នុងករណីនេះទេ ។

**ង.** ករណីដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ ត្រូវបានបែកបាក់ ឬ ករណីផ្សេងទៀត ដែលគ្មានសង្ឃឹមថា នឹងអាចបដិទានឡើងវិញបាន : បញ្ញត្តិចំណុចនេះមានលក្ខណៈទូលាយ និយាយរួមទោះបីជាមូលហេតុទាំងឡាយ ដែលមិនចូលក្នុងចំណុចចាប់ពី "ក" ដល់ "ឃ" គឺ ស្ថានភាពនោះ អាចនឹងត្រូវបានគេរាប់បញ្ចូលទៅក្នុងចំណុច "ង" នេះ។ តុលាការ គប្បីត្រូវពិចារណាដល់ស្ថានភាពនានា ដូចជា សកម្មភាព និង អាកប្បកិរិយារបស់អ្នកទាំងពីរក្នុងអំឡុងអាពាហ៍ពិពាហ៍ (វាយដំ ធ្វើទុកបុកម្នេញ ប្រមាថមើលងាយធ្ងន់ធ្ងរចំពោះសហព័ទ្ធ ឬ ញាតិរបស់សហព័ទ្ធ, មានចរិយាផ្ទុយពីសីលធម៌ ឬ ប្រព្រឹត្តអនាចារ), ឆន្ទៈចង់បន្តចំណងអាពាហ៍ពិពាហ៍ឬទេ, ស្ថានភាពសុខភាព (អពលានុភាពនៃលិង្គ) ស្ថានភាពសេដ្ឋកិច្ច ជាអាទិ៍ ។

មានករណីជាច្រើន ដែលបានបំពេញលក្ខខណ្ឌពីចំណុច "ក" ដល់ "ឃ" ជាញឹកញាប់ក៏ត្រូវបានចាត់ចូលទៅក្នុងចំណុច "ង" ផងដែរ ហើយក៏អាចមានករណីជាច្រើន ដែលមិនស្របនឹងចំណុច "ក" ដល់ "ឃ" តែស្របនឹងចំណុច "ង"។

### ២.២.២ មូលហេតុរាំងការលែងលះ

ជាគោលការណ៍ អោយតែមានមូលហេតុ ដូចមានលើកឡើងខាងលើ ចាប់ពីចំណុច "ក" ដល់ "ង" នោះ ការលែងលះ ត្រូវបានទទួលស្គាល់។ ក៏ប៉ុន្តែ ការលែងលះនេះ អាចមានផលប៉ះពាល់ធ្ងន់ធ្ងរ ដល់សហព័ទ្ធ និង កូន ដូចនេះ ដើម្បីទប់ស្កាត់ការលែងលះតាមទំនើងចិត្ត ដែលជាផលប៉ះពាល់ធ្ងន់ធ្ងរដល់សហព័ទ្ធ និង កូន តុលាការ អាចច្រានចោលការលែងលះ ដោយផ្អែកលើមាត្រា ៩៧៨ កថាខណ្ឌទី ២ និង ទី ៣ នៃក្រមរដ្ឋប្បវេណី។ នៅត្រង់ចំណុចនេះ កត្តាផ្លូវចិត្ត កត្តាសង្គម កត្តាសេដ្ឋកិច្ច គឺត្រូវបានយកមកពិចារណាទាំងអស់ ហើយ អំឡុងពេលដែលរស់នៅបែកគ្នា ក៏ត្រូវយកមកពិចារណាផងដែរ។

**ករណីយុត្តិសាស្ត្ររបស់ប្រទេសជប៉ុន**

សាលដីកាតុលាការកំពូលប្រទេសជប៉ុន នៅថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ ១៩៩០ :

ប្តី មានអាយុ ៩២ ឆ្នាំ ប្រពន្ធអាយុ ៩៩ ឆ្នាំ កូនប្រុសច្បងអាយុ ២៩ ឆ្នាំ កូនប្រុសទី ២ អាយុ ២៤ ឆ្នាំ ក្រោយរៀបអាពាហ៍ពិពាហ៍ បាន ២៣ ឆ្នាំ ប្តី បានចេញពីផ្ទះទៅនៅជាមួយស្រីផ្សេង។ បន្ទាប់ពីនោះ ក៏បែកពីនារីនោះ តែមិនបានមករស់នៅជាមួយប្រពន្ធវិញទេ ហើយរយៈពេលដែលរស់នៅបែកគ្នានោះ គឺ ០៨ ឆ្នាំ។ ក្រោយពីបានរស់នៅបែកគ្នា ប្តី បានផ្ញើប្រាក់ផ្គត់ផ្គង់ជីវភាពប្រពន្ធ រហូតមក ហើយចំនួនប្រាក់នោះ មានច្រើនគួរសមដែរ។ ប្តី បានដាក់ពាក្យបណ្តឹងសុំលែងលះគ្នា រីឯកូន យល់ឃើញថា ចង់លែងលះ ឬ ទេនោះ គឺជាឆន្ទៈរបស់ម្តាយគេ។ ម្យ៉ាងទៀត ប្តី បានបង្ហាញឆន្ទៈថា ស្តីពីការបែកចែកទ្រព្យសម្បត្តិ ពេលលែងលះគ្នា ត្រូវលក់ផ្ទះ និង ដី ដែលប្រពន្ធ កំពុងរស់នៅ ហើយដែលជាកម្មសិទ្ធិរបស់ប្តីនោះ ហើយទូទាត់នៅពន្ធដា ព្រមទាំងចំណាយផ្សេង ៗ លើការលក់ នៅសល់ប៉ុន្មានចែកជាពីរ ខាងប្តីយកពាក់កណ្តាល ខាងប្រពន្ធយកពាក់កណ្តាល។ រីឯ បំណុលនៅសល់ ហើយជាប់ហ៊ីប៉ូតែកលើអចលនវត្ថុនោះ ខាងប្តីជាអ្នករ៉ាប់រង ហើយគាត់ នឹងទូទាត់ពីប្រាក់ ដែលគាត់បានទទួលពីការបែងចែកនោះ ។

**"សេចក្តីសម្រេចបញ្ចប់"**

សាលដីកាដើម បានច្រានចោលនូវការទាមទារ។ តុលាការកំពូល បានបដិសេធចោលនូវសាលដីកាដើម ហើយ បញ្ជូនត្រឡប់ទៅវិញ ។

...........ក្នុងការវិនិច្ឆ័យអំពីការលែងលះគ្នា ត្រូវពិចារណាដល់អាយុរបស់ប្តីប្រពន្ធ ដោយ ប្រៀបធៀបអំឡុងពេលដែលរស់នៅបែកគ្នា និង អំឡុងពេលដែលរស់នៅជាមួយគ្នាដើម្បីមើលថា តើអំឡុងពេលដែលរស់នៅបែកគ្នា នោះវែងគួរសម ឬ ទេ។ តាមគោលគំនិតនេះ គឺត្រូវពិចារណាដល់ការប្រែប្រួល ស្ថានភាពផ្សេង១ រួមទាំងអត្ថន័យ និងការវាយតម្លៃក្នុងសង្គម (សង្គមអាចទទួលបាន ឬ ទេ) ក្រោយការរស់នៅបែកគ្នាផងដែរ។ ហើយពេល ធ្វើការវិនិច្ឆ័យ អំពីការទាមទារសុំលែងលះគ្នា ដោយពិចារណាអំពីគោលការណ៍សុចរិត និង ស្មោះត្រង់ ក៏ត្រូវពិចារណាអំពីឥទ្ធិពលនៃបញ្ហានានា ដែលកើតមានឡើង ក្នុងអំឡុងពេលកន្លងមកនោះដែរ ។

............ហេតុនេះហើយពេលពិចារណាថា តើអំឡុងពេលដែលរស់នៅបែកគ្នានោះ វែង ឬ ខ្លី មិនមែនគ្រាន់តែប្រៀបធៀបនឹងរយៈពេល ឬអាយុប៉ុណ្ណោះទេ គឺត្រូវពិចារណា ដល់ការប្រែប្រួលនៃស្ថានភាពទាំងនេះផងដែរ

...............អំឡុងពេលដែលរស់នៅបែកគ្នារវាងដើមបណ្តឹងសារទុក្ខ និង ចុងចម្លើយបណ្តឹងសារទុក្ខ មាន ០៨ ឆ្នាំ ហើយ ក្រោយពេលរស់នៅបែកគ្នា ប្តី បានផ្ញើប្រាក់ទៅអោយប្រពន្ធសំរាប់ផ្គត់ផ្គង់ជីវភាពរស់នៅគួរសមដែរ ម្យ៉ាងទៀត ប្តី បានផ្តាច់ទំនាក់ទំនងនឹងស្ត្រីនោះ ក្រោយពីបានរស់នៅបែកគ្នា។ លើសពីនេះ ក្នុងការទាមទារសុំលែងលះគ្នានេះ ដើមបណ្តឹង បានបង្ហាញឆន្ទៈទូទាត់ទ្រព្យទៅអោយ ចុងចម្លើយបណ្តឹងសារទុក្ខ ដែលអាចទទួលស្គាល់ថាសមរម្យបាន។ រីឯចុងចម្លើយនៃបណ្តឹងសារទុក្ខវិញ ចង់បន្តទំនាក់ទំនងអាពាហ៍ពិពាហ៍ ក៏ប៉ុន្តែក្រោយពី រស់នៅបែកគ្នាប្រហែល ៥ ឆ្នាំ គាត់ បានដាក់ពាក្យបណ្តឹងសុំនូវការចាត់ចែងជាបណ្តោះអាសន្ន មិនឱ្យចាត់ចែងអចលនវត្ថុ ដែល

ជាកម្មសិទ្ធិរបស់ដើមបណ្ដឹងសាទុក្ខ។ ក្រៅពីនេះ កូនដែលមានវ័យជានីតិជនហើយនោះ មានឆន្ទៈថា ការលែងលះ ឬ មិនលែងលះនោះ សំខាន់គឺឆន្ទៈរបស់ចុងចម្លើយនៃបណ្ដឹងសាទុក្ខ។ ហេតុនេះហើយ បើសិនជាពុំមានបញ្ហាអ្វីពិសេសទៀតទេ អំឡុងពេលនៃការរស់នៅបែកគ្នា និង ការប្រែប្រួលនៃស្ថានភាពផ្សេងៗ របស់ភាគី ទាំងសងខាង គប្បីពិចារណាដល់ការប្រែប្រួលនៃការវាយតម្លៃរបស់សង្គមផងដែរ ។

### ២.២.៣ ការបែងចែកទ្រព្យសម្បត្តិ

#### ២.២.៣.១ តួនាទីនៅក្នុងបណ្ដឹងសុំលែងលះ

នៅក្នុងរឿងលែងលះ ភាគច្រើនតែងមានបណ្ដឹងសុំបែងចែកទ្រព្យសម្បត្តិជាមួយនឹងបណ្ដឹងសុំលែងលះផងដែរ ( មាត្រា៩៨០នៃក្រមរដ្ឋប្បវេណី) ។ ក្នុងករណីនេះ តុលាការត្រូវសម្រេចពីការបែងចែកទ្រព្យឱ្យភាគី ប៉ុន្តែត្រូវពិនិត្យឱ្យបានច្បាស់ថា ភាគីបានដាក់ពាក្យសុំបែងចែកទ្រព្យដែរឬទេ ពីព្រោះបើគ្មានពាក្យសុំ តុលាការមិនអាចវិនិច្ឆ័យអំពីការបែងចែកទ្រព្យបានឡើយ។ មានករណីខ្លះ គូភាគីប្ដឹងសុំបែងចែកទ្រព្យក្រោយពេលលែងលះ ហើយអនុវត្តនីតិវិធីនៃរឿងក្ដីមិនមែនជាបណ្ដឹង។

នៅក្នុងសាលក្រម តុលាការអាចបង្គាប់ឱ្យផ្ដល់តាវកាលិកជាប្រាក់ ការបណ្ដេញចេញហើយឱ្យប្រគល់អចលនវត្ថុ ការចុះបញ្ជីផ្ទេរកម្មសិទ្ធិ ជាដើម។

#### ២.២.៣.២ គោលការណ៍សមាមាត្រនៃចំណែក និង ករណីពិសេស

ការបែងចែកទ្រព្យនៅពេលមានបណ្ដឹងសុំលែងលះ ត្រូវផ្អែកលើមាត្រា ៩៨០ ។ គេហកិច្ច ត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ ។

មាត្រានេះ បានបង្ហាញឱ្យអនុវត្តតាមវិធីដូចខាងក្រោម :

១. ការបែងចែកទ្រព្យសម្បត្តិ ដោយផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង ។

២. ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្ដីប្រពន្ធបានទេ ត្រូវបែងចែកទ្រព្យសម្បត្តិ ដូចខាងក្រោម :

- សហព័ទ្ធនីមួយៗ ត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន ដូចបានកំណត់នៅក្នុងមាត្រា ៩៧២។

- ជាគោលការណ៍ ទ្រព្យសម្បត្តិរួម ត្រូវបែងចែកជាពីរចំណែកស្មើគ្នា ។

- ក្នុងករណីពិសេស និង មានការទាមទាររបស់ប្ដី ឬ ប្រពន្ធណាមួយ តុលាការ ក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗ ដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅ នៅក្នុងពេលមាន

ចំណេងអាពាហពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្តនិងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និង ផលប្រយោជន៍របស់កូន ជាអាទិ៍ ។

### ២.២.៣.៣ វិធីបែងចែក

ដើម្បីឱ្យសាលក្រម អាចយកទៅអនុវត្តបាន តុលាការ ត្រូវកំណត់វិធីបែងចែកឱ្យបានច្បាស់ នៅក្នុងសេចក្តីសម្រេច ។ មានវិធី ៣ យ៉ាង :

១. ការបែងចែកវត្ថុជាក់ស្តែង : ជាវិធីយកទ្រព្យមកបែងចែក តាមការជាក់ស្តែង

២. ការបែងចែកជាតម្លៃថ្នូរ : ជាវិធីបែងចែកដោយប្រគល់វត្ថុឱ្យភាគីម្ខាងគ្រប់គ្រង ហើយឱ្យអ្នកដែលទទួលលទ្ធកម្មនោះ បង់ជាតម្លៃថ្នូរដែលស្មើនឹងចំណែករបស់ភាគីម្ខាងទៀត ។

៣. ការបែងចែកដោយប្តូរជាប្រាក់ : ជាវិធីបែងចែកប្រាក់ ដែលបានមកពីការលក់ដោយបង្ខំ

### ២.២.៣.៤ ទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយ ដែលប្តីប្រពន្ធទាំងសង ឬ តែម្ខាង ទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិ ដែលបានកំណត់ក្នុងចំណុច **ខ** និង **គ** នៃមាត្រា ៩៧២ ( ទ្រព្យសម្បត្តិដោយឡែក) ។

### ២.២.៤ អំពីអំណាចមេបាលើកូន

សហព័ទ្ធដែលមានកូនជាអនីតិជន មានអំណាចមេបាទៅលើកូននោះ និង ប្រើប្រាស់អំណាចនេះ ដោយសហការគ្នា ( មាត្រា ១០៣៦) ។ អ្នកដែលមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ចត្រូវបីបាច់រក្សារូបកាយរបស់កូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ ( មាត្រា ១០៣៤) ។

នៅពេលដែលមានការលែងលះគ្នា ឪពុកម្តាយដែលលែងលះគ្នា ត្រូវកំណត់យកឪពុក ឬ ម្តាយណាម្ខាង ជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយ ( មាត្រា ១០៣៧ កថាខណ្ឌទី១) ។

ក្នុងករណីដែលឪពុកម្តាយ បានលែងលះគ្នានៅមុនកំណើតរបស់កូន ម្តាយ គឺជាអ្នកមានអំណាចមេបាចំពោះកូនដែលបានកើតមកនោះ ។ ប៉ុន្តែក្រោយកំណើតរបស់កូន អាចកំណត់យកឪពុកជាអ្នកមានអំណាច មេបាតាមការពិភាក្សារបស់ឪពុកម្តាយបាន ( មាត្រា ១០៣៧ កថាខណ្ឌទី២) ។

ប្រសិនបើភាគី មិនអាចពិភាក្សាអំពីការប្រគល់អំណាចមេបាលើកូនបានទេ ហើយមានការទាមទារធ្វើជាអ្នកមានអំណាចមេបារៀងៗ ខ្លួន នោះ តុលាការ ត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅលើផលប្រយោជន៍របស់កូននោះ ( មាត្រា ១០៣៧ កថាខណ្ឌទី៣) ។

ក្នុងករណីដែលការសម្រេចអំពីអ្នកមានអំណាចមេបា នៅពេលលែងលះគ្នារួចហើយ តុលាការ អាចផ្លាស់ប្តូរអ្នកដែលមានអំណាចមេបាតាមការទាមទាររបស់ញាតិនៅក្នុងបួនថ្នាក់របស់កូនបាន ប្រសិនបើ ទទួលស្គាល់ថាចាំបាច់ដើម្បីផលប្រយោជន៍របស់កូន ( មាត្រា ១០៣៩) ។

ឪពុក ឬ ម្តាយដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន និង មានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយ ដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ( មាត្រា ១០៤០ កថាខណ្ឌទី១) ។

ឪពុក ឬ ម្តាយដែលពុំមានអំណាចមេបាលើកូន អាចទាមទារឱ្យអ្នកដែលមានអំណាចមេបា រាយការណ៍អំពីស្ថានភាពរបស់កូននោះបាន។ ចំពោះខ្លឹមសារ និង របៀបរបបនៃការរាយការណ៍ ត្រូវកំណត់តាមការពិភាក្សារវាងឪពុកម្តាយ ប៉ុន្តែបើការពិភាក្សាមិនបានសម្រេចទេ ឬ ពុំអាចធ្វើការពិភាក្សាបានទេ តុលាការ អាចសម្រេចសេចក្តីជំនួសការពិភាក្សាតាមការទាមទាររបស់ឪពុក ឬ ម្តាយបាន។ ញាតិបួនថ្នាក់របស់កូន អាចទាមទារអោយរាយការណ៍អំពីស្ថានភាពរបស់កូន ចំពោះអ្នកមានអំណាចមេបាបាន ( មាត្រា ១០៤១) ។

អ្នកមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ចអប់រំកូន ( មាត្រា ១០៤៣) ។

អ្នកមានអំណាចមេបា អាចដាក់ទណ្ឌកម្មកូនដោយខ្លួនឯង នៅក្នុងទំហំដែលចាំបាច់បាន ( មាត្រា ១០៤៥) ។

ឪពុក ឬ ម្តាយដែលអនុវត្តអំណាចមេបា បានបំពានសិទ្ធិអំណាចក្នុងនាមជាអ្នកមានអំណាចមេបា ឬ បើបានធ្វេសប្រហែសក្នុងការបំពេញករណីយកិច្ចក្នុងនាមជាអ្នកមានអំណាចមេបា តុលាការ អាចប្រកាសព្យួរ ឬ ដកហូតអំណាចមេបាតាមការទាមទាររបស់ញាតិបួនថ្នាក់របស់កូន មេឃុំ ចៅសង្កាត់ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខមាលភាពកុមារ ឬ តំណាងអយ្យការបាន ( មាត្រា ១០៤៨) ។

ប្រសិនបើការលុបចោលនូវការប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបាបានបញ្ចប់ហើយ តុលាការ អាចលុបចោលការប្រកាសការព្យួរ ឬ ការដកហូតសិទ្ធិអំណាចក្នុងនាមជាអ្នកមានអំណាចមេបា តាមការទាមទាររបស់សាម៉ីជន ដែលបានទទួលការប្រកាសព្យួរ ឬ ការដកហូតអំណាចមេបា ឬ ញាតិក្នុងបួនថ្នាក់របស់ជននោះបាន ( មាត្រា ១០៤៩) ។

បើមានមូលហេតុដែលមិនអាចជៀសវាងបាន ឪពុក ឬ ម្តាយដែលអនុវត្តអំណាចមេបា អាចលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបាបាន ដោយទទួលការអនុញ្ញាតពីតុលាការ។ ប៉ុន្តែបើមូលហេតុ ដែលបានកំណត់ខាងលើត្រូវបានបញ្ចប់ហើយ ឪពុក ឬ ម្តាយ ដែលបានលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា អាចទទួលបដិទាននូវអំណាចមេបានោះវិញបាន ដោយទទួលការអនុញ្ញាតពីតុលាការ ( មាត្រា ១០៥០) ។

ក្នុងករណីដែលឪពុកម្តាយតែម្ខាង ជាអ្នកមានអំណាចមេបា ហើយកូនបានធ្លាក់ទៅក្នុងស្ថានភាពដែលពុំមានអ្នកមានអំណាចមេបាដោយសារអ្នកនោះ ត្រូវបានប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា ឬ បានលា

ឈប់ពីការធ្វើជាអ្នកមានអំណាចមេបា តុលាការ អាចយកឪពុក ឬ ម្ដាយដែលពុំមានអំណាចមេបាមកធ្វើជាអ្នកមានអំណាចមេបារបស់កូនបាន។ ក្នុងករណីចាំបាច់ញាតិក្នុងបួនថ្នាក់របស់កូន អាចទាមទារឱ្យធ្វើការប្រកាសដូចខាងលើបាន។ នៅពេលលែងលះគ្នា ប្រសិនបើឪពុក ឬ ម្ដាយដែលធ្វើជាអ្នកមានអំណាចមេបារបស់កូនតាមការពិភាក្សា បានទទួលមរណភាព ប្រសិនបើកូន ពុំមានអ្នកមានអំណាចមេបាទេ ឪពុក ឬ ម្ដាយ ដែលពុំបានធ្វើជាអ្នកមានអំណាចមេបា ត្រូវក្លាយជាអ្នកមានអំណាចមេបា ( មាត្រា ១០៥១) ។

## ៣. ការទទួលខុសត្រូវចំណាយក្នុងពេលអាពាហ៍ពិពាហ៍

### ៣.១ អ្វីទៅជាការទទួលខុសត្រូវចំណាយក្នុងពេលអាពាហ៍ពិពាហ៍ ?

ប្ដីប្រពន្ធ ត្រូវមានចំណែកបន្ទុកលើសោហ៊ុយ ដែលកើតចេញពីអាពាហ៍ពិពាហ៍ ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និងស្ថានភាពផ្សេងៗទៀត ( មាត្រា ៩៧១) ។ វា មានន័យថាប្ដីប្រពន្ធ ត្រូវមានករណីយកិច្ចទទួលខុសត្រូវនូវសោហ៊ុយចំណាយ ដើម្បីថែទាំជីវភាពរួមនៃអាពាហ៍ពិពាហ៍ ដោយតម្រូវឱ្យប្ដីប្រពន្ធចែករំលែកនូវការទទួលខុសត្រូវសោហ៊ុយជីវភាពរួមនៃអាពាហ៍ពិពាហ៍ ទៅតាមទ្រព្យសម្បត្តិ ប្រាក់ចំណូល ឋានៈក្នុងសង្គម និងមុខរបររបស់ប្ដីប្រពន្ធជាដើម។ ការទទួលខុសត្រូវនូវសោហ៊ុយ ចំណាយដើម្បីថែទាំជីវភាពរួមនៃអាពាហ៍ពិពាហ៍ មិនសំដៅលើត្រឹមតែការចំណាយសម្រាប់សំលៀកបំពាក់ ម្ហូបអាហារ ការស្នាក់នៅ ថ្លៃព្យាបាលប៉ុណ្ណោះទេ គឺរាប់បញ្ចូលទាំងការចំណាយលើការសិក្សា និង ថែទាំកូនផងដែរ ។ មិនតែប៉ុណ្ណោះ ក្រោយពេលប្ដីប្រពន្ធ រស់នៅបែកគ្នាក៏ដោយ ក៏ប្ដីប្រពន្ធ ត្រូវតែបន្តនូវករណីកិច្ចទទួលបន្ទុកនូវចំណែកនេះផងដែរ ប្រសិនបើពួកគេ មិនទាន់លែងលះនឹងគ្នា។ ទោះជា ប្ដីប្រពន្ធ រស់នៅបែកគ្នាក៏ដោយ ក៏ប្ដីប្រពន្ធ ត្រូវមានអាហារកាតព្វកិច្ចរវាងសហព័ទ្ធដែរ។ មានន័យថា សហព័ទ្ធម្ខាង អាចទាមទារ រួមទាំងសោហ៊ុយសម្រាប់ជីវភាពរស់នៅរបស់កូនដែលរស់នៅជាមួយខ្លួន ពីសហព័ទ្ធម្ខាងទៀតបានដែរ ។

ក្នុងករណីដែលសហព័ទ្ធណាមួយ មិនអនុវត្តកាតព្វកិច្ចនៃសោហ៊ុយចំណាយក្នុងពេលអាពាពិពាហ៍ សហព័ទ្ធម្ខាងទៀត អាចដាក់ពាក្យសុំទៅតុលាការឱ្យសម្រេចអំពីសោហ៊ុយចំណាយនេះបាន ក្នុងនីតិវិធីរឿងក្ដីដែលមិនមែនជាបណ្ដឹង ។

### ៣.២ ទំនាក់ទំនងរវាងការទទួលខុសត្រូវសោហ៊ុយចំណាយក្នុងពេលអាពាហ៍ពិពាហ៍និងរឿងក្ដីសុំលែងលះ

សហព័ទ្ធ ត្រូវបន្តនូវករណីកិច្ចទទួលបន្ទុកនូវចំណែកបន្ទុកនៃសោហ៊ុយចំណាយ ក្នុងពេលអាពាហ៍ពិពាហ៍ រហូតដល់ពេលដែល ប្ដីប្រពន្ធ បានលែងលះគ្នាដាច់ស្រេច មិនថាឡើយសូម្បីតែនីតិវិធីលែងលះ កំពុងតែអនុវត្ត។ នៅក្នុងករណីដែលតុលាការ ច្រានចោលនូវការទាមទារលែងលះរបស់សហព័ទ្ធ នោះបន្ទុកនៃការទទួលខុសត្រូវសោហ៊ុយចំណាយក្នុងពេលអាពាហ៍ពិពាហ៍ នៅតែបន្តដដែលសម្រាប់សហព័ទ្ធ ។

នៅពេលដែលការសុំលែងលះ បានសម្រេចរួចរាល់ហើយ ករណីយកិច្ចទទួលខុសត្រូវនូវចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ ក៏ត្រូវអស់ពីពេលនោះដែរ ប៉ុន្តែ មាត្រា ៧៦ (អាហារកិច្ចនៅក្រោយការលែងលះ) នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ គឺត្រូវបានរក្សាទុក ទោះជានៅក្រោយក្រមរដ្ឋប្បវេណីថ្មី ត្រូវបានអនុវត្ត ដោយផ្អែកទៅលើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។

## ៣.៣ វិធីគណនាទឹកប្រាក់នៃការទទួលខុសត្រូវចំណាយក្នុងពេលអាពាហ៍ពិពាហ៍

វិធីគណនាទឹកប្រាក់នៃការទទួលខុសត្រូវចំណាយក្នុងពេលអាពាហ៍ពិពាហ៍មានបីវិធីដូចខាងក្រោម :

**ក.** ត្រូវគណនាទៅតាមចំណូលមូលដ្ឋាន (x) របស់អ្នកមានសិទ្ធិ (ច្រើនតែប្រពន្ធ) និងចំណូលមូលដ្ឋាន (Y) របស់អ្នកមានករណីកិច្ច (ច្រើនតែប្តី)។

**ខ.** ត្រូវគណនាសោហ៊ុយអាពាហ៍ពិពាហ៍ (Z) ដែលត្រូវចែកទៅឱ្យខាងគ្រួសារអ្នកមានសិទ្ធ ។

$$Z=(X+Y)\times\frac{\text{សូចនាយករណ៍នៃសោហ៊ុយសម្រាប់ជីវភាពគ្រួសារអ្នកមានសិទ្ធិ (អ្នកមានករណីកិច្ច គឺជាអ្នកមានបន្ទុកលើអាហារកាតព្វកិច្ច)}}{\text{សូចនាយករណ៍នៃសោហ៊ុយសម្រាប់ជីវភាពទាំងសងខាង (អ្នកមានករណីយកិច្ច គឺជាអ្នកមានបន្ទុកលើអាហារកាតព្វកិច្ច)}}$$

**គ.** ត្រូវគណនាទឹកប្រាក់ ដែលអ្នកមានករណីយកិច្ចត្រូវទទួលបន្ទុក (ទឹកប្រាក់នៃចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍) ពីទឹកប្រាក់ដែលបានគណនានៅចំណុច "ខ"

ទឹកប្រាក់នៃចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ = Z - Y

# ៤. ទំនាក់ទំនងដោយគ្មានខាន់ស្លា

## ៤.១ អ្វីទៅគឺជា ទំនាក់ទំនងដោយគ្មានខាន់ស្លា ?

ទំនាក់ទំនងដែលគ្មានខាន់ស្លា គឺជាស្ថានភាពដែលមានការរស់នៅជាមួយគ្នាជាប្តីប្រពន្ធជាសារធាតុនៅក្នុងសង្គម ក៏ប៉ុន្តែ ទំនាក់ទំនងនេះ មិនបានបង្កើតជាទំនាក់ទំនងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ទេ ដោយសារតែមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ជាអាទិ៍ (មាត្រា ៩៥៥)។

## ៤.២ ទំហំនៃការអនុវត្តបញ្ញត្តិស្តីពីអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់

ចំពោះបុរសនិងស្ត្រីដែលមានទំនាក់ទំនងដោយគ្មានខាន់ស្លា តើត្រូវអនុវត្តបញ្ញត្តិច្បាប់ស្តីពីអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ (បញ្ញត្តិស្តីពីការសុំលែងលះ) ត្រឹមកម្រិតណា គឺជាបញ្ហាបកស្រាយ។ ខាងក្រោមនេះ គឺជាការបកស្រាយជាទូទៅ នៅប្រទេសជប៉ុន។ ចំពោះការអនុវត្តនៅកម្ពុជា គឺជាបញ្ហាដែលត្រូវធ្វើការពិចារណា និងបកស្រាយ ដោយផ្អែកលើទំនៀមទម្លាប់ ឬ ស្ថានភាពនានា នៅក្នុងសង្គម។

ក. ការលុបចោលនូវទំនាក់ទំនងដោយគ្មានខាន់ស្លា

តុលាការជប៉ុន មិនធ្វើអន្តរាគមន៍ទេ។ ទោះជាមានពាក្យបណ្តឹងទាមទារសុំលែងលះគ្នា លើករណីដែលជាទំនាក់ទំនងដោយគ្មានខាន់ស្លាក៏ដោយ ក៏តុលាការ លើកបណ្តឹងនោះចោល ដោយមូលហេតុគ្មានផលប្រយោជន៍ក្នុងការធ្វើបណ្តឹងដែរ។

ក៏ប៉ុន្តែ នៅកម្ពុជា មានគ្រួសារជាច្រើនដែលមានទំនាក់ទំនងដោយគ្មានខាន់ស្លា ហេតុនេះហើយ អាចមានការបកស្រាយ និងអនុវត្តផ្សេងពីជប៉ុន។

ខ. ការទាមទារជម្ងឺចិត្ត

នៅជប៉ុន គេបកស្រាយថា រវាងបុរស និង ស្ត្រីដែលមានទំនាក់ទំនងដោយគ្មានខាន់ស្លានោះ ត្រូវមានករណីយកិច្ចរួមរស់នឹងគ្នា សហការ និង សង្គ្រោះគ្នាទៅវិញទៅមក (មាត្រា ៩៦៦) ឬ ករណីយកិច្ចរក្សានូវសេចក្តីបរិសុទ្ធដែរ។ ហេតុនេះហើយ បើសិនជាមានការប្រព្រឹត្តផ្ទុយនឹងករណីយកិច្ចនេះ បុរស ឬ ស្ត្រី ដែលមានទំនាក់ទំនងដោយគ្មានខាន់ស្លា អាចទាមទារនូវជម្ងឺចិត្ត ដោយផ្អែកលើអំពើអនីត្យានុកូលបាន។

គ. ករណីយកិច្ចទទួលបន្ទុកនូវចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍

គេបកស្រាយថា ត្រូវអនុវត្តដូចគ្នានឹងចំណុច (b) ដែរ។ ដូចដែលមានសរសេរក្នុងចំណុច (a) ដែរ តុលាការមិនធ្វើអន្តរាគមន៍ចំពោះបញ្ហារំលាយទំនាក់ទំនងដោយគ្មានខាន់ស្លាទេ ហេតុនេះហើយ ថាតើត្រូវចាត់ទុកពេលវេលាណាមួយ ជាពេលដែលបានរំលាយទំនាក់ទំនងនេះ (=ពេលចប់ករណីយកិច្ចទទួលបន្ទុកនូវចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍) គឺជាបញ្ហាវាយតម្លៃទៅលើអង្គហេតុដែលមានជាក់លាក់នោះ។

ឃ. ទំនាក់ទំនងឪពុក និង កូន, សិទ្ធិអំណាចមេបា

ទោះជា មានទំនាក់ទំនងដោយគ្មានខាន់ស្លាក៏ដោយ ក៏មិនអាចអនុវត្តបញ្ញត្តិស្តីពី ការសន្មតបិតុភាព (មាត្រា ៩៨៨) ដែរ ដូច្នេះដើម្បីបង្កើតទំនាក់ទំនងបិតុភាពបាន ទាល់តែមានការទទួលស្គាល់ (ពីមាត្រា ៩៩៣ ទៅ)។

បន្ទាប់មក ស្តីពីសិទ្ធិអំណាចមេបាវិញ ទោះជាមានការទទួលស្គាល់ក៏ដោយ ក៏មិនអាចអនុវត្តបញ្ញត្តិស្តីពីសហការក្នុងការប្រើអំណាចមេបា (មាត្រា ១០៣៦) បានឡើយ គឺត្រូវអនុវត្តបញ្ញត្តិស្តីពី អំណាចមេបារវាងឪពុកម្តាយដែលមិនទាន់បានរៀបអាពាហ៍ពិពាហ៍ (មាត្រា ១០៣៨)។

ទោះជាក្រោយពេលដែលទំនាក់ទំនងដោយគ្មានខាន់ស្លា ត្រូវបានរលាយក៏ដោយ ក៏អ្នកដែលមានអំណាចមេបាពេលមានទំនាក់ទំនងដោយគ្មានខាន់ស្លា នៅតែមានសិទ្ធិអំណាចមេបាដដែល។ ក៏ប៉ុន្តែ វា អាចមានករណីដែលត្រូវផ្លាស់ប្តូរអ្នកមានអំណាចមេបា នៅពេលនោះក៏មានដែរ (មាត្រា ១០៣៩)។ ឧទាហរណ៍ នៅពេល ដែលមានទំនាក់ទំនងដោយគ្មានខាន់ស្លា ឪពុកជាអ្នកមានអំណាចមេបា តែក្រោយពីបានរំលាយទំនាក់ទំនងដោយគ្មាន

ខាន់ស្លា ម្តាយជាអ្នក យកកូនទៅចិញ្ចឹម ដូច្នេះហើយ អាចមានការដាក់ពាក្យទៅតុលាការសុំឱ្យប្តូរអ្នកមានអំណាចមេបាពីម្តាយ ។

**ង.** ការប្រាស្រ័យទាក់ទង. សោហ៊ុយដើម្បីគ្រប់គ្រងថែរក្សាកូន

បើសិនជាមានការទទួលស្គាល់ដោយឪពុក អាចអនុវត្តតាមបញ្ញត្តិនៃមាត្រា ១០៤០ កថាខ័ណ្ឌទី៣ ដល់ទី៧ បាន ។

**ច.** ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ និង ការបែងចែកទ្រព្យសម្បត្តិ

នៅជប៉ុន គេ បកស្រាយថា ត្រូវអនុវត្តនូវបញ្ញត្តិស្តីពី ការបែងចែកទ្រព្យសម្បត្តិ ចំពោះប្តីប្រពន្ធគ្មានខាន់ស្លា ដែរ ។

ក្នុងករណីរបស់កម្ពុជា បញ្ញត្តិស្តីពីការបែងចែកទ្រព្យសម្បត្តិ និងស្តីពីទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ មានទំនាក់ទំនងគ្នាទៅវិញទៅមក (មាត្រា ៩៨០) ហេតុនេះហើយ បើសិនជាមានការបកស្រាយថា ត្រូវអនុវត្តបញ្ញត្តិស្តីពីការបែងចែកទ្រព្យសម្បត្តិ ចំពោះប្តីប្រពន្ធគ្មានខាន់ស្លា គឺត្រូវអនុវត្តបញ្ញត្តិច្បាប់ស្តីពីទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធដែរ ។

ក៏ប៉ុន្តែ គប្បីតែពិចារណាថា ត្រូវអនុវត្តមាត្រាណាខ្លះឱ្យបានលំអិត ដូចជាបញ្ញត្តិស្តីពីការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ (មាត្រា ៩៧៦) ជាដើម ។

**ឆ.** ស្តីពីសន្តតិកម្ម

គេបកស្រាយថា សហព័ទ្ធម្ខាងនៃប្តីប្រពន្ធគ្មានខាន់ស្លា ពុំមានសិទ្ធិសន្តតិកម្ម នៅពេលដែលសហព័ទ្ធម្ខាងទៀត ទទួលមរណភាពឡើយ ។

បើសិនជាឈរលើការបកស្រាយខាងលើនេះ ពេលដែលប្តីគ្មានខាន់ស្លា បានទទួលមរណភាព ហើយប្រសិនបើ ប្តីនោះ ពុំបានទទួលស្គាល់កូនដែលជាញាតិលោហិតទេ ទាំងប្រពន្ធ និង កូន ពុំមានសិទ្ធិសន្តតិកម្មទេ ដូច្នេះហើយ មានតែបុព្វញាតិផ្ទាល់ ឬ បងប្អូនទេ ដែលមានសិទ្ធិសន្តតិកម្ម ។ គេ អាចបង្កើតសិទ្ធិសន្តតិកម្មឱ្យកូនបាន តាមរយៈការដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់ក្រោយមរណភាព (មាត្រា ១០០១ កថាខ័ណ្ឌទី ៥) ក៏ប៉ុន្តែ បណ្តឹងនេះ ត្រូវដាក់ក្នុងអំឡុងពេល ១ ឆ្នាំ បន្ទាប់ពីប្តីគ្មានខាន់ស្លានោះ បានទទួលមរណភាព ។

# ជំពូកទី ៩

# សន្តតិកម្ម

## ផ្នែកទី ១

## ការបែងចែងមតិក

### ១. សេចក្តីផ្តើម

ជាទូទៅ គោលការណ៍សន្តតិកម្ម មានចំនួនពីរ គឺ គោលការណ៍ជម្រះបញ្ជី និង គោលការណ៍សន្តតិកម្មដោយស្វ័យប្រវត្តិ។ ក្រមរដ្ឋប្បវេណីថ្មី បានប្រកាន់យកគោលការណ៍សន្តតិកម្មដោយស្វ័យប្រវត្តិ។

នៅក្នុងគោលការណ៍ជំរះបញ្ជី ដែលប្រទេសកម្ពុជា មិនប្រកាន់យក នៅពេលមានមនុស្សស្លាប់ ពេលនោះតុលាការ ត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមតិក ហើយអ្នកគ្រប់គ្រងនេះ ត្រូវធ្វើការបែងចែកមតិកទៅឱ្យសន្តតិជន។

នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជា ដែលប្រកាន់យកគោលការណ៍សន្តតិកម្មដោយស្វ័យប្រវត្តិ សន្តតិជន ត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចទាំងអស់ នៅពេលមរណភាពរបស់មតកជន ( មាត្រា ១១៤៥ និង ១១៤៧) ។

វិធីធ្វើសន្តតិកម្មនៅកម្ពុជា ត្រូវបានបែងចែកជា ពីរ ប្រភេទ គឺ សន្តតិកម្មតាមច្បាប់ និង សន្តតិកម្មមានបណ្តាំ ( មាត្រា ១១៤៥ កថាខណ្ឌទី ២) ។

មូលហេតុអ្វីបានជាមានពីរដូច្នេះ ? នេះមកពីការគោរពតាមឆន្ទៈរបស់មតកជន។ ពេលនៅរស់ ឬ ពេលត្រូវការលក់វត្ថុមួយ គឺម្ចាស់កម្មសិទ្ធិ ជាអ្នកសម្រេច ដូច្នេះនៅពេលស្លាប់ក៏បានដូចគ្នាដែរ គាត់ ចង់ទុកទ្រព្យឱ្យទៅអ្នកណា ជាសេរីភាពរបស់គាត់ ដូច្នេះគាត់ ត្រូវធ្វើបណ្តាំ ដើម្បីបង្ហាញឆន្ទៈរបស់គាត់។ ក៏ប៉ុន្តែ ការផ្ទេរទាំងពីនេះគឺខុសគ្នាត្រង់ចំណុចមួយ គឺ ការស្លាប់ ពេលផ្ទេរសាមីខ្លួនអត់នៅទេ។ ដូចនេះ ក្នុងក្រមរដ្ឋប្បវេណី ពាក់ព័ន្ធជាមួយសន្តតិកម្ម គេត្រូវធ្វើដោយប្រិតប្រៀង (ប្រុងប្រយ័ត្ន) មុនពេលសន្តតិជន ទទួលបានមតិក ។ ផ្ទុយទៅវិញអ្នកស្លាប់ អាចមិនទុកបណ្តាំទេ នៅក្នុងករណីបែបនេះ ការបែងចែក ត្រូវបានធ្វើឡើង តាមច្បាប់ (ចាប់ពីមាត្រា ១១៥៦ ដល់ មាត្រា១១៦៧) ។

### ២. អ្នកណាខ្លះ គឺជាសន្តតិជននៃមតកជន?

នៅពេលចាប់ផ្តើសន្តតិកម្ម មានដំណាក់កាល ពីរសំខាន់ៗ គឺទី ១ ត្រូវដឹងថាតើមតកជនមានទ្រព្យសម្បត្តិអ្វីខ្លះ? តើនរណាខ្លះជាសន្តតិជន? នៅពេលដែលយើង កំណត់ស្ថានភាពទាំងពីរនេះបាន នោះយើង អាចធ្វើការបែងចែកមតិកបានហើយ។ ការកំណត់បានច្បាស់លាស់អំពីចំនួនសន្តតិជន នោះយើង អាចធ្វើការបែងចែកមតិកទៅតាមភាគនីមួយៗ របស់សន្តតិជនម្នាក់ៗ ដែលមានចំពោះមតិក។

សន្តតិជន រួមមាន :

- សហព័ទ្ធ ( ប្រពន្ធ ឬ ប្ដី) - នៅគ្រប់ករណី ( មាត្រា ១១៦១)

- កូន ( ទាំងកូនបង្កើត និង កូនសុំ) ( ឬ នៅក្នុងករណីសន្តតិកម្មជំនួស) - លំដាប់ទី ១ ( មាត្រា ១១៥៦)

- បុព្វញាតិផ្ទាល់ - លំដាប់ទី ២ ( មាត្រា ១១៥៨)

- បងប្អូនបង្កើត ( ឬករណីសន្តតិកម្មជំនួស) - លំដាប់ទី ៣ ( មាត្រា ១១៦០)

សន្តតិកម្មជំនួស ចាប់ផ្តើម នៅពេលដែលសន្តតិជន ទទួលមរណភាព មុនពេលមរណភាពរបស់មតកជន ( ការចាប់ផ្ដើមសន្តតិកម្ម) ជាអាទិ៍ ( មាត្រា ១១៥៧) ។

## ៣. តើសន្តតិជនម្នាក់ៗ បានទទួលចំណែកមតិកប៉ុន្មាន ?

**លំដាប់ទី ១** គឺ កូន ។ នៅប្រទេសណា ក៏គេ កំណត់យកកូនជាសន្តតិជនដែរ បើទោះបីជាកូនប្រុស ឬ ស្រី តូច ឬ ធំ កូនបង្កើត ឬ កូនសុំក៏ដោយ ។ តើកូនម្នាក់ៗបានទទួលប៉ុន្មានភាគរយ?

មាត្រា ១១៥៦-២ គឺកូនម្នាក់ៗទទួលបានចំណែកមតិកស្មើៗគ្នា ប៉ុន្តែប្រសិនបើមានសហព័ទ្ធ គឺ មាត្រា ១១៦២-ក : កូន និងសហព័ទ្ធ ត្រូវបានចំណែកមតិកស្មើគ្នា ។

**លំដាប់ទី ២** គឺ បុព្វញាតិផ្ទាល់ ត្រូវបានចំណែកស្មើគ្នា មាត្រា ១១៥៩-២ ។ ករណីដែលមានសហព័ទ្ធ គឺ ឪពុកម្ដាយ បាន ២/៣ ( ចែកស្មើគ្នាទៀត គឺបានក្នុងម្នាក់ ១/៣) សហព័ទ្ធបាន ១/៣ ( មាត្រា ១១៦២ ចំណុច ខ) ។ ឬនៅក្នុងករណី មានតែម្ដាយ ឬ ឪពុកតែមួយ ដែលនៅរស់ គឺឪពុក ឬ ម្ដាយនោះ ទទួលបាន ១/២ សហព័ទ្ធ ទទួលបាន ១/២ មាត្រា ១១៦២ ចំណុច ខ ។ ជួនកាល មតកជន អាចមានឪពុកម្ដាយដល់ទៅបីនាក់ ( ឪពុក ចិញ្ចឹមម្នាក់ទៀត) ករណីនេះ គឺ សហព័ទ្ធ ទទួលបាន ១/៣ ( ឬ៣/៩) ឪពុកម្ដាយទាំងបី បាន ២/៣ គឺ ម្នាក់ៗ ទទួលបាន ២/៩ ។

**លំដាប់ទី ៣** បងប្អូនបង្កើត គឺទទួលបានចំណែកស្មើគ្នា មាត្រា ១១៦០ កថាខណ្ឌទី ២

- ករណីបងប្អូនបង្កើតណាមានឪពុក ឬ ម្ដាយតែម្ខាង ត្រូវបាន ១/២ នៃបងប្អូនបង្កើត ដែលមានឪពុក ម្ដាយទាំងសងខាង រួមគ្នាជាមួយនឹងមតកជន ( មាត្រា ១១៦០ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២)

-ករណីមានសហព័ទ្ធ នីតិវិធីបែងចែកគឺមាត្រា ១១៦២ ចំណុច គ គឺសហព័ទ្ធ បាន ១/២ រីឯ បងប្អូន បង្កើត ទទួលបាន១/២ ។

ឧទាហរណ៍ **ក១** ជាកូនរបស់ **ក** (ស្លាប់) និងនាង **ខ** (ប្រពន្ធ) ។ **ក១** (ស្លាប់មុន **ក**) មានកូន ២ នាក់ គឺ **ក២** និង **ក៣**។ ចំណែក មត៌កគឺ ១/២ បានទៅ នាង **ខ** រីឯ ១/២ ទៀត បានទៅដល់ **ក២** និង **ក៣** (មាត្រា ១១៦២ ចំណុច គ)

## ៤. ភាពគ្រប់លក្ខណៈសម្បត្តិជាសន្តតិជន

សន្តតិជន ដែលអាចទទួលមត៌ក លុះណាតែមិនមែនជាជន ដែលមានចែង នៅក្នុងមាត្រា ១១៥០ និង ១១៥១ នៃក្រមរដ្ឋប្បវេណី។ ការចែងជាពីរបញ្ញត្តិដូច្នេះ ដោយហេតុថា មាត្រា ១១៥១ គឺតម្រូវឱ្យធ្វើសកម្មភាព ដាក់ពាក្យសុំ រីឯមាត្រា ១១៥០ មិនចាំបាច់ដាក់ពាក្យសុំទេ គឺស្វ័យប្រវត្តិតែម្តង។ ប្រសិនបើធ្វើការប្រៀបធៀប គឺសកម្មភាព ដែលមានចែងនៅក្នុងមាត្រា ១១៥០ មានលក្ខណៈធ្ងន់ជាង មាត្រា ១១៥១។ ក៏ប៉ុន្តែ នៅក្នុងការ អនុវត្ត ទោះបីជានៅក្នុងស្ថានភាព ដែលមានចែងក្នុងមាត្រា ១១៥០ក៏ដោយ ក៏វា មានការលំបាកសំរាប់តុលាការ ក្នុងការ វិនិច្ឆ័យលើការបាត់បង់សិទ្ធិរបស់សន្តតិជន ដោយគ្មានការអះអាង និង ការបង្ហាញរបស់ភាគីម្ខាងទៀត។

វា ខុសពីការបែងចែកមត៌ក :

ឧទាហរណ៍ នៅប្រទេសជប៉ុន នៅក្នុងករណីនៃសន្តតិកម្ម ដែលមានវិវាទនៅលើទំហំនៃមត៌ក គេ តែងណែនាំអោយដាក់បណ្តឹងលើបញ្ហានេះមុន។ ប្រសិនបើមិនបានដោះស្រាយវិវាទនៅលើបញ្ហានេះទេ នោះ សេចក្តីសំរេចរបស់តុលាការទាក់ទងនឹងការបែងចែកមត៌ក អាចនឹងត្រូវបានផ្លាស់ប្តូរ នៅពេលក្រោយ ដោយសារតែបណ្តឹងដោយផ្អែកលើមូលហេតុថា សេចក្តីសំរេចនោះ ត្រូវបានធ្វើឡើង ដោយផ្អែកលើអង្គហេតុមិនពិត ទាក់ទងនឹងទំហំនៃសន្តតិកម្ម។

ឧបមាថា លោក **ក** មើលទៅហាក់ដូចជា មានដីមួយកន្លែង ហើយ បានទទួលមរណភាព។ លោក **ខ** ដែលជាសន្តតិជនម្នាក់ នៅក្នុងចំណោមសន្តតិជនទាំងអស់ បានអះអាងថា ដីនោះ មិនមែនជាដីរបស់ **ក** ទេ។ តើជាករណីវិវាទបែបណា? នៅពេល លោក **ក** ស្លាប់ ភាគីដទៃទៀត យកល្អ ត្រូវដាក់ពាក្យបណ្តឹងទាក់ទងនឹងបញ្ហានេះជាមុនសិន ព្រោះ ដីនោះ គឺជាកម្មវត្ថុមត៌ក។ នៅក្នុងបណ្តឹង សន្តតិជនទាំងអស់ គប្បីត្រូវបញ្ចូលជាភាគី។

នៅពេល លោក **ក** បានស្លាប់ទៅ ហើយទុកបណ្តាំ ដែលមត៌កទាំងអស់ ត្រូវឱ្យទៅកូន **ខ**។ ប៉ុន្តែ កូន **គ** មានភាគបម្រុងរបស់គាត់ដែរ។ មធ្យោបាយតែមួយគត់ ដើម្បីមិនរាប់បញ្ចូល **គ** គឺត្រូវប្រើមាត្រា ១១៥០ ឬ ១១៥១។

## ៥. ទំហំមត៌ក

ទំហំមរតក គឺជាទ្រព្យសម្បត្តិរបស់មតកជន។ សំណួរ អាចសួរឡើងថា តើស្វែងរកមរតក យ៉ាងដូចម្តេច។ ជំរើសទី ១ គឺថារាល់ភាគី ត្រូវបង្ហាញពីចំណុចនេះ។ ជាងនេះទៅទៀត "ការប្រគល់កិច្ចការស្រាវជ្រាវ" (មាត្រា

១០ នៃច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និង មាត្រា ១៣០ នៃក្រមនីតិវិធីរដ្ឋប្បវេណី) អាចត្រូវបានយកមកអនុវត្ត ដែល តុលាការ អាចផ្ទុកផ្តាក់ឱ្យមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ទាក់ទងនឹងអចលនវត្ថុ និង ផ្ទុកផ្តាក់អោយស្ថាប័នធនាគារ ទាក់ទងនឹងគណនីនៅធនាគារ ។

## ៦. ការវាយតំលៃមត៌ក

មរតក អាចមានជាប្រាក់ បំណុល និងជាអចលនវត្ថុ។ នៅក្នុងចំណោមមរតក មានតែអចលនវត្ថុទេ ដែលមានការលំបាកក្នុងការប៉ាន់ពីតំលៃរបស់វា។ ភាគី អាចព្រមព្រៀងគ្នាពីតំលៃ ប៉ុន្តែ ប្រសិនបើ គ្មានមានការព្រមព្រៀងគ្នាទេ នោះ តំរូវអោយមានអ្នកជំនាញ មកវាយតំលៃ។

## ៧. ការកែតម្រូវនូវចំណែកមត៌ក ចំពោះសន្តិជនដែលទទួលផលប្រយោជន៍ពិសេស

### ៧.១ គោលគំនិត

មាត្រា ១១៦៣

| |
|---|
| ឧទាហរណ៍ : លោក X បានទទួលមរណភាព ហើយគ្មានប្រពន្ធទេ ។ លោក X បានបន្សល់ទុកមត៌ក ចំនួន ៩០០ ដុល្លារ។ លោក X មានកូន ៣ នាក់ គឺលោក A លោក B និងលោក C។ កាលពីលោក X នៅរស់ គាត់ បានផ្តល់ផលប្រយោជន៍ពិសេស ៣០០ ដុល្លា ឱ្យទៅលោក C ។<br>តាមមាត្រា ១១៦៣ ទ្រព្យចាត់ទុកជាមត៌ក គឺ ៩០០ + ៣០០ = ១.២០០ ដុល្លារ។<br>ដូច្នេះ ទ្រព្យ ដែលចាត់ទុកជាចំណែកនៃមត៌ក គឺ លោក A លោក B និងលោក C ត្រូវទទួលបាន ៤០០ ម្នាក់ ស្មើៗ គ្នា។ បន្ទាប់ ចំពោះចំណែកមត៌កពិតប្រាកដរបស់លោក C គឺ ១០០ ដុល្លា ដែលជាសមតុល្យ នៅក្រោយការដក ៣០០ ដុល្លា ចេញពីទ្រព្យចាត់ទុកជាមត៌ក។ |

### ៧.២ កត្តាដែលត្រូវពិចារណា

ត្រូវចាត់ទុកថា អច្ច័យទាន គឺជាផលប្រយោជន៍ពិសេសរៀងរាល់ពេល។ ប៉ុន្តែប្រទានកម្ម មុនពេលទទួលមរណភាព មិនមែនជាផលប្រយោជន៍ពិសេសរៀងរាល់ពេលនោះទេ ។

ផលប្រយោជន៍ពិសេស គឺជាប្រទានកម្មពិសេស ដែលមតកជនបានផ្តល់នូវទ្រព្យណាមួយទៅឱ្យសន្តិជន។ មិនមែនឱ្យអ្វីបន្តិចបន្តួច សម្រាប់ចាយវាយប្រចាំថ្ងៃ ជាផលប្រយោជន៍ពិសេសនោះទេ។ បើការឱ្យនោះ លើសពីទំហំធម្មតា ជាផលប្រយោជន៍ពិសេស។ នេះ ជាបញ្ហានៃការបកស្រាយ ព្រោះលក្ខណៈវិនិច្ឆ័យ ដែលចែងនៅក្នុងមាត្រា ១១៦៣ គឺមានលក្ខណៈអរូបី។

នៅក្នុងការអនុវត្តនៅប្រទេសជប៉ុន កត្តាដ៏សំខាន់មួយ នៅក្នុងចំណោមកត្តាសំខាន់ជាច្រើន នៅក្នុងការបកស្រាយបញ្ហានេះ គឺចំនួនទឹកប្រាក់នៃអំណោយ មានន័យថា ទឹកប្រាក់កាន់តែធំ រិតតែអាចចាត់ទុកជាផលប្រយោជន៍ពិសេស យើង ត្រូវពិនិត្យទៅតាមស្ថានភាពសេដ្ឋកិច្ចរបស់មតកជន។

ឧទាហរណ៍ :

- ទ្រព្យសម្បត្តិ មាន ១ លាន ដុល្លារ ឱ្យចំនួន ១០០ដុល្លារ នេះ ហាក់ដូចជាមិនមែនជាផលប្រយោជន៍ពិសេស

- ការឱ្យដីធ្លី ហាក់ដូចជាផលប្រយោជន៍ពិសេស

- ការឱ្យប្រាក់ទិញផ្ទះ ហាក់ដូចជាផលប្រយោជន៍ពិសេស

- កំជាប់ពាក្យ ការលើកជំនូន អាច ឬ មិនអាច ចាត់ទុកជាផលប្រយោជន៍ពិសេស អាស្រ័យទៅលើការចំណាយ និន្នាការ ប្រពៃណី ជាអាទិ៍ នៅក្នុងសាសនា។

ឧទាហរណ៍នៃមាត្រា ១១៦៥ គឺមានដូចខាងក្រោម។

ឧទាហរណ៍ :

លោក X បានទទួលមរណភាព ។ លោក X បានបន្សល់ទុកមតិក ចំនួន ១,០០០ ដុល្លារ ។ គាត់ មានកូន ៣ នាក់ គឺលោក A លោក B និងលោក C។ កាលពីលោក X នៅរស់ គាត់ បានផ្ដល់ផលប្រយោជន៍ពិសេសឱ្យទៅលោក A ចំនួន ១,០០០ ដុល្លារ និង លោក B ចំនួន ៤០០ ដុល្លារ ។

ដូច្នេះ ទ្រព្យ ដែលត្រូវចាត់ទុកជាមតិក ចំនួន ២៤០០ ដុល្លារ ហើយ ទ្រព្យ ដែលត្រូវចាត់ទុកជាចំណែកមតិករបស់លោក A លោក B និងលោក C គឺចំនួន ៨០០ ដុល្លារ។ ខាងក្រោមនេះ គឺជាការគណនា តាមមាត្រា ១១៦៣ ចំណែកមតិកពិតប្រាកដរបស់ A គឺ "-២០០" ដុល្លា (=៨០០ - ១,០០០) ប៉ុន្តែ មាត្រា ១១៦៥ ចែងថា លោក A មិនបាច់បង្វិល ២០០ ដុល្លា ដែលជាផ្នែកដែលលើស មកវិញទេ។ ចំណែកមតិកពិតប្រាកដរបស់ B គឺ ៤០០ ដុល្លា (=៨០០ - ៤០០) ហើយ ចំណែកមតិកពិតប្រាកដរបស់ C គឺ ៨០០ ដុល្លា។ ដូច្នេះ មតិក ដែលមានតំលៃ ១,០០០ ដុល្លា ត្រូវបានគេបែងចែកតាមសមាមាត្រា ៤០០:៨០០ (១:២) រវាង B និង C។ B ទទួលបាន ៣៣៣ ដុល្លា ហើយ C ទទួលបាន ៦៦៧ ដុល្លា។

## ៤. ភាគនៃវិភាគទាន

ការកែតម្រូវទី ២ នូវចំណែកមតិក គឺជាភាគនៃវិភាគទាន (មាត្រា ១១៦៦)

ករណីដែលសន្តតិជន បានចូលរួមវិភាគទាន ដើម្បីបង្កើនទ្រព្យមតកជន ។

> ឧទាហរណ៍ លោក X មានកូន បីនាក់ គឺលោក a លោក b និង លោក c នៅពេលដែលនៅរស់ លោក a បានចូលរួមវិភាគទានដល់លោក X ចំនួន ៤០០ ដុល្លារ ។ នៅពេលទទួលមរណភាព លោក X បន្សល់ទុក ចំនួន ១,០០០ ដុល្លារ ។ ដូច្នេះ ទ្រព្យ ដែលចាត់ទុកជាមតិក គឺ ១,០០០ - ៤០០ = ៦០០ ដុល្លារ ហើយ ទ្រព្យ ដែលចាត់ទុកជាចំណែកនៃការមតិករបស់កូនម្នាក់ ៗ គឺ ២០០ ដុល្លារ ( = ៦០០ ÷ ៣) ។ ចំណែកមតិកពិតប្រាកដរបស់ a គឺ ៦០០ ដុល្លា ដែល ២០០ ដុល្លារ ( ទ្រព្យដែលចាត់ទុកជាចំណែកមតិក) បូកជាមួយនឹង ៤០០ ដុល្លារ ( ភាគនៃវិភាគទាន) ។

### ៤.១ ប្រភេទនៃវិភាគទាន

- វិភាគទានជាការគ្រប់គ្រងទ្រព្យសម្បត្តិ
- ជួយរកស៊ីជាវិភាគទានជាគេហកិច្ច
- ឱ្យដើមទុនរកស៊ី ជាវិភាគទានជាការចេញដើមទុន
- នៅពេលមតកជនឈឺ ចេញលុយថែទាំ គឺវិភាគទានជាការថែទាំ

### ៤.២ កំណត់ចំណាំមួយចំនួន

* មាត្រា ១១៦៦ តំរូវអោយមាន វិភាគទាន "ពិសេស" ដូច្នេះ វិភាគទានសាមញ្ញធម្មតា ត្រូវបានរាប់បញ្ចូលទៅក្នុងកាតព្វកិច្ចផ្តល់អាហារកាតព្វកិច្ចរវាងញាតិ ឬ វិភាគទានជាថ្នូរនៃរង្វាន់ គឺមិនបំពេញលក្ខខណ្ឌនៃមាត្រានេះទេ ។

* តុលាការ ទទួលស្គាល់ភាគនៃវិភាគទានពិសេស មានតែនៅពេលដែល ពាក្យសុំ ត្រូវបានដាក់ ( មាត្រា ១១៦៦ កថាខណ្ឌ ទី ២) ។

## ៥. សេចក្តីសម្រេចអំពីវិធីបែងចែកជាក់ស្តែង

គេ អាចគណនាទឹកប្រាក់នៃមតិក ដែលសន្តតិជនម្នាក់ៗ អាចទទួលបាន (ទឹកប្រាក់ទទួលជាក់ស្តែង) ។ ក៏ប៉ុន្តែ នៅពេលបែងចែកមតិក មិនត្រឹមតែត្រូវកំណត់នូវទឹកប្រាក់នៃចំណែកមតិករបស់សន្តតិជនម្នាក់ៗ ប៉ុណ្ណោះទេ គឺត្រូវកំណត់ទាំងវិធីបែងចែកមតិកនោះជាក់ស្តែង ដើម្បីកុំឱ្យមានវិវាទ ។ ចំណុចនេះ ក៏ដូចគ្នានឹងការបែងចែកទ្រព្យសម្បត្តិ នៅពេលលែងលះគ្នាដែរ ។

បញ្ហាសំខាន់ គឺភាគី អាចទទួលបាននូវសាលក្រម ដែលអាចសម្រេច ( អាចអនុវត្ត) នូវការបែងចែកមតិក ដោយមិនចាំបាច់មានការចូលរួមពីសន្តតិជនដទៃទៀត ។

បើសិនជាមិនមានការជជែកអំពីការបែងចែកមតិក ឬ គ្មានដីកាសម្រេច ដែលកំណត់អំពីការបែងចែកមតិកទេ មិនអាចអនុញ្ញាតឱ្យតុលាការអនុវត្ត ឬ អាជ្ញាសាលា ធ្វើការវិនិច្ឆ័យអំពីវិធីបែងចែកឡើយ ។

## ៩.១ វិធីបែងចែកមតិក

ក. ការបែងចែកវត្ថុជាក់ស្តែង

ការបែងចែកវត្ថុជាក់ស្តែង គឺជាវិធីធ្វើការបែងចែកវត្ថុដោយផ្ទាល់តែម្តង ។

ខ. ការបែងចែកជាតម្លៃថ្នូរ

ការបែងចែងជាតំលៃថ្នូរ គឺជាវិធីធ្វើការបែងចែកមតិកដោយឱ្យសន្តតិជនណាម្នាក់ ទទួលទ្រព្យមួយទាំងមូល ហើយបង់ជាថ្លៃថ្នូរសមស្រប ទៅតាមចំណែកមតិកនៃសន្តតិជនម្នាក់ៗ ទៅឱ្យអ្នកទាំងនោះ ។

គ. ការបែងចែកមតិកដោយការប្តូរជាប្រាក់ ( មាត្រា ១២៧១)

ការបែងចែងមតិកដោយការប្តូរជាប្រាក់ គឺជាវិធីធ្វើការបែងចែកមតិក តាមរយៈការបែងចែកថ្លៃលក់ដែល បានមកពីការលក់ដោយបង្ខំ ។

## ៩.២ កត្តាដែលត្រូវពិចារណា

ត្រូវប្រយ័ត្នដល់មាត្រា ១២៦៧ កថាខ័ណ្ឌទី ១ , មាត្រា ១២៦៨ ( សិទ្ធិអាទិភាពរបស់សហព័ទ្ធ)

## ៩.៣ ស្តីពីកាតព្វកិច្ច

ដូចដែលបានពន្យល់ខាងលើនេះ តាមផ្លូវតុលាការ កាតព្វកិច្ចមិនមែនជាកម្មវត្ថុនៃការបែងចែកមតិកទេ គឺត្រូវទទួលបន្តទៅតាមចំណែកមតិកដែលច្បាប់កំណត់ ។ នៅពេលធ្វើការបែងចែកមតិក ត្រូវពិចារណា ដោយផ្អែកលើការទទួលបន្តនូវកាតព្វកិច្ច ទៅតាមចំណែកមតិក ដែលច្បាប់កំណត់នេះផង ( មាត្រា ១២៦៩) ។

## ៩.៤ ទម្រង់នៃការបែងចែកមតិក

ការជជែកអំពីការបែងចែកមតិក មិនចាំបាច់មានទម្រង់អ្វីជាក់លាក់ទេ អាចធ្វើតាមមាត់ក៏បានដែរ ។ ក៏ប៉ុន្តែ ការផ្ទេរសិទ្ធិទ្រព្យ ចាំបាច់ត្រូវមានទម្រង់ ដូច្នេះហើយ ក្នុងការបែងចែកមតិក ក៏ត្រូវមានទម្រង់ត្រឹមត្រូវដែរ ( មាត្រា ១២៦៦ កថាខ័ណ្ឌទី ២) ។

# ផ្នែកទី ២

# មតកសាសន៍

## ១. អត្ថន័យ និង លក្ខណៈនៃមតកសាសន៍

### ១.១ និយមន័យ

មតកសាសន៍ គឺជាការបង្ហាញឆន្ទៈឯកតោភាគី ដោយពុំមានភាគីម្ខាងទៀត ដែលធ្វើដោយម្ចាស់បណ្តាំ ពាក់ព័ន្ធនឹងចំណុចពិសេសស្តីពីទំនាក់ទំនងទ្រព្យសម្បត្តិរបស់ជននោះ ឬ ស្តីពីទំនាក់ទំនងឋានៈបុគ្គល ក្នុងគោលបំណងបង្កើតអានុភាព នៅពេលដែលខ្លួនទទួលមរណភាព ហើយ ដែលបានធ្វើទៅតាមវិធីកំណត់ជាក់លាក់ ។

មនុស្សយើង អាចចាត់ចែងដោយសេរី នូវទ្រព្យសម្បត្តិរបស់ខ្លួនបាន តាមរយៈមតកសាសន៍ ( សេរីភាពនៃមតកសាសន៍) ។ នេះ គឺជាការពង្រីកគោលការណ៍ស្វ័យភាពរបស់បុគ្គលឯកជន រហូតដល់ក្រោយពេលមរណភាព ។

### ១.២ លក្ខណៈនៃមតកសាសន៍

- គឺជាសកម្មភាពឯកតោភាគី ដោយគ្មានភាគីម្ខាងទៀត ។

  មិនចាំបាច់មានការទទួល ឬ យល់ព្រមពីភាគីម្ខាងទៀតទេ ។

- មតកសាសន៍ គឺជាសកម្មភាពក្រោយពេលមរណភាព ហើយ ទាល់តែម្ចាស់បណ្តាំ ទទួលមរណភាព ទើបមានអានុភាព ។

  នៅពេលដែលម្ចាស់បណ្តាំ នៅរស់ មតកសាសន៍ ពុំមានអានុភាពទេ ម្ល៉ោះហើយ ម្ចាស់បណ្តាំ មានសិទ្ធិសេរីភាពក្នុងការលុបចោលនូវការបង្ហាញឆន្ទៈតាមរយៈមតកសាសន៍ នៅពេលណាក៏បានដែរ ( មាត្រា ១១៨៨) ។

- មតកសាសន៍ គឺជាសកម្មភាព ដែលត្រូវធ្វើតាមទំរង់ ។

  នៅពេលដែលមតកសាសន៍ មានអានុភាព ម្ចាស់បណ្តាំ បានទទួលមរណភាពទៅហើយ ។ ដើម្បីធ្វើឱ្យម្ចាស់បណ្តាំ បង្ហាញឆន្ទៈ ដោយមានការពិចារណាហ្មត់ចត់ ហើយ ដើម្បីការពារកុំឱ្យមានការក្លែងបន្លំ ឬ កែមតកសាសន៍ ឬ កុំអោយមានជម្លោះដោយសារមតកសាសន៍នោះ ចាំបាច់ធ្វើមតកសាសន៍ទៅតាមវិធីដែលបានកំណត់ជាក់លាក់ ។

- ចំណុចអ្វី ៗ ដែលអាចធ្វើតាមមតកសាសន៍ ត្រូវបានកំណត់ដោយច្បាប់ ។

  ម្ចាស់បណ្តាំ បានទទួលមរណភាពបាត់ទៅហើយ ដូច្នេះ មានការបាត់បង់ប្រធាន ម្ល៉ោះហើយ អ្វី ៗ ដែលអាចសំរេចតាមរយៈមតកសាសន៍ ក្រោយពេលម្ចាស់បណ្តាំទទួលមរណភាព ក៏ត្រូវបានកំរិតដែរ ( ចំណុច ដែលត្រូវសរសេរក្នុងមតកសាសន៍) ។

- មតកសាសន៍ គឺមានភាពផ្ដាច់មុខរបស់បុគ្គល ។

មតកសាសន៍ គឺជាការទទួលស្គាល់នូវអានុភាពច្បាប់ ដោយគោរពតាមឆន្ទៈរបស់ម្ចាស់បណ្ដាំ ។ ហេតុនេះហើយ មិនត្រូវមានការយល់ព្រម ឬ មិនអាចឱ្យអ្នកតំណាងធ្វើជំនួសបានទេ ។ ឱ្យតែមានសមត្ថភាពធ្វើមតកសាសន៍ ទោះបីជាជននៅក្រោមអាណាព្យាបាលទូទៅ ឬ ជននៅក្រោមហិតូបត្ថម្ភក៏ដោយ ក៏អាចធ្វើមតកសាសន៍បានដែរ ( មាត្រា ១១៦៨ កថាខណ្ឌទី ១) ។

## ២. សមត្ថភាពធ្វើមតកសាសន៍

មតកសាសន៍ គឺជារបបមួយ ដែលគោរពឆន្ទៈរបស់ម្ចាស់បណ្ដាំ ។ ដូច្នេះ ម្ចាស់បណ្ដាំ ត្រូវមានសមត្ថភាពវិនិច្ឆ័យត្រឹមត្រូវ ទៅលើមតកសាសន៍របស់ខ្លួន ។ ហេតុនេះហើយ ម្ចាស់បណ្ដាំ ត្រូវមានសមត្ថភាព (※) នៅពេលធ្វើមតកសាសន៍ ( មាត្រា ១១៦៩ កថាខណ្ឌទី ១) ។ ម្យ៉ាងទៀត អ្នកនៅក្រោមអាណាព្យាបាលទូទៅ ដើម្បីធ្វើមតកសាសន៍ ត្រូវមានសមត្ថភាពខាងឆន្ទៈឡើងវិញ ( មាត្រា ១១៧៦)

※ គឺជាការមានសមត្ថភាពយល់ដឹង និង វិនិច្ឆ័យនូវលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ។

## ៣. វិធីធ្វើមតកសាសន៍

### ៣.១ គោលគំនិត

មតកសាសន៍ ដែលពុំបានធ្វើឡើងតាមវិធី ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណីទេ ពុំមានអានុភាពឡើយ ( មាត្រា ១១៧០) ។

មតកសាសន៍ មានចំណុចសំខាន់ៗ ជាច្រើន ។ ក៏ប៉ុន្តែ នៅពេលដែលមតកសាសន៍ មានអានុភាព ពេលនោះម្ចាស់បណ្ដាំ បានទទួលមរណភាពបាត់ទៅហើយ ដូច្នេះ មិនអាចតវ៉ាបានទេ ហើយ មិនអាចសួរបញ្ជាក់នូវឆន្ទៈពិតប្រាកដរបស់អ្នកនោះដែរ ។ ហេតុនេះហើយ មានតែធ្វើការវិនិច្ឆ័យអំពីឆន្ទៈរបស់ម្ចាស់បណ្ដាំ ឬ ខ្លឹមសារនៃមតកសាសន៍ តាមពាក្យពេចន៍ ដែលមានសរសេរក្នុងមតកសាសន៍នោះប៉ុណ្ណោះ ។ លើសពីនេះ ក៏អាចមានមតកសាសន៍ក្លែងក្លាយ ឬ អាចមានការក្លែងបន្លំដែរ ។

ដូច្នេះ ដើម្បីឱ្យឆន្ទៈរបស់ម្ចាស់បណ្ដាំ មានភាពច្បាស់លាស់ ហើយ ដើម្បីជៀសវាងនូវទំនាស់នៅពេលក្រោយ ម្យ៉ាងទៀត ដើម្បីការពារកុំឱ្យមានការធ្វើមតកសាសន៍ក្លែងក្លាយ ឬ ក្លែងបន្លំ ក្រមរដ្ឋប្បវេណី បានកំណត់លំអិតអំពីវិធីធ្វើមតកសាសន៍នោះ ហើយបើសិនជាមិនធ្វើតាមវិធីនោះទេ មតកសាសន៍នោះ ពុំមានអានុភាពឡើយ ។

## ៣.២ ប្រភេទនៃវិធីធ្វើមតកសាសន៍

**១.** វិធីធម្មតា

មតកសាសនី ដោយលិខិតយថាភូត ( មាត្រា ១១៧៣)

មតកសាសនី ដោយលិខិតឯកជន ( មាត្រា ១១៧៤)

មតកសាសនី ដោយលិខិតសំងាត់ ( មាត្រា ១១៧៥)

**២.** វិធីពិសេស

មតកសាសនីរបស់ជន ដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ( មាត្រា ១១៧៧)

មតកសាសនីរបស់ជន ដែលត្រូវជាប់ឃុំឃាំង ( មាត្រា ១១៧៨ កថាខណ្ឌទី ១)

មតកសាសនីរបស់ជន ដែលនៅលើនាវា ឬ យន្តហោះ ( មាត្រា ១១៧៨ កថាខណ្ឌទី ២)

មតកសាសនីដោយវិធីពិសេស គឺជាមតកសាសន៍សំរាប់ករណីបន្ទាន់ ហេតុនេះហើយដើម្បីឱ្យមានអានុភាពច្បាប់តំរូវឱ្យមានការស្របនឹងលក្ខខណ្ឌផ្សេង ៗ ទៀត ។

### ៣.២.១ មតកសាសន៍ដោយវិធីធម្មតា

### ៣.២.១.១ មតកសាសន៍ដោយលិខិតយថាភូត ( មាត្រា ១១៧៣)

នេះ គឺជាវិធីធ្វើមតកសាសន៍ដោយលិខិតយថាភូត ។

ម្ចាស់បណ្តាំ ត្រូវពន្យល់អំពីគោលគំនិតនៃមតកសាសន៍ចំពោះសារការី ហើយត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិចពីរនាក់ ហើយ សារការី ត្រូវសរសេរអំពីខ្លឹមសារនៃមតកសាសនីនោះជាលាយលក្ខណ៍អក្សរ ហើយ ត្រូវអានឱ្យម្ចាស់បណ្តាំស្តាប់ ។ បន្ទាប់មក ម្ចាស់បណ្តាំ សាក្សី និង សារការី ត្រូវចុះហត្ថលេខា ជាអាទិ៍ ទៅលើលិខិតនោះ ។

**គុណសម្បត្តិ**

- មានភាពត្រឹមត្រូវច្បាស់លាស់ (សារការី ជាអ្នកធ្វើ ហេតុនេះហើយ មិនមានបញ្ហាអសុពលភាព ដោយសារកង្វះលក្ខណៈទេ) ។

- ជន ដែលមិនចេះសរសេរអក្សរ ក៏អាចធ្វើមតកសាសនីបានដែរ (គ្រាន់តែពន្យល់អំពីខ្លឹមសារនៃមតកសាសនីតាមមាត់ ចំពោះសារការីបានហើយ)

( - ការការពារកុំឱ្យបាត់ ឬ កុំឱ្យគេធ្វើក្លែងក្លាយ ឬ ក្លែងបន្លំ ( នៅជប៉ុន សារការី ជាអ្នករក្សាទុក ។))

- ពេលអនុវត្តមតកសាសនី មិនចាំបាច់មាននីតិវិធីពិនិត្យបញ្ជាក់ទេ

**គុណវិបត្តិ**

- ចាំបាច់មានអន្តរាគមន៍ពីសារការី

- សាក្សី ដឹងអំពីខ្លឹមសារនៃមតកសាសន៍

### ៣.២.១.២ មតកសាសន៍ ដោយលិខិតឯកជន ( មាត្រា ១១៧៤)

នេះ គឺជាវិធីធ្វើមតកសាសន៍ ដែលម្ចាស់បណ្តាំ ត្រូវសរសេរអំពីខ្លឹមសារទាំងមូលនៃមតកសាសន៍ ហើយចុះថ្ងៃខែឆ្នាំ ព្រមទាំងចុះហត្ថលេខាដោយខ្លួនឯង។

**គុណសម្បត្តិ**

- ម្ចាស់បណ្តាំ អាចធ្វើតែឯងបាន (ដោយមិនចាំបាច់មានអន្តរាគមន៍ពីសារការី ឬ វត្តមានរបស់សាក្សីបាន)

- មិនអស់សោហ៊ុយ

- អាចរក្សាការសំងាត់នៃខ្លឹមសារនៃមតកសាសន៍

**គុណវិបត្តិ**

- មិនសូវមានភាពត្រឹមត្រូវច្បាស់លាស់ទេ (អាចមានករណីអសុពលភាពដោយសារផ្ទុយនឹងទម្រង់ដែរ)

- បើសិនជាមិនចេះសរសេរអក្សរទេ មិនអាចធ្វើបានទេ

- អាចបាត់ ឬ អាចមានការធ្វើក្លែងក្លាយ ឬ ក្លែងបន្លំ

- ចាំបាច់ត្រូវមានការពិនិត្យបញ្ជាក់ដើម្បីអនុវត្តមតកសាសន៍

### ៣.២.១.៣ មតកសាសន៍ដោយលិខិតសំងាត់ ( មាត្រា ១១៧៥)

មតកសាសន៍ដោយលិខិតសំងាត់ គឺជាវិធីធ្វើមតកសាសន៍មួយ ដែលគេបានឱ្យដឹងច្បាស់លាស់ថា មានមតកសាសន៍ តែគេរក្សាការសំងាត់អំពីខ្លឹមសារនោះ។

ម្ចាស់បណ្តាំ ត្រូវចុះហត្ថលេខាក្នុងលិខិត (អាចប្រើម៉ាស៊ីនធ្វើឯកសារបាន ឬ ក៏អាចឱ្យអ្នកដទៃសរសេរជំនួសក៏បាន) ហើយ ត្រូវដាក់លិខិតនោះ ក្នុងស្រោមបិទជិត ជាអាទិ៍ ព្រមទាំងសរសេរសញ្ញាលើមាត់ស្រោមនោះ ដើម្បីឱ្យដឹង នៅពេលគេបើកស្រោម ហើយ ត្រូវដាក់នៅចំពោះមុខសារការីម្នាក់ និង សាក្សីពីរនាក់ ដោយថ្លែងការណ៍ថា នេះ គឺជាមតកសាសន៍ ជាអាទិ៍ ហើយ សារការី ម្ចាស់បណ្តាំ សាក្សី ត្រូវចុះហត្ថលេខាលើលិខិតបិទជិតនោះ។

ម្យ៉ាងទៀត ទោះបីជាមិនស្របនឹងលក្ខខណ្ឌនៃមតកសាសន៍ដោយលិខិតសំងាត់ក៏ដោយ ក៏មានសុពលភាពជាមតកសាសន៍ដោយលិខិតឯកជនដែរ (មាត្រា ១១៧១)។

**គុណសម្បត្តិ**

- ទោះបីជាមិនចេះសរសេរអក្សរ ក៏អាចធ្វើបានដែរ

- អាចការពារការធ្វើក្លែងក្លាយ ឬ ក្លែងបន្លំ

- អាចរក្សាការសំងាត់អំពីខ្លឹមសារនៃមតកសាសន៍បាន

**គុណវិបត្តិ**

- ចាំបាច់មានអន្តរាគមន៍ពីសារការី

- ចាំបាច់ធ្វើការពិនិត្យបញ្ជាក់ ពេលអនុវត្តមតកសាសន៍

| | មតកសាសន៍ដោយលិខិតយថាភូត | មតកសាសន៍ដោយលិខិតឯកជន | មតកសាសន៍ដោយលិខិតសំងាត់ |
|---|---|---|---|
| អ្នកសរសេរ | សារការី | ម្ចាស់បណ្តាំ | អ្នកណាក៏បានដែរ |
| សាក្សី | សាក្សីយ៉ាងតិច ពីរនាក់ | គ្មាន | សាក្សីយ៉ាងតិច ពីរនាក់ សារការី |
| ហត្ថលេខា | ម្ចាស់បណ្តាំ សារការី សាក្សី | ម្ចាស់បណ្តាំ | ម្ចាស់បណ្តាំ សារការី សាក្សី |
| ពិនិត្យបញ្ជាក់ | មិនចាំបាច់ | ចាំបាច់ | ចាំបាច់ |

### ៣.២.២ វិធីពិសេស

#### ៣.២.២.១ មតកសាសន៍របស់ជន ដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ( មាត្រា ១១៧៧)

ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់ជីវិត ប្រសិនជាជននោះ អាចធ្វើមតកសាសន៍តាមធម្មតាបាន ជននោះ អាចធ្វើមតកសាសន៍ធម្មតាបាន។

ក្នុងករណីដែលពុំមានសមត្ថភាព ឬ ពុំមានពេលវេលា បើសិនជាមានវត្តមាន សាក្សីយ៉ាងតិច បីនាក់ ម្ចាស់បណ្តាំ អាចនិយាយប្រាប់តាមមាត់ អំពីគោលគំនិតនៃមតកសាសន៍របស់ខ្លួន ប្រាប់សាក្សីម្នាក់ក្នុងចំណោមនោះ ហើយអោយសាក្សីនោះសរសេរ។ បន្ទាប់ពីបានបញ្ជាក់ខ្លឹមសារនៃមតកសាសន៍នោះហើយ សាក្សីម្នាក់ៗ ត្រូវចុះហត្ថលេខាលើលិខិតនោះ។

ក្នុងអំឡុងពេល ១ ខែ ដោយគិតពីថ្ងៃដែលបានធ្វើមតកសាសន៍នោះ ត្រូវមានការបញ្ជាក់ពីតុលាការ។ ហើយ ក្នុងករណីដែលតុលាការ ទទួលស្គាល់ថា ខ្លឹមសារនោះ គឺជាឆន្ទៈពិតរបស់ម្ចាស់បណ្តាំ ពេលនោះមតកសាសន៍ នឹងមានសុពលភាព។

### ៣.២.២.២ មតកសាសន៍របស់ជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍ ( មាត្រា ១១៧៨)

ចំពោះជន ដែលត្រូវជាប់ឃុំឃាំង ឬ ជនដែលនៅលើនាវា ឬ នៅក្នុងយន្តហោះ បើសិនជាអាចធ្វើមតកសាសន៍បាន ( មតកសាសន៍ដោយលិខិតឯកជន) ជននោះ អាចធ្វើមតកសាសន៍ដោយវិធីធម្មតាក៏បាន ។

អាចមានករណី ដែលម្ចាស់បណ្តាំមិនចេះអក្សរ ឬ ខូចដៃ មាត្រា ១១៧៨ បានចែងចំពោះករណីបែបនេះ ។

នីតិវិធីនៃករណីនេះ គឺប្រហាក់ប្រហែលនឹងមតកសាសន៍ ដោយលិខិតយថាភូតដែរ គឺនគរបាល ឬ នាវិកនាយក ជាដើម នឹងមានតួនាទីជាសារការី ។

មតកសាសន៍ ដោយផ្អែកលើមាត្រានេះ គឺជាមតកសាសន៍ ដែលធ្វើឡើងជាបណ្តោះអាសន្នទេ ដូច្នេះ មតកសាសន៍នេះ នឹងបាត់បង់នូវអានុភាព ៦ ខែ ក្រោយពេលចេញពីកន្លែងឃុំឃាំង ឬ ក្រោយពេលចុះពីនាវា ជាអាទិ៍ ( មាត្រា ១១៧៨ កថាខណ្ឌទី ៥) ។

### ៤. ចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍

មានតែចំណុច ដែលច្បាប់បានកំណត់ទេ ដែលអាចសរសេរក្នុងមតកសាសន៍បាន ។ ម្ចាស់បណ្តាំ ចង់សរសេរអ្វី ៗ ក្រៅពីចំណុចទាំងនេះក៏បានដែរ ក៏ប៉ុន្តែពុំមានអានុភាពតាមផ្លូវច្បាប់ឡើយ ។

បើសិនជាយើង បែងចែកទៅតាមលក្ខណៈពិសេសទៅ អាចមានដូចតទៅ ។

**- ទាក់ទងនឹងសន្តតិកម្ម**

**ក.** ការផ្តាច់មតិកពីជន ដែលត្រូវបានសន្មតថាជាសន្តតិជន និង ការលុបចោលនូវការផ្តាច់មតិកពីសន្តតិជន ( មាត្រា ១១៥១, មាត្រា ១១៥៣)

**ខ.** ការកំណត់ចំណែកមតិក ( មាត្រា ១១៨២)

**គ.** ការកំណត់នូវវិធីបែងចែកមតិក ( មាត្រា ១១៨៣)

**ឃ.** ការហាមឃាត់នូវការបែងចែកមតិក ( មាត្រា ១១៨៣)

**ង.** ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍ ( មាត្រា ១១៨៦)

**- ការចាត់ចែងទ្រព្យសម្បត្តិ**

**ក.** អច្ច័យទានសកល អច្ច័យទានពិសេស ( មាត្រា ១១៨៤)

**ខ.** ការវិភាគទានទ្រព្យសម្បត្តិដើម្បីបង្កើតនីតិបុគ្គលមូលនិធិ ( មាត្រា ១១៣)

**- ទំនាក់ទំនងនឹងឋានៈបុគ្គល**

**ក.** ការទទួលស្គាល់ ( មាត្រា ៩៩៧)

**ខ.** ការកំណត់អ្នកអាណាព្យាបាល ( មាត្រា ១០៦៨)

## ៥. ការលុបចោលនូវមតកសាសន៍

ម្ចាស់បណ្តាំ អាចលុបចោលនូវមតកសាសន៍នៅពេលណាក៏បានដែរ ក៏ប៉ុន្តែ ស្តីពីការលុបចោលនូវមតកសាសន៍នេះ គឺជាបញ្ហាក្រោយពេលទទួលមរណភាព ហេតុនេះហើយ ដើម្បីការពារកុំឱ្យមានវិវាទពេលក្រោយ ការលុបចោលមតកសាសន៍ ត្រូវធ្វើតាមវិធីដែលចែងដោយក្រមរដ្ឋប្បវេណី ( មាត្រា ១១៨៨) ។

ស្តីពីការលុបចោលនូវមតកសាសន៍ អាចបែងចែកជាពីរប្រភេទ ។

- ការលុបចោលដោយមតកសាសន៍ ( មាត្រា ១១៨៩ កថាខណ្ឌទី ១)

- ការលុបចោល ដែលច្បាប់បានកំណត់ (ក្នុងករណីដែលបានប្រព្រឹត្តអំពើកំណត់មួយចំនួន ដែលផ្ទុយនឹងមតកសាសន៍មុន = ការលុបចោលដែលច្បាប់កំណត់) ( មាត្រា ១១៨៩ កថាខណ្ឌទី ២, មាត្រា ១១៩០, មាត្រា ១១៩១) ។

### ៥.១ ការលុបចោលដោយមតកសាសន៍ ( មាត្រា ១១៨៩ កថាខណ្ឌទី ១)

ក្នុងករណីដែលបានធ្វើមតកសាសន៍ជាថ្មី ដែលមានខ្លឹមសារថា "លុបចោលនូវមតកសាសន៍ ដែលបានធ្វើនៅថ្ងៃទី ០ ខែ ០ ឆ្នាំ ០" គឺជាការលុបចោលដោយមតកសាសន៍ ។

### ៥.២ ការលុបចោលដែលច្បាប់កំណត់

ក្នុងករណីដែលម្ចាស់បណ្តាំ បានធ្វើសកម្មភាពផ្ទុយនឹងមតកសាសន៍មុន អាចមានករណីដែលត្រូវបានចាត់ទុកថា បានលុបចោលដោយស្វ័យប្រវត្តិនូវមតកសាសន៍មុន ។

ក្នុងករណីដែលមតកសាសន៍ក្រោយមានភាពផ្ទុយនឹងមតកសាសន៍មុន ( មាត្រា ១០៨៩ កថាខណ្ឌទី ២)

ក្នុងករណីដែលមតកសាសន៍មុន និង មតកសាសន៍ក្រោយ មានភាពផ្ទុយគ្នា ទោះជាមិនបានបង្ហាញឆន្ទៈលុបចោលមតកសាសន៍ក៏ដោយ ក៏ត្រូវចាត់ទុកថា បានលុបចោលនូវភាគដែលមានភាពផ្ទុយនោះ ក្នុងមតកសាសន៍មុន ។

ឧទាហរណ៍ ដូចករណីខាងក្រោមនេះ

មតកសាសន៍មុន : "ឱ្យ **ក** ទទួលដោយសន្តតិកម្ម នូវទ្រព្យសម្បត្តិទាំងអស់ (ដី, ប្រាក់បញ្ញើនៅធនាគារ, ទ្រព្យផ្សេងទៀត)"

មតកសាសន៍ក្រោយ : "ឱ្យ **ក** ទទួលដោយសន្តតិកម្មនូវដីទាំងអស់, ឱ្យ **ខ** ទទួលសន្តតិកម្មនូវប្រាក់បញ្ញើនៅធនាគារទាំងអស់, ឱ្យ **គ** ទទួលដោយសន្តតិកម្មនូវទ្រព្យក្រៅពីនេះ" ។

ក្នុងករណីនេះ ត្រូវចាត់ទុកថា "ឱ្យ **ក** ទទួលដោយសន្តតិកម្មនូវប្រាក់បញ្ញើធនាគារ និង ទ្រព្យផ្សេងទៀត" ក្នុងមតកសាសន៍មុន ត្រូវបានលុបចោល ។

ស្តីពីវត្ថុ ដែលជាកម្មវត្ថុនៃមតកសាសនី បើសិនជាម្ចាស់បណ្តាំបានធ្វើអនុប្បទាន ឬ បានធ្វើសកម្មភាពផ្សេងទៀត ( មាត្រា ១០៩០) ។

ស្តីពីវត្ថុ ដែលជាកម្មវត្ថុនៃមតកសាសនី បើសិនជាម្ចាស់បណ្តាំបានធ្វើអនុប្បទាន ឬ បានធ្វើសកម្មភាពផ្សេងទៀត ត្រូវបានចាត់ទុកថា ស្តីពីភាគដែលផ្ទុយនឹងមតកសាសនី ត្រូវបានលុបចោល ។

ឧទាហរណ៍ ម្ចាស់បណ្តាំ បានសរសេរក្នុងមតកសាសនីថា "ឱ្យ **ក** ធ្វើសន្តតិកម្មដី **ខ**" ក៏ប៉ុន្តែ បើសិនជាម្ចាស់បណ្តាំ បានលក់ដីនោះបាត់ទៅពេលគាត់នៅរស់ ត្រូវចាត់ទុកថា គាត់បានលុបចោលនូវមតកសាសនីពាក់ព័ន្ធនឹងផ្នែកនោះ ។

※ ក្នុងករណីនេះ ស្តីពីថ្លៃលក់ដីនោះ តើគប្បីឱ្យ **ក** ធ្វើសន្តតិកម្ម ឬ ក៏ត្រូវបែងចែកទៅតាមចំណែកសន្តតិកម្ម ដែលច្បាប់កំណត់ ឬ យ៉ាងណាដែរ គឺអាចជាបញ្ហា ( សូមមើលការបកស្រាយនៃមាត្រានីមួយ ៗ)

ការបដិសេធចោលនូវមតកសាសនី ជាអាទិ៍ ( មាត្រា ១១៩១)

បើសិនជាម្ចាស់បណ្តាំ បានបំផ្លាញចោលនូវច្បាប់ដើមនៃមតកសាសនី ឬ វត្ថុដែលជាកម្មវត្ថុនៃមតកសាសនីនោះ ដោយចេតនា ត្រូវចាត់ទុកថា ម្ចាស់បណ្តាំ បានលុបចោលនូវផ្នែកដែលត្រូវបានបំផ្លាយនោះ ។

## ៥.៣ អានុភាពនៃការលុបចោល

បើសិនជាមតកសាសនី ត្រូវបានលុបចោល ត្រូវចាត់ទុកថា មតកសាសនីនោះ ពុំមានតាំងពីដំបូងមក ។

※ ក្នុងករណីដែលបានលុបចោលនូវ "ការលុបចោលមតកសាសនី" តាមវិធីនៃមតកសាសនី នៅជប៉ុន គេមិនយកមតកសាសនីនោះមកធ្វើជាការវិញទេ តែក្នុងក្រមកម្ពុជា ពុំមានបញ្ញត្តិណាចែងឡើ តើគប្បីគិតយ៉ាងណាដែរ?

# ៦. អានុភាពនៃមតកសាសនី

## ៦.១ អានុភាពនៃមតកសាសនី

មតកសាសនី ត្រូវបង្កើតអានុភាពចាប់ពីពេលដែលម្ចាស់បណ្តាំ បានទទួលមរណភាព ( មាត្រា ១១៩៤ កថាខណ្ឌទី ១) ។

ក្នុងករណីដែលមតកសាសនីភ្ជាប់ជាមួយនឹងលក្ខខណ្ឌបង្អង់ បើលក្ខខណ្ឌនោះ ត្រូវបានបំពេញ នៅក្រោយពេលដែលម្ចាស់បណ្តាំ បានទទួលមរណភាព មតកសាសនីនោះ ត្រូវមានអានុភាពចាប់ពីពេលដែលលក្ខខណ្ឌនោះត្រូវបានបំពេញ ( មាត្រា ១១៩៤ កថាខណ្ឌទី ២) ។

ឧទាហរណ៍ ក្នុងករណីដែលឪពុក បានធ្វើអច្ច័យទានដី ដែលមានភ្ជាប់នឹងអាគារ ទៅឱ្យកូនស្រីរបស់គាត់ ដោយមានលក្ខខណ្ឌថា "ពេលកូនស្រីបានរៀបអាពាហ៍ពិពាហ៍" ដូច្នេះ មតកសាសន៍នេះ នឹងមានអានុភាព នៅពេល ដែលកូនស្រីគាត់ បានរៀបអាពាហ៍ពិពាហ៍ ។

## ៦.២ មោឃភាព និង ការលុបចោលនូវមតកសាសន៍

ក្នុងករណីដែលមតកសាសន៍ ត្រូវបានធ្វើមិនត្រឹមត្រូវនឹងទម្រង់ (មាត្រា ១១៧០ កថាខណ្ឌទី ២) (មាត្រា ១១៦៩ កថាខណ្ឌទី ១) ឬ ក្នុងករណីដែលម្ចាស់បណ្ដាំ ពុំមានសមត្ថភាពនាពេលធ្វើមតកសាសន៍ (មាត្រា ៣៩៧) ឬ ក្នុងករណីដែលខ្លឹមសារនៃមតកសាសន៍នោះ ផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និង ទំនៀមទំលាប់ល្អ មតកសាសន៍នោះ នឹងគ្មានសុពលភាពទេ ។

ម្យ៉ាងទៀត ក្នុងករណីដែលមតកសាសន៍ ត្រូវបានធ្វើឡើងដោយមានការភាន់ច្រឡំ (មាត្រា ៣៤៦) ឬ ដោយការឆបោក (មាត្រា ៣៤៧) ឬ ដោយការគំរាមកំហែង (មាត្រា ៣៥០) អាចលុបចោលបាន ។

# ៧. អច្ច័យទាន

## ៧.១ អត្ថន័យ លក្ខណៈពិសេស ពេលវេលាបង្កើតអានុភាព

អច្ច័យទាន គឺជាប្រទានកម្មដែលម្ចាស់បណ្ដាំបានធ្វើទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ នូវទ្រព្យសម្បត្តិរបស់ខ្លួន តាមរយៈមតកសាសន៍ ។

អ្នកទទួលអច្ច័យទាន គេ ហៅថា "អច្ច័យលាភី" ។

អច្ច័យទាន គឺជារបបមួយប្រហាក់ប្រហែលនឹងប្រទានកម្មដែរ ក៏ប៉ុន្តែ អច្ច័យទាន គឺជាការផ្ទេរទ្រព្យសម្បត្តិតាមរយៈសកម្មភាពឯកតោភាគីរបស់ម្ចាស់បណ្ដាំ ដូច្នេះ ខុសគ្នានឹងប្រទានកម្ម ដែលជាការផ្ទេរទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យា ។

អច្ច័យទាន មានពីរប្រភេទ គឺ :

- អច្ច័យទាន ដែលជាប្រទានកម្មនូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយភាគដោយកំណត់ទៅតាមភាគ (អច្ច័យទានសកល)

- អច្ច័យទាន ដែលជាប្រទានកម្មនូវទ្រព្យសម្បត្តិពិសេស (អច្ច័យទានពិសេស)

អ្នកទទួលអច្ច័យទានសកល (=អច្ច័យលាភីសាកល) មានសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងសន្តតិជន (មាត្រា ១២១២) ។

អច្ច័យទាន គឺជាសន្តតិកម្មមួយបែប ហេតុនេះហើយ អច្ច័យទាននឹងបង្កើតអានុភាពចាប់ពីពេល ដែលម្ចាស់បណ្ដាំ បានទទួលមរណភាព (មាត្រា ១១៩៤) ។

## ៧.២ ស្តីពីអច្ច័យលាភី

បើសិនជាអច្ច័យលាភី បានទទួលមរណភាព នៅមុនពេលដែលម្ចាស់បណ្តាំ ទទួលមរណភាព អច្ច័យទាន ពុំបង្កើតអានុភាពឡើយ ( មាត្រា ១២០០ កថាខណ្ឌទី ១) ។

ម្យ៉ាងទៀត ចំពោះទារក ដែលនៅក្នុងគភ៌ នៅពេលម្ចាស់បណ្តាំ ទទួលមរណភាព បើទារកនោះ មានកំណើតនៅពេលក្រោយ អាចទទួលនូវអានុភាពនៃបណ្តាំនោះបាន ( មាត្រា ៩ កថាខណ្ឌទី ៣) ។ ហេតុនេះហើយ ក៏អាចជាមុខសញ្ញានៃអច្ច័យទានដែរ ។

## ៧.៣ ការបោះបង់ ការទទួលស្គាល់នូវអច្ច័យទាន ជាអាទិ៍

អច្ច័យទាន គឺជាការផ្ទេរទ្រព្យសម្បត្តិតាមរយៈសកម្មភាពឯកតោភាគីរបស់ម្ចាស់បណ្តាំ ដូច្នេះ ត្រូវបង្កើតអានុភាពចាប់ពីពេលដែលម្ចាស់បណ្តាំ បានទទួលមរណភាព ដោយគ្មានពាក់ព័ន្ធនឹងឆន្ទៈរបស់អច្ច័យលាភីទេ។ ក៏ប៉ុន្តែ មិនអាចបង្ខំអច្ច័យលាភីបានទេ ម្ល៉ោះហើយ អច្ច័យលាភី អាចបោះបង់អច្ច័យទានបាន ( មាត្រា ១២០១) ។

ស្តីពីការបោះបង់ចោលនូវអច្ច័យទានសកល ត្រូវអនុលោមតាមបញ្ញត្តិស្តីពីការបោះបង់សន្តតិកម្ម ( មាត្រា ១២០១ កថាខណ្ឌទី ១) ។

※ ស្តីពីការបោះបង់អច្ច័យទានពិសេស ពុំមានបញ្ញត្តិណាមួយចែងទេ ក៏ប៉ុន្តែ នៅជប៉ុន យោងតាមករណីយុត្តិសាស្ត្រ សន្តតិជន អាចបង្ហាញឆន្ទៈបោះបង់ចោលបាន ។

ក្នុងករណីដែលបានបោះបង់អច្ច័យទាន ត្រូវមានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលម្ចាស់បណ្តាំ បានទទួលមរណភាព។

អច្ច័យលាភី អាចបោះបង់អច្ច័យទានពេលណាក៏បានដែរ ។ ក៏ប៉ុន្តែ បើធ្វើអីចឹងទៅ មតិកនោះ មិនដឹងជាធ្លាក់ទៅលើអ្នកណាច្បាស់លាស់ ដូច្នេះ គឺជាស្ថានភាពមិនល្អទេ ។ ម្ល៉ោះហើយ បុគ្គល ដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន (សន្តតិជន ជាដើម) ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាស់តឿនឱ្យអច្ច័យលាភីទទួលស្គាល់ ឬ បោះបង់អច្ច័យទានបាន ដោយកំណត់អំឡុងពេលសមរម្យ ( មាត្រា ១២០២) ។ បើសិនជាអច្ច័យលាភី មិនបានបង្ហាញឆន្ទៈ នៅក្នុងអំឡុងពេលដែលបានកំណត់នោះទេ ត្រូវចាត់ទុកថា អច្ច័យលាភី បានទទួលស្គាល់អច្ច័យទាននោះ ។

## ៧.៤ អច្ច័យទានដែលភ្ជាប់បន្ទុក ( មាត្រា ១២១១)

អច្ច័យទានដែលភ្ជាប់បន្ទុក គឺជាអច្ច័យទាន ដែលតំរូវឱ្យអច្ច័យលាភីទទួលបន្ទុកនូវករណីយកិច្ចកំណត់មួយចំនួន ។

ឧទាហរណ៍ ម្ចាស់បណ្ដាំ ក បានទុកមតកសាសន៍មួយ ដែលមានខ្លឹមសារថា "ធ្វើអច្ច័យទានដីទៅឱ្យ ខ។ ក៏ប៉ុន្តែ ខ ត្រូវបង់ ១០០០ ដុល្លា ទៅអោយ គ"។

អច្ច័យលាភី ត្រូវទទួលខុសត្រូវក្នុងការអនុវត្តករណីយកិច្ច ត្រឹមកំរិត ដែលមិនលើសពីតំលៃនៃវត្ថុ ដែលជាកម្មវត្ថុនៃអច្ច័យទាន។

ឧទាហរណ៍ ក្នុងករណីខាងលើនេះ ប្រសិនជាដីនោះ មានតំលៃ ៨០០ ដុល្លា អច្ច័យលាភី អាចបង់ ៨០០ ដុល្លា ហើយធ្វើលទ្ធកម្មដីនោះបាន។

## ៤. ការអនុវត្តមតកសាសន៍

### ៤.១ អត្ថន័យនៃការអនុវត្តមតកសាសន៍

ការអនុវត្តមតកសាសន៍ គឺជាការចាត់ចែងដែលចាំបាច់ ដើម្បីសំរេចនូវខ្លឹមសារនៃមតកសាសន៍នោះ ក្រោយពេលដែលអានុភាពនៃមតកសាសន៍នោះ បានកើតឡើង។

អាចមានមតកសាសន៍ ដែលពុំមាននីតិវិធីពិសេស (ឧទាហរណ៍ ការកំណត់នូវចំណែកមតិក ការហាមនូវការបែងចែកមតិក ជាដើម)។

ក៏ប៉ុន្តែ ទោះជាអានុភាពនៃមតកសាសន៍ កើតមានឡើងក៏ដោយ ភាគច្រើន ទាល់តែធ្វើនីតិវិធី ចាំបាច់ ទើបអាចសំរេចនូវខ្លឹមសារនៃមតកសាសន៍នោះបាន។

ហេតុនេះហើយ ក្រមរដ្ឋប្បវេណី មានបញ្ញត្តិចែងស្ដីពីនីតិវិធីនៃការអនុវត្តមតកសាសន៍។

### ៤.២ នីតិវិធីត្រៀមដើម្បីអនុវត្តមតកសាសន៍ ( ការពិនិត្យបញ្ជាក់ និង ការបើកលិខិតមតកសាសន៍) ( មាត្រា ១២១៣)

ស្ដីពីមតកសាសន៍ ក្រៅពីមតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើការពិនិត្យបញ្ជាក់នូវមតកសាសន៍នោះ។

អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ត្រូវដាក់ពាក្យសុំការបញ្ជាក់លិខិតនោះ ដោយភ្ជាប់លិខិតមតកសាសន៍នោះ ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ក្រោយពីខ្លួនបានដឹងអំពីការចាប់ផ្ដើមសន្តតិកម្ម។

ការពិនិត្យបញ្ជាក់ គឺជានីតិវិធីពិនិត្យមើលអំពីទំរង់ ឬ រូបរាងផ្សេងៗ នៃមតកសាសន៍ ដើម្បីការពារនូវការធ្វើក្លែងក្លាយ ឬ ក្លែងបន្លំនៅពេលក្រោយ ព្រមទាំងរក្សាទុកឱ្យបានត្រឹមត្រូវ ក្នុងគោលបំណងធានានូវឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្ដាំ។

ក្នុងករណី ដែលបានបើកលិខិតមតកសាសន៍ ដោយមិនបានធ្វើការពិនិត្យបញ្ជាក់ ត្រូវពិន័យជាប្រាក់ មិនលើសពី ១ លានរៀល។

ទោះជាមិនបានពិនិត្យបញ្ជាក់ក៏ដោយ ក៏មិនមែនមានន័យថា លិខិតមតកសាសន៍នោះ គ្មានសុពលភាពទេ។

## ៤.៣ ការប្រតិបត្តិមតកសាសន៍ និង អ្នកប្រតិបត្តិមតកសាសន៍

### ៤.៣.១ ការកំណត់ និង ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍

#### ៤.៣.១.១ ជនប្រតិបត្តិមតកសាសន៍ ដែលត្រូវបានកំណត់ ( មាត្រា ១២១៤)

ម្ចាស់បណ្តាំ អាចកំណត់អ្នកប្រតិបត្តិមតកសាសន៍បាន តាមមតកសាសន៍។ ម្យ៉ាងទៀត ម្ចាស់បណ្តាំ ក៏អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិនោះក៏បានដែរ ( មាត្រា ១២១៤ កថាខណ្ឌទី ១) ។

ជនដែលបានទទួលអាណត្តិ ត្រូវកំណត់អ្នកប្រតិបត្តិមតកសាសន៍ ហើយ ត្រូវជូនដំណឹងនោះទៅអោយសន្តតិជន ដោយគ្មានការយឺតយ៉ាវ ( មាត្រា ១២១៤ កថាខណ្ឌទី ១) ។

ជន ដែលត្រូវបានកំណត់ជាអ្នកប្រតិបត្តិមតកសាសន៍ អាចទទួល ឬ អាចប្រកែកមិនទទួល ដោយសេរីបាន។ ក៏ប៉ុន្តែបើសិនជាអ្នកប្រតិបត្តិមតកសាសន៍ បានយល់ព្រមកាន់មុខងារហើយ អ្នកប្រតិបត្តិមតកសាសន៍នោះត្រូវអនុវត្តភារកិច្ចនោះភ្លាម ៗ ( មាត្រា ១២១៥) ។

បើសិនជាជន ដែលត្រូវបានកំណត់ជាអ្នកប្រតិបត្តិមតកសាសន៍ មិនសំរេចថាទទួល ឬ មិនទទួលទេនោះនឹងធ្វើឱ្យទំនាក់ទំនងគតិយុត្តិអស្ថេរភាព។ ក្នុងករណីនេះ សន្តតិជន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត អាចកំណត់អំឡុងពេលសមរម្យ និង ដាស់តឿនចំពោះជនដែលត្រូវបានកំណត់ជាអ្នកប្រតិបត្តិមតកសាសន៍ឱ្យឆ្លើយបញ្ជាក់ច្បាស់ក្នុងអំឡុងពេលនោះ អំពីការយល់ព្រម ឬ មិនយល់ព្រមកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍បាន ( មាត្រា ១២១៦ កថាខណ្ឌទី ១) ។ បើសិនជាអ្នកប្រតិបត្តិមតកសាសន៍ មិនបានឆ្លើយបញ្ជាក់ច្បាស់ក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា បានប្រកែកមិនទទួលការងារនោះ ( មាត្រា ១២១៦ កថាខណ្ឌទី ១) ។

#### ៤.៣.១.២ ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ ( មាត្រា ១២១៨)

បើគ្មានអ្នកប្រតិបត្តិមតកសាសន៍ទេ ឬ បើបាត់បង់អ្នកប្រតិបត្តិមតកសាសន៍ តុលាការ អាចជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍បាន តាមការទាមទាររបស់សន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍។

### ៤.៣.២ មុខនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិ និង ករណីយកិច្ចក្នុងការគ្រប់គ្រងមតិក និង ធ្វើនូវរាល់សកម្មភាពផ្សេងទៀត ដែលចាំបាច់ ដើម្បីប្រតិបត្តិមតកសាសន៍ ( មាត្រា ១២២០) ។

### ៤.៣.២.១ ការចាប់ផ្ដើមបំពេញការងារ

អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ហើយ ប្រគល់បញ្ជីសារពើភ័ណ្ឌនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ( មាត្រា ១២១៩) ។

ម្យ៉ាងទៀត ក្នុងករណីដែលខ្លឹមសារនៃមតកសាសន៍ មានការពាក់ព័ន្ធតែនឹងទ្រព្យសម្បត្តិ ដែលបានកំណត់ជាក់លាក់ (=ទ្រព្យសម្បត្តិពិសេស) មិនមែននឹងទ្រព្យសម្បត្តិទាំងអស់ទេ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើតែបញ្ជីសារពើភ័ណ្ឌស្ដីពីទ្រព្យសម្បត្តិពិសេសនោះប៉ុណ្ណោះ (សូមមើលមាត្រា ១២២២) ។

### ៤.៣.២.២ សកម្មភាពគ្រប់គ្រង និង អនុវត្ត

អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិ និង កាតព្វកិច្ចធ្វើសកម្មភាពអ្វីៗ ទាំងអស់ដែលចាំបាច់សំរាប់អនុវត្តមតកសាសន៍។ ឧទាហរណ៍ ការសងបំណុល ដែលជាមតិកអកម្ម ការទទួលនូវសំណង ការទទួលនូវលក្ខខណ្ឌតតាំងតាមរយៈការចុះបញ្ជី ឬ ការទទួលនូវការប្រគល់វត្ថុដែលជាកម្មវត្ថុ ជាដើម។

### ៤.៣.២.៣ ការហាមឃាត់សិទ្ធិចាត់ចែងរបស់សន្តតិជន ( មាត្រា ១២២១)

ទ្រព្យសម្បត្តិសន្តតិកម្ម ត្រូវធ្លាក់ទៅលើសន្តតិជន ចាប់ពីពេលដែលចាប់ផ្ដើមសន្តតិកម្ម ( មាត្រា ១១៤៧ កថាខណ្ឌទី ១) ។

ក៏ប៉ុន្តែ ក្នុងករណី ដែលមានអ្នកប្រតិបត្តិមតកសាសន៍ បើសិនឱ្យសន្តតិជន អាចចាត់ចែងទ្រព្យសម្បត្តិសន្តតិកម្ម នឹងធ្វើអោយអ្នកប្រតិបត្តិមតកសាសន៍ ពុំមានដំណើរការ ។

ហេតុនេះហើយ ក្នុងករណីដែលមានអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជន ពុំមានសិទ្ធិចាត់ចែងទ្រព្យសម្បត្តិសន្តតិកម្មទេ ( មាត្រា ១២២១) ។ ការចាត់ចែងរបស់សន្តតិជន ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនេះ ត្រូវចាត់ទុកជាមោឃៈ ។

### ៤.៣.២.៤ ឋានៈ សិទ្ធិជ្រើសតាំងបន្ត កម្រៃ ជាអាទិ៍ របស់អ្នកប្រតិបត្តិដែលត្រូវបានកំណត់

អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើសកម្មភាពក្នុងនាមជាអ្នកប្រតិបត្តិមតកសាសន៍ ចំពោះមតិកដែលខ្លួនត្រូវប្រតិបត្តិ ហើយសកម្មភាពនោះ នឹងបង្កើតអានុភាពដោយផ្ទាល់ចំពោះសន្តតិជន ( មាត្រា ១២២៣) ។ មានន័យថា ធ្វើសកម្មភាពក្នុងនាម "B អ្នកប្រតិបត្តិមតកសាសន៍របស់មតកជន A" ។

ឋានៈតាមផ្លូវច្បាប់របស់អ្នកប្រតិបត្តិមតកសាសន៍ គឺដូចគ្នានឹងអ្នកតំណាង ដែលបានទទួលនូវការអាណត្តិរបស់សន្តតិជនដែរ ។

ក្រៅពីនេះ មានបញ្ញត្តិដូចតទៅ :

- សិទ្ធិជ្រើសតាំងបន្ត (សិទ្ធិអំណាចរបស់អ្នកប្រតិបត្តិមតកសាសន៍ ក្នុងការអោយតតិយជនបំពេញភារកិច្ច នោះ) ( មាត្រា ១២២៤)

បើគ្មានមូលហេតុ ដែលពុំអាចជៀសវាងបាន អ្នកប្រតិបត្តិមតកសាសន៍ ពុំអាចឱ្យតតិយជនអនុវត្ត ភារកិច្ចរបស់ខ្លួនបានឡើយ ។ បញ្ញត្តិនេះ ដូចគ្នានឹងបញ្ញត្តិស្តីពីការជ្រើសតាំងអនុតំណាង ក្នុងរបប តំណាងដែរ ( មាត្រា ៣៧៦) ។

- កំរៃ ( មាត្រា ១២២៦)

អ្នកប្រតិបត្តិមតកសាសន៍ អាចទទួលកម្រៃដែលបានកំណត់នៅក្នុងមតកសាសន៍បាន ។ ក្នុងករណី ដែលមតកសាសន៍ ពុំបានកំណត់កំរៃទេ តុលាការ អាចកំណត់ចំនួនទឹកប្រាក់នៃកំរៃនោះ បើយល់ ឃើញថា សមរម្យក្នុងការបង់កំរៃ

- សោហ៊ុយ ( មាត្រា ១២២៨)

សោហ៊ុយ ដែលទាក់ទងទៅនឹងការប្រតិបត្តិមតកសាសន៍ ត្រូវជាបន្ទុកនៃមតិក ។

- ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីអាណត្តិ ( មាត្រា ១២២៩)

ដោយសារភាពប្រហាក់ប្រហែលគ្នានៃឋានៈតាមផ្លូវច្បាប់ ត្រូវយកបញ្ញត្តិស្តីពីអាណត្តិមកអនុវត្ត

### ៤.៣.២.៥ ការបញ្ចប់ភារកិច្ច

ភារកិច្ចរបស់អ្នកប្រតិបត្តិមតកសាសន៍ ត្រូវបញ្ចប់នៅពេលដែលបានបញ្ចប់ការអនុវត្តមតកសាសន៍ ។

**ឧទាហរណ៍នៃមតកសាសន៍**

**១. ករណីឱ្យប្រពន្ធធ្វើសន្តតិកម្មទាំងអស់ ( មតកសាសន៍ដោយលិខិតឯកជន)**

| |
|---|
| មតកសាសន៍<br>ម្ចាស់បណ្តាំឱ្យប្រពន្ធឈ្មោះ A ( កើតនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៨០) ធ្វើសន្តតិកម្មនូវទ្រព្យសម្បត្តិទាំង អស់ដែលម្ចាស់បណ្តាំមាន ។<br>ធ្វើនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១២<br>អាស័យដ្ឋាន 00000<br>ម្ចាស់បណ្តាំ B<br>ត្រា |

※ ម្ចាស់បណ្តាំ ត្រូវសរសេរដោយដៃខ្លួនឯង ហើយ ត្រូវចុះថ្ងៃខែឆ្នាំ

**២. ករណីឱ្យប្រពន្ធ និង កូនធ្វើសន្តតិកម្មនូវទ្រព្យពិសេស ( មតកសាសន៍ដោយលិខិតឯកជន)**

មតកសាសន៍

ប្រការទី ១ ម្ចាស់បណ្តាំ អោយប្រពន្ធឈ្មោះ A ( កើតនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៨០) ធ្វើសន្តតិកម្មនូវអចលនវត្ថុខាងក្រោមនេះ ដែលជាកម្មសិទ្ធិរបស់ម្ចាស់បណ្តាំ ។

ទីតាំង ខេត្ត 00 ស្រុក 00 ឃុំ 00 ភូមិ 00

លេខឡូ 00-00

ប្រភេទដី សំរាប់លំនៅឋាន

ទំហំដី ២00 $m^2$

ប្រការទី ២ ម្ចាស់បណ្តាំ ឱ្យកូនស្រីច្បង ឈ្មោះ C ( កើតនៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ២000) ធ្វើសន្តតិកម្មនូវសិទ្ធិលើបំណុល ដែលជាប្រាក់បញ្ញើនៅធនាគារ "ក" ។

គណនីសន្សំធម្មតា

លេខកូដ ១២៣៤៥

គណនីលេខ ១២៣៤៥៦៧៨៩០

ប្រការទី ៣ ម្ចាស់បណ្តាំឱ្យកូនប្រុសច្បងឈ្មោះ D ( កើតនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២00៥) ធ្វើសន្តតិកម្មនូវអចលនវត្ថុ និង ប្រាក់បញ្ញើនៅធនាគារ និង ប្រាក់ទាំងអស់ ដែលម្ចាស់បណ្តាំមាន លើកលែងតែទ្រព្យសម្បត្តិដែលមានចុះក្នុងប្រការទី ១ និង ទី ២ ខាងលើនេះ ។

ធ្វើនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១២

អាស័យដ្ឋាន 00000

ម្ចាស់បណ្តាំ B

ត្រា

※ ម្ចាស់បណ្តាំ ត្រូវសរសេរដោយដៃខ្លួនឯង ហើយ ត្រូវចុះថ្ងៃខែឆ្នាំ ។

**៣. ករណីកំណត់ចំណែកមតិក ( មតកសាសន៍ដោយលិខិតឯកជន)**

| |
|---|
| មតកសាសន៍<br>ម្ចាស់បណ្តាំ អោយប្រពន្ធឈ្មោះ A ( កើតនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៨០) កូនស្រីច្បងឈ្មោះ C ( កើតនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០០) និង កូនប្រុសច្បងឈ្មោះ D ( កើតនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៥) ធ្វើសន្តតិកម្មនូវប្រាក់បញ្ញើនៅធនាគារ និង ទ្រព្យសម្បត្តិអ្វីៗ ទាំងអស់ ដែលម្ចាស់បណ្តាំមាន ម្នាក់មួយភាគបី ។<br>ធ្វើនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១២<br>អាស័យដ្ឋាន 00000<br>ម្ចាស់បណ្តាំ B<br>ត្រា |

※ ម្ចាស់បណ្តាំ ត្រូវសរសេរដោយដៃខ្លួនឯង ហើយ ត្រូវចុះថ្ងៃខែឆ្នាំ ។

※ ដើម្បីជៀសវាងនូវវិវាទនាពេលក្រោយ ស្តីពីអចលនវត្ថុ គប្បីឱ្យអ្នកណាតែម្នាក់ធ្វើសន្តតិកម្ម ជាការល្អ ។

### ៤. ករណីធ្វើអច្ច័យទានសកល ( មតកសាសន៍ដោយលិខិតឯកជន)

| |
|---|
| មតកសាសន៍<br>ម្ចាស់បណ្តាំ ធ្វើអច្ច័យទានសកល នូវទ្រព្យសម្បត្តិទាំងអស់របស់ខ្លួន ចំពោះជនខាងក្រោមនោះ :<br>អាស័យដ្ឋាន 000<br>អច្ច័យលាភី F ( កើតនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៧០)<br>ធ្វើនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១២<br>អាស័យដ្ឋាន 00000<br>ម្ចាស់បណ្តាំ B<br>ត្រា |

※ ម្ចាស់បណ្តាំ ត្រូវសរសេរដោយដៃខ្លួនឯង ហើយ ត្រូវចុះថ្ងៃខែឆ្នាំ ។

### ៥. ករណីធ្វើអច្ច័យទានពិសេស ( មតកសាសន៍ដោយលិខិតឯកជន)

មតកសាសន៍

ម្ចាស់បណ្ដាំ ធ្វើអច្ច័យទាននូវអចលនវត្ថុខាងក្រោមនេះ ចំពោះក្មួយស្រីឈ្មោះ F (កើតថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២000) ។

ទីតាំង ខេត្ត 00 ស្រុក 00 ឃុំ 00 ភូមិ 00

លេខឡូ 00-00

ប្រភេទដី សំរាប់លំនៅឋាន

ទំហំដី ៥00 $m^2$

ធ្វើនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១២

អាស័យដ្ឋាន 00000

ម្ចាស់បណ្ដាំ B

ត្រា

※ ម្ចាស់បណ្ដាំ ត្រូវសរសេរដោយដៃខ្លួនឯង ហើយ ត្រូវចុះថ្ងៃខែឆ្នាំ។

### ៦. ករណីធ្វើអច្ច័យទានដោយមានបន្ទុក (មតកសាសន៍ដោយលិខិតឯកជន)

មតកសាសន៍

ប្រការទី ១ ម្ចាស់បណ្ដាំ ធ្វើអច្ច័យទាននូវអចលនវត្ថុខាងក្រោមនេះ ចំពោះក្មួយស្រីឈ្មោះ F (កើតនៅថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២000) ។

ទីតាំង ខេត្ត 00 ស្រុក 00 ឃុំ 00 ភូមិ 00

លេខឡូ 00-00

ប្រភេទដី សំរាប់លំនៅឋាន

ទំហំដី ៥00 $m^2$

ប្រការទី ២ ក្នុងអំឡុងពេលដែលប្រពន្ធឈ្មោះ A របស់ម្ចាស់បណ្ដាំនៅរស់ អច្ច័យលាភី F ត្រូវឱ្យ A រស់នៅក្នុងអចលនវត្ថុនេះ ដោយមិនយកថ្លៃឈ្នួល ហើយ ត្រូវបង់ប្រាក់ ៣ ម៉ឺនយ៉េន ក្នុង ១ ខែ ដោយយកទៅឱ្យ A ដោយផ្ទាល់ដៃ នៅរាល់ចុងខែ។

ធ្វើនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១២

អាស័យដ្ឋាន 00000

ម្ចាស់បណ្តាំ B

ត្រា

※ ម្ចាស់បណ្តាំ ត្រូវសរសេរដោយដៃខ្លួនឯង ហើយ ត្រូវចុះថ្ងៃខែឆ្នាំ ។

**៧. ករណីហាមបែងចែកទ្រព្យសម្បត្តិ ( មតកសាសន៍ដោយលិខិតឯកជន)**

មតកសាសន៍

ម្ចាស់បណ្តាំ ហាមមិនអោយបែងចែកទ្រព្យសម្បត្តិទាំងអស់របស់ម្ចាស់បណ្តាំ ក្នុងអំឡុងពេលពេល ៥ ឆ្នាំ បន្ទាប់ពីពេលចាប់ផ្តើមសន្តតិកម្ម ។

ធ្វើនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១២

អាស័យដ្ឋាន 00000

ម្ចាស់បណ្តាំ B

ត្រា

※ ម្ចាស់បណ្តាំ ត្រូវសរសេរដោយដៃខ្លួនឯង ហើយ ត្រូវចុះថ្ងៃខែឆ្នាំ ។

**៨. ករណីមតកសាសន៍ទូទៅ ( មតកសាសន៍ដោយលិខិតឯកជន)**

មតកសាសន៍

ប្រការទី ១ ម្ចាស់បណ្តាំ អោយកូនស្រីច្បងឈ្មោះ C ( កើតនៅថ្ងៃទី 0 ខែ 0 ឆ្នាំ 0) កូនស្រីទីពីរឈ្មោះ D ( កើតនៅថ្ងៃទី 0 ខែ 0 ឆ្នាំ 0) កូនស្រីទីបីឈ្មោះ E ( កើតនៅថ្ងៃទី 0 ខែ 0 ឆ្នាំ 0) ធ្វើសន្តតិកម្ម នូវទឹកប្រាក់ពីប្រាក់បញ្ញើ ដែលម្ចាស់បណ្តាំមាននៅធនាគារ ម្នាក់ចំនួន ៣ លានយ៉េន ។

ប្រការទី ២ ម្ចាស់បណ្តាំ អោយឈ្មោះ G ( កើតនៅថ្ងៃទី 0 ខែ 0 ឆ្នាំ 0) ដែលជាប្រពន្ធរបស់កូនប្រុសច្បង F ធ្វើអច្ច័យទាននូវទឹកប្រាក់ចំនួន ៥ លាន យ៉េន ពីក្នុងប្រាក់បញ្ញើ ដែលម្ចាស់បណ្តាំមាននៅធនាគារ ។

ប្រការទី ៣ ម្ចាស់បណ្តាំ អោយកូនប្រុសច្បង ឈ្មោះ F ( កើតនៅថ្ងៃទី 0 ខែ 0 ឆ្នាំ 0) ធ្វើសន្តតិកម្មនូវអចលនវត្ថុ និង ទ្រព្យសម្បត្តិទាំងអស់ដែលម្ចាស់បណ្តាំមាន លើកលែងតែប្រាក់បូកសរុបចំនួន ១៤ លាន យ៉េន ដែលមានបញ្ជាក់ក្នុងប្រការទី ១ និង ទី ២ ខាងលើនេះ ។

ប្រការទី ៤ ម្ចាស់បណ្តាំ កំណត់អោយកូនប្រុសច្បង F ប្រតិបត្តិក្នុងនាមជាអ្នកប្រតិបត្តិមតកសាសន៍នេះ ។

បណ្តាំបន្ថែម គ្រួសារកូនប្រុសច្បង F ជាអ្នកគ្រប់គ្រងហាង ។ ហេតុនេះហើយ បានជាបានសំរេចមតកសាសន៍នេះ ។ កូនទាំងអស់ ត្រូវយល់នូវទឹកចិត្តរបស់ឪពុក ហើយ រួមរស់ដោយសុខដុមរមនា ជាមួយគ្នាទាំងអស់ ។

ធ្វើនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១២

អាស័យដ្ឋាន 00000

ម្ចាស់បណ្តាំ B

ត្រា

※ ម្ចាស់បណ្តាំ ត្រូវសរសេរដោយដៃខ្លួនឯង ហើយ ត្រូវចុះថ្ងៃខែឆ្នាំ។

**៩. ករណីឱ្យប្រពន្ធធ្វើសន្តតិកម្មទាំងអស់ ( មតកសាសន៍ដោយលិខិតយថាភូត)**

លិខិតយថាភូតនៃមតកសាសន៍

សារការី បានធ្វើលិខិតនេះទៅតាមសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំ តាមរយៈការអាណត្តិពីម្ចាស់បណ្តាំ ដោយមានវត្តមានសាក្សីឈ្មោះ B និង ឈ្មោះ C ។

ប្រការទី ១ ម្ចាស់បណ្តាំ បានអោយប្រពន្ធឈ្មោះ D (កើតនៅថ្ងៃទី 0 ខែ 0 ឆ្នាំ 0) ធ្វើសន្តតិកម្មនូវទ្រព្យសម្បត្តិទាំងអស់ដែលម្ចាស់បណ្តាំមាន ។

បន្ទាប់ពីបានអានអោយអ្នកទាំងអស់គ្នាស្តាប់ហើយ ឃើញថាត្រឹមត្រូវទាំងស្រុង ហេតុនេះហើយ អ្នកទាំងអស់គ្នាក៏បានចុះឈ្មោះ និង បោះត្រាខាងក្រោមនេះ ។

| | | |
|---|---|---|
| ម្ចាស់បណ្តាំ | A | ត្រា |
| សាក្សី | B | ត្រា |
| សាក្សី | C | ត្រា |

លិខិតនេះ ត្រូវបានធ្វើឡើងនៅការិយាល័យសារការីនេះ តាមទំរង់ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ហើយសារការី ដែលជាអ្នកធ្វើលិខិតនេះ បានបោះត្រាខាងក្រោមនេះ ។

អាស័យដ្ឋាន 000000000

ប្រចាំមន្ទីរនីត្យានុកូលដ្ឋាន 00000

សារការី 0000 ត្រា

※ សារការីជប៉ុន ធ្វើលិខិតយថាភូត តាមទំរង់នៃលិខិតយថាភូតជប៉ុន ហេតុនេះហើយ មិនដូចគ្នានឹង លិខិតយថាភូតកម្ពុជាទេ ។

※ ក្រៅពីភាគីដែលមានពណ៌ខៀវនៃមតកសាសន៍នេះ គេ មិនប្តូរតាមខ្លឹមសារមតកសាសន៍ទេ ។

# ផ្នែកទី ៣

## ភាគបំរុង

**សំណួរ ១ :** ហេតុអ្វីបានជាមានរបបភាគបំរុងនេះ ?

**ចំលើយ :** របបភាគបំរុង គឺជារបបធានាមួយភាគនូវចំណែកមតិកតាមច្បាប់ ចំពោះសន្តតិជន កំណត់ដោយច្បាប់ មួយចំនួន។ នេះ គឺអាចចាត់ទុកថា ជាការសំរបសម្រួលរវាងសន្តតិកម្មតាមមតកសាសន៍ និង សន្តតិកម្មតាមច្បាប់ ហើយមានមុខងារការពារសិទ្ធិ ដែលជនជាសាច់ញាតិក្នុងទំហំកំណត់មួយ ដែលអាចមាន។

ក្នុងករណីដែលមានអច្ច័យទាន ឬ មានការកំណត់នូវចំណែកមតិកដោយមតកសាសន៍ ឬ មានការទទួលផលប្រយោជន៍ពិសេស ឬ មានប្រទានកម្មកំណត់មួយចំនួននៅពេលនៅរស់ (មាត្រា ១២៣២) អាចមានការបំពាននូវភាគបំរុង។

**សំណួរ ២ :** តើអ្នកណា មានភាគបំរុងប៉ុន្មាន ?

**ចំលើយ :** អ្នកមានសិទ្ធិលើភាគបំរុង គឺមានដូចជា បច្ឆាញាតិផ្ទាល់ ឬ ឪពុកម្តាយ ឬ ជីដូនជីតា និង សហព័ទ្ធរបស់មតកជន (មាត្រា ១២៣០)។ រីឯ បងប្អូនរបស់មតកជន ពុំមានសិទ្ធិលើភាគបំរុងទេ។

ជាគោលការណ៍ ចំណែកនៃភាគបំរុង គឺមួយភាគពីរ នៃទ្រព្យសម្បត្តិរបស់មតកជន ក៏ប៉ុន្តែ បើសិនជាមានតែសន្តតិជន ជាឪពុកម្តាយ ឬ ជីដូនជីតា គឺមួយភាគបី នៃទ្រព្យសម្បត្តិរបស់មតកជន (មាត្រា ១២៣០ កថាខណ្ឌទី ១)។ បន្ទាប់មក ក្នុងករណីដែលអ្នកមានសិទ្ធិលើភាគបំរុង មានច្រើននាក់ អ្នកមានសិទ្ធិលើភាគបំរុងម្នាក់ៗ អាចទទួលភាគបំរុងតាមសមាមាត្រនៃចំណែកមតិកបាន (មាត្រា ១២៣០ កថាខណ្ឌទី ២)។

ឧទាហរណ៍ : ករណីដែលសន្តតិជន មានប្រពន្ធ និង កូនពីរនាក់

សមាមាត្រនៃភាគបំរុងរបស់ម្នាក់ៗ គឺ ១/២ x ១/៣ = ១/៦ នៃទ្រព្យសម្បត្តិរបស់មតកជន

**សំណួរ ៣ :** តើទ្រព្យសម្បត្តិដែលជាមូលដ្ឋាននៃការគណនាទឹកប្រាក់នៃភាគបំរុង មានអ្វីខ្លះ ?

**ចំលើយ :** ទ្រព្យសម្បត្តិដែលជាមូលដ្ឋាននៃការគណនាភាគបំរុង មិនមែនមានតែមតិកប៉ុណ្ណោះទេ។ ត្រូវបូកទ្រព្យសម្បត្តិសកម្ម ដែលមតកជនមាន នៅពេលចាប់ផ្តើមសន្តតិកម្ម និង ទឹកប្រាក់នៃផលប្រយោជន៍ពិសេស (មាត្រា ១១៦៣) និង ទឹកប្រាក់នៃទ្រព្យមួយចំនួននៃប្រទានកម្មនាពេលនៅរស់ (ដែលមិនមែនជាផលប្រយោជន៍ពិសេស) (មាត្រា ១២៣២) ដកនឹងបំណុល។

ឧទាហរណ៍ : ទ្រព្យសកម្មរបស់មតកជន មាន ៨០.០០០ ដុល្លា បំណុល មាន ៣០.០០០ ដុល្លា ផលប្រយោជន៍ពិសេសដែលសន្តតិជនបានទទួល ៥០.០០០ ដុល្លា

៨០,០០០ + ៥០,០០០ - ៣០,០០០ = ១០០,០០០

**សំណួរ ៤ :** តើមានទ្រព្យសម្បត្តិអ្វីខ្លះ ដែលជាកម្មវត្ថុនៃការកាត់បន្ថយនូវភាគបំរុង ?

**ចំលើយ :** ដើម្បីការពារភាគបំរុងរបស់អ្នកមានសិទ្ធិលើភាគបំរុង

- អច្ច័យទាន
- ការកំណត់ចំណែកមតិកតាមមតកសាសន៍
- ផលប្រយោជន៍ពិសេស
- ប្រទានកម្មមួយចំនួននាពេលនៅរស់ ( មាត្រា ១២៣២)

គឺជាកម្មវត្ថុនៃការកាត់បន្ថយនៃភាគបំរុង ( មាត្រា ១២៣៣) ។

វា មានន័យថា ក្នុងករណីដែលមានការបំពាននូវភាគបំរុង តាមរយៈសកម្មភាពទាំងនេះ របបភាគបំរុង បានធានានូវភាគបំរុង តាមរយៈការបដិសេធនូវអានុភាពនៃសកម្មភាពទាំងនេះ ។

**សំណួរ ៥ :** តើត្រូវគណនាយ៉ាងដូចម្តេចដែរ អំពីទឹកប្រាក់នៃការបំពានភាគបំរុងរបស់អ្នកមានសិទ្ធិលើភាគបំរុង ?

**ចំលើយ :** ត្រូវគណនា ដោយយកចំនួនទឹកប្រាក់នៃភាគបំរុង ដកនឹងចំនួនសរុបនៃទឹកប្រាក់នៃទ្រព្យសម្បត្តិ ដែលអ្នកមានសិទ្ធិលើភាគបំរុងបានទទួលដោយសន្តតិកម្ម និង ចំនួននៃផលប្រយោជន៍ពិសេស ហើយ បូកបញ្ចូលនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ច ដែលអ្នកមានសិទ្ធិលើភាគបំរុងនោះ បានទទួលបន្ទុកដោយសន្តតិកម្ម ( មាត្រា ១២៣០ កថាខណ្ឌទី ១) ( មាត្រា ១២៣៤) ។

បញ្ញត្តិនេះ មានការពិបាកយល់ ហេតុនេះហើយ សូមលើកយកឧទាហរណ៍នៃ**សំណួរ ១០** ជាអាទិ៍ ដើម្បីពន្យល់ឱ្យងាយស្រួលយល់ ។

**សំណួរ ៦ :** តើវិធីកាត់បន្ថយភាគបំរុង ជាវិធីយ៉ាងដូចម្តេចដែរ ? ក្នុងករណីនេះ តើមានអានុភាព ខាងផ្លូវច្បាប់យ៉ាងដូចម្តេចដែរ ?

**ចំលើយ :** ការកាត់បន្ថយភាគបំរុង គឺជាការដែលអ្នកមានសិទ្ធិលើភាគបំរុង ( ព្រមទាំងអ្នកទទួលបន្តនោះ) ទាមទារអោយកាត់បន្ថយនូវអច្ច័យទាន ការកំណត់ចំណែកមតិកតាមមតកសាសន៍ ផលប្រយោជន៍ពិសេស ប្រទានកម្មកំណត់មួយចំនួននាពេលមុនទទួលមរណភាព ( មាត្រា ១២៣២) ចំពោះ អ្នកដែលបានទទួលទ្រព្យសម្បត្តិ ឬ ផលប្រយោជន៍ ដែលជាកម្មវត្ថុនៃការកាត់បន្ថយភាគបំរុង ហើយ អានុភាពនឹងកើតមានឡើងតាមរយៈការទាមទារនេះ ( មាត្រា ១២៣៥) ។ មានន័យថា ទោះជាករណីដែលមានការបំពានភាគបំរុង ដោយឃើញជាក់

ច្បាស់ក៏ដោយ តែបើសិនជាអ្នកមានសិទ្ធិលើភាគបំរុង មិនបានអនុវត្តសិទ្ធិរបស់ខ្លួនទេ អច្ច័យទាន ជាអាទិ៍ មិនអាចក្លាយទៅជាមោឃៈបានឡើយ ។ ក្នុងការចាត់ចែងកិច្ចការជាក់ស្តែងរបស់ជប៉ុន ក្នុងករណីដែលមានពាក្យបណ្តាំឱ្យជនណាម្នាក់ក្នុងចំណោមសន្តតិជនច្រើននាក់ ធ្វើសន្តតិកម្មនូវទ្រព្យសម្បត្តិទាំងអស់ ជាអាទិ៍ ទោះជាករណីដែលអាចទាមទារឱ្យកាត់បន្ថយចំណែកមតិកក៏ដោយ ក៏មានករណីជាច្រើន ដែលគេ មិនទាមទារអោយកាត់បន្ថយទេ ។

ពេលដែលមានការទាមទារឱ្យកាត់បន្ថយនូវភាគបំរុង អច្ច័យទាន ជាអាទិ៍ ត្រូវបាត់បង់នូវអានុភាពត្រឹមកំរិតនៃការបំពានទៅលើភាគបំរុងនោះ ហើយ សិទ្ធិទៅលើភាគនោះ ត្រូវធ្លាក់ទៅលើអ្នកអនុវត្តសិទ្ធិទាមទារឱ្យកាត់បន្ថយភាគបំរុង ។

ក្រោមក្រមរដ្ឋប្បវេណីនេះ ស្តីពីការទាមទារឱ្យកាត់បន្ថយភាគបំរុងនេះ មិនតំរូវអោយដាក់ពាក្យបណ្តឹងទេ គឺគ្រាន់តែបង្ហាញឆន្ទៈក្រៅតុលាការបានហើយ ។ ចំណុចនេះ ដូចគ្នានឹងការរំលាយកិច្ចសន្យា ដោយសារការមិនអនុវត្តកាតព្វកិច្ចដែរ ( មាត្រា ៤០៩) ហើយនេះ គឺខុសគ្នានឹងប្រព័ន្ធមុនរបស់កម្ពុជា ។ ក៏ប៉ុន្តែ អាចបង្ហាញឆន្ទៈនេះតាមរយៈពាក្យបណ្តឹងដែរ ។

**សំណួរ ៧ :** ក្នុងករណីដែលមានអច្ច័យទាន ជាអាទិ៍ ច្រើន ដែលជាកម្មវត្ថុនៃការកាត់បន្ថយភាគបំរុង តើការកាត់បន្ថយនោះ មានលំដាប់ ឬ ទេ ?

**ចំលើយ :**

លំដាប់ទី ១ អច្ច័យទានចំពោះសន្តតិជន ឬ ការកំណត់ចំណែកតាមមតកសាសន៍ ( មាត្រា ១២៣៧)

លំដាប់ទី ២ អច្ច័យទាន ដែលបានធ្វើចំពោះបុគ្គលដែលមិនមែនជាសន្តតិជន ( មាត្រា ១២៣៧)
ស្តីពីចំណុចដែលមានលំដាប់ស្មើគ្នា ត្រូវកាត់បន្ថយនូវភាគបំរុង ទៅតាមសមាមាត្រនៃតំលៃនៃវត្ថុនោះដែរ ។

លំដាប់ទី ៣ ប្រទានកម្ម ឬ ផលប្រយោជន៍ពិសេស ( មាត្រា ១២៣៨)
ស្តីពីប្រទានកម្ម ផលប្រយោជន៍ពិសេស ត្រូវកាត់បន្ថយពីប្រទានកម្ម ឬផលប្រយោជន៍ពិសេស ដែលកើតឡើងក្រោយគេ ហើយបន្ទាប់មក ត្រូវគិតជាលំដាប់លំដោយនូវប្រទានកម្ម ឬ ផលប្រយោជន៍ពិសេសមុនជាបន្តបន្ទាប់ ។

**សំណួរ ៨ :** ក្នុងករណីដែលមានវិវាទពាក់ព័ន្ធនឹងការទាមទារឱ្យកាត់បន្ថយភាគបំរុង ដែលមានកម្មវត្ថុជាអច្ច័យទាន ជាដើមនៃដីធ្លី តើអាចដោះស្រាយជាប្រាក់បានដែរ ឬ ទេ ?

**ចំលើយ :** អ្នកមានកាតព្វកិច្ចនៃការទាមទារអោយកាត់បន្ថយភាគបំរុង អាចរួចផុតពីកាតព្វកិច្ចផ្តល់តាវកាលិកជាវត្ថុនោះបាន ដោយបង់សំណងជាប្រាក់ចំពោះអ្នកមានសិទ្ធិលើភាគបំរុងនោះបាន ។

ម្យ៉ាងទៀត អ្នកមានសិទ្ធិលើភាគបំរុង មិនអាចទាមទារនូវការបង់ជាប្រាក់ជំនួសវត្ថុ ដែលជាកម្មវត្ថុនៃការកាត់បន្ថយភាគបំរុងបានទេ។ ក៏ប៉ុន្តែ អ្នកមានសិទ្ធិលើភាគបំរុង អាចចរចារ ហើយ សះជាគ្នា តាមរយៈការដោះស្រាយដោយបង់ជាប្រាក់បាន។ នៅជប៉ុន រឿងក្តីពាក់ព័ន្ធនឹងភាគបំរុង មានការពិចារណាដោះស្រាយ ដោយសារតែវិវាទជាសារធាតុ គឺពាក់ព័ន្ធនឹងការទាមទារឱ្យកាត់បន្ថយភាគបំរុង តែដីធ្លី ជាអាទិ៍ ស្ថិតនៅក្នុងស្ថានភាពសហកម្មសិទ្ធិ ដូច្នេះ ភាគច្រើន គេតែងតែចរចារដោះស្រាយជាប្រាក់ទៅវិញ។

**សំណួរ ៩ :** តើអាចទាមទារឱ្យកាត់បន្ថយភាគបំរុងបានរហូតដល់ពេលណាដែរ ?

**ចំលើយ :** សិទ្ធិទាមទារឱ្យកាត់បន្ថយ ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ១ ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបំរុង បានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម និង ការកំណត់ចំណែកមតិក អច្ច័យទាន ប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេស ដែលត្រូវកាត់បន្ថយ។ ម្យ៉ាងទៀត សិទ្ធិទាមទារអោយកាត់បន្ថយ ក៏ត្រូវរលត់ដោយអាជ្ញាយុកាលបើអំឡុងពេល ៥ ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម (មាត្រា ១២៤៥)។

**សំណួរ ១០ :** ស្តីពីឧទាហរណ៍នីមួយៗ ខាងក្រោមនេះ តើត្រូវគណនាភាគបម្រុងយ៉ាងណាដែរ ?

ឧទាហរណ៍ ទី១

- ○ សន្តតិជនគឺ A, B និង C (សុទ្ធតែជាកូនរបស់មតកជនទាំងអស់)
- ○ មតកជនបានទទួលមរណភាពនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០០៩។
- ○ នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០៨ មតកជនបានធ្វើប្រទានកម្មដីមួយដុំដែលមានតម្លៃ 150,000ដុល្លារទៅឱ្យ A (នេះត្រូវជាផលប្រយោជន៍ពិសេស)។
- ○ ទ្រព្យសម្បត្តិសន្តតិកម្មរបស់មតកជនពុំមានអ្វីទេ ទាំងទ្រព្យសកម្ម ទាំងទ្រព្យអកម្ម។
- ○ នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០១០ Bបានដាក់ពាក្យបណ្តឹងបង្ហាញឆន្ទៈទាមទារឱ្យកាត់បន្ថយភាគបម្រុង ចំពោះ A។
- ○ C បានដឹងអំពីការដែលមតកជនបានធ្វើប្រទានកម្មដីចំពោះ A ពេលនៅរស់ដែរ តែ Cមិនបានទាមទារឱ្យកាត់បន្ថយភាគបម្រុងនេះទេ។

ទ្រព្យសម្បត្តិដែលជាមូលដ្ឋាននៃការគណនា :

ទ្រព្យសម្បត្តិសកម្មនៅពេលចាប់ផ្តើមសន្តតិកម្ម + ផលប្រយោជន៍ពិសេស + ប្រទានកម្មកំណត់មួយពេលនៅរស់ − បំណុល

= 0 + 150,000 + 0 − 0

= 150,000

ចំនួនទឹកប្រាក់នៃភាគបម្រុងរបស់ B : ទ្រព្យសម្បត្តិដែលជាមូលដ្ឋាន × សមាមាត្រនៃភាគបម្រុង

= 150,000×1/2×1/3

= 25,000

· ចំនួនទឹកប្រាក់ដែលបានបំពានភាគបម្រុង : ចំនួនទឹកប្រាក់នៃភាគបម្រុង – ចំនួនទឹកប្រាក់សរុបដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចទទួលបានតាមរយៈសន្តតិកម្ម – ចំនួនទឹកប្រាក់នៃផលប្រយោជន៍ពិសេស + បំណុលដែលអ្នកមានសិទ្ធិលើភាគបម្រុងត្រូវទទួលបន្ទុកតាមរយៈសន្តតិកម្ម

= 25,000 - 0 - 0 + 0

= 25,000

· តាមការគណនាខាងលើនេះ ស្តីពីដីដែល A បានទទួលដោយប្រទានកម្មពីមតកជននោះ ទឹកប្រាក់ចំនួន 25,000 ដុល្លារ ក្នុងនោះ គឺមានអានុភាពនៃការកាត់បន្ថយនៃភាគបម្រុង។

→25,000/150,000=1/6គឺជាចំណែកដែលត្រូវធ្លាក់ទៅលើ B

→សេចក្តីសម្រេចបញ្ចប់ (នៅជប៉ុន)

"ចុងចម្លើយ (A) ត្រូវធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិនៃចំណែកមួយភាគប្រាំមួយនៃដី ដែលមាននៅក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធនៃអចលនវត្ថុ ទៅឱ្យដើមចោទ (B) ដោយមូលហេតុនៃការកាត់បន្ថយភាគបម្រុង នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០១០" ។

· បើសិនជា B បានទាមទារសំណងជាប្រាក់ (បើសិនជាតម្លៃដីនោះនៅតែ 150,000ដុល្លារដដែល)

ប្រសិនជា B បានបង់ជាប្រាក់ចំនួន 150,000×1/6 = 25,000ដុល្លារ ពេលនោះ គាត់អាចរួចផុតពីកាតព្វកិច្ចផ្តល់តាវកាលិកស្តីពីអចលវត្ថុនោះបាន។

→ សេចក្តីសម្រេចបញ្ចប់ (នៅជប៉ុន)

"បើសិនជាចុងចម្លើយ (A) មិនបានបង់ប្រាក់ចំនួន 25,000ដុល្លារ ទៅអោយដើមចោទ (B) ទេ ចុងចម្លើយ (A) ត្រូវធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិនៃចំណែក ១ ភាគ ៦ នៃដីដែលមាននៅក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធនៃអចលនវត្ថុ ទៅអោយដើមចោទ (B) ដោយមូលហេតុនៃការកាត់បន្ថយភាគបម្រុង នៅថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១០" ។

ឧទាហរណ៍ ទី២

- សន្តតិជនគឺ A, B និង C (សុទ្ធតែជាកូនរបស់មតកជនទាំងអស់ )។
- មតកជនបានទទួលមរណភាពនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០០៩។
- នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០៨ មតកជនបានធ្វើប្រទានកម្មដីមួយដុំដែលមានតម្លៃ 150,000ដុល្លារទៅឱ្យ A (នេះត្រូវជាផលប្រយោជន៍ពិសេស)។
- ទ្រព្យសម្បត្តិសន្តតិកម្មរបស់មតកជនគឺមាន 60,000ដុល្លារ ជាសាច់ប្រាក់។
- នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០១០ Bបានដាក់ពាក្យបណ្តឹងបង្ហាញឆន្ទៈទាមទារឱ្យកាត់បន្ថយភាគបម្រុង ចំពោះ A។
- C បានដឹងអំពីការដែលមតកជនបានធ្វើប្រទានកម្មដីចំពោះ A ពេលនៅរស់ដែរ តែ Cមិនបានទាមទារឱ្យកាត់បន្ថយភាគបម្រុងនេះទេ។
- នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០៨ មតកជនបានធ្វើប្រទានកម្មដីមួយដុំដែលមានតម្លៃ 150,000ដុល្លារទៅឱ្យ A (នេះត្រូវជាផលប្រយោជន៍ពិសេស)។

ទ្រព្យសម្បត្តិដែលជាមូលដ្ឋាននៃការគណនា :

ទ្រព្យសម្បត្តិសកម្មនៅពេលចាប់ផ្តើមសន្តតិកម្ម + ផលប្រយោជន៍ពិសេស + ប្រទានកម្មកំណត់មួយពេលនៅរស់ – បំណុល

= 60,000 + 150,000 + 0 – 0

= 210,000

ចំនួនទឹកប្រាក់នៃភាគបម្រុងរបស់ B : ទ្រព្យសម្បត្តិដែលជាមូលដ្ឋាន × សមាមាត្រនៃភាគបម្រុង

= 210,000×1/2×1/3

= 35,000

- ចំនួនទឹកប្រាក់ដែលបានបំពានភាគបម្រុង : ចំនួនទឹកប្រាក់នៃភាគបម្រុង – ចំនួនទឹកប្រាក់សរុបដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចទទួលបានតាមរយៈសន្តតិកម្ម – ចំនួនទឹកប្រាក់នៃផលប្រយោជន៍ពិសេស + បំណុលដែលអ្នកមានសិទ្ធិលើភាគបម្រុងត្រូវទទួលបន្ទុកតាមរយៈសន្តតិកម្ម

= 35,000 - 30,000 - 0 + 0 (កំណត់ : ស្តីពីសាច់ប្រាក់ 60,000 សូមចាត់ទុកថា B និង C នឹងធ្វើលទ្ធកម្មនូវសាច់ប្រាក់នេះ 30,000 ម្នាក់ តាមរយៈការបែងចែកមតិក )

= 5,000

- តាមការគណនាខាងលើនេះ ស្តីពីដីដែល A បានទទួលដោយប្រទានកម្មពីមតកជននោះ ទឹកប្រាក់ចំនួន 5,000 ដុល្លារ ក្នុងនោះ គឺមានអានុភាពនៃការកាត់បន្ថយនៃភាគបម្រុង។

→5,000/150,000=1/30 គឺជាចំណែកដែលត្រូវធ្លាក់ទៅលើ B

→សេចក្តីសម្រេចបញ្ចប់ (នៅជប៉ុន)

"ចុងចម្លើយ (A) ត្រូវធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិនៃចំណែក១ភាគ៣០នៃដី ដែលមាននៅក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធនៃអចលនវត្ថុ ទៅឱ្យដើមចោទ (B) ដោយមូលហេតុនៃការកាត់បន្ថយភាគបម្រុង នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០១០" ។

· បើសិនជា B បានទាមទារសំណងជាប្រាក់ (បើសិនជាតម្លៃដីនោះនៅតែ 150,000ដុល្លារដដែល) ប្រសិនជា A បានបង់ជាប្រាក់ចំនួន 150,000×1/30 = 5,000ដុល្លារ ពេលនោះគាត់ អាចរួចផុតពីកាតព្វកិច្ចផ្តល់តាវកាលិកស្តីពីអចលវត្ថុនោះបាន។

→សេចក្តីសម្រេចបញ្ចប់ (នៅជប៉ុន)

"បើសិនជាចុងចម្លើយ (A) មិនបានបង់ប្រាក់ចំនួន 5,000ដុល្លារទៅអោយដើមចោទ (B) ទេ ចុងចម្លើយ (A) ត្រូវធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិនៃចំណែក ១ ភាគ ៣០ នៃដីដែលមាននៅក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធនៃអចលនវត្ថុ ទៅឱ្យដើមចោទ (B) ដោយមូលហេតុនៃការកាត់បន្ថយភាគបម្រុង នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០១០" ។

ឧទាហរណ៍ ទី៣

- សន្តតិជនគឺ A, B និង C (សុទ្ធតែជាកូនរបស់មតកជនទាំងអស់ )។
- មតកជនបានទទួលមរណភាពនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០០៩។
- <u>នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ មតកជនបានធ្វើប្រទានកម្មជាសាច់ប្រាក់ចំនួន 30,000ដុល្លារទៅឱ្យ A (នេះត្រូវជាផលប្រយោជន៍ពិសេស)</u>។
- នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០៨ មតកជនបានធ្វើប្រទានកម្មដីមួយដុំដែលមានតម្លៃ 150,000ដុល្លារទៅឱ្យ A (នេះត្រូវជាផលប្រយោជន៍ពិសេស)។
- ទ្រព្យសម្បត្តិសន្តតិកម្មរបស់មតកជនគឺមាន <u>60,000ដុល្លារ ជាសាច់ប្រាក់។</u>
- នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០១០
  Bបានដាក់ពាក្យបណ្តឹងបង្ហាញឆន្ទៈទាមទារឱ្យកាត់បន្ថយភាគបម្រុង ចំពោះ A។
- C បានដឹងអំពីការដែលមតកជនបានធ្វើប្រទានកម្មដី និង ប្រាក់ ចំពោះ A ពេលនៅរស់ដែរ តែCមិនបានទាមទារឱ្យកាត់បន្ថយភាគបម្រុងនេះទេ។

ទ្រព្យសម្បត្តិដែលជាមូលដ្ឋាននៃការគណនា :

ទ្រព្យសម្បត្តិសកម្មនៅពេលចាប់ផ្តើមសន្តតិកម្ម + ផលប្រយោជន៍ពិសេស + ប្រទានកម្មកំណត់មួយពេលនៅរស់ – បំណុល

= 60,000 + (30,000 +150,000) + 0 – 0

= 240,000

ចំនួនទឹកប្រាក់នៃភាគបម្រុងរបស់ B : ទ្រព្យសម្បត្តិដែលជាមូលដ្ឋាន × សមាមាត្រនៃភាគបម្រុង

= 240,000×1/2×1/3

= 40,000

· ចំនួនទឹកប្រាក់ដែលបានបំពានភាគបម្រុង : ចំនួនទឹកប្រាក់នៃភាគបម្រុង – ចំនួនទឹកប្រាក់សរុបដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចទទួលបានតាមរយៈសន្តតិកម្ម – ចំនួនទឹកប្រាក់នៃផលប្រយោជន៍ពិសេស + បំណុលដែលអ្នកមានសិទ្ធិលើភាគបម្រុងត្រូវទទួលបន្ទុកតាមរយៈសន្តតិកម្ម

= 40,000 - 30,000 - 0 + 0 (កំណត់ : ស្តីពីសាច់ប្រាក់ 60,000 សូមចាត់ទុកថា B និង C នឹងធ្វើលទ្ធកម្មនូវសាច់ប្រាក់នេះ 30,000 ម្នាក់ តាមរយៈការបែងចែកមតិក )

= 10,000

· តាមការគណនាខាងលើនេះ ស្តីពីដីដែល A បានទទួលដោយប្រទានកម្មពីមតកជននោះ ទឹកប្រាក់ចំនួន 10,000ដុល្លារ ក្នុងនោះ គឺមានអានុភាពនៃការកាត់បន្ថយនៃភាគបម្រុង (យោងតាមមាត្រា 1238 ការកាត់បន្ថយត្រូវចាប់ផ្តើមពីប្រទានកម្មចុងក្រោយ ហេតុនេះហើយ អានុភាពនៃការកាត់បន្ថយនេះមិនមានឥទ្ធិពលដល់ប្រទានកម្មជាសាច់ប្រាក់ 30,000 ដុល្លារទេ)។

→10,000/150,000=1/15 គឺជាចំណែកដែលត្រូវធ្លាក់ទៅលើ B

→សេចក្តីសម្រេចបញ្ចប់ (នៅជប៉ុន)

"ចុងចម្លើយ (A) ត្រូវធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិនៃចំណែក១ភាគ១៥នៃដីដែលមាននៅក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធនៃអចលនវត្ថុ ទៅឱ្យដើមចោទ (B) ដោយមូលហេតុនៃការកាត់បន្ថយភាគបម្រុង នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០១០" ។

· បើសិនជា B បានទាមទារសំណងជាប្រាក់

ប្រសិនជា A បានបង់ជាប្រាក់ចំនួន 150,000×1/15 = 10,000ដុល្លារ ពេលនោះ គាត់ អាចរួចផុតពីកាតព្វកិច្ចផ្តល់តាវកាលិកស្តីពីអចលវត្ថុនោះបាន។

→សេចក្តីសម្រេចបញ្ចប់ (នៅជប៉ុន)

"បើសិនជាចុងចម្លើយ (A) មិនបានបង់ប្រាក់ចំនួន 10,000ដុល្លារ ទៅអោយដើមចោទ (B) ទេ ចុងចម្លើយ (A) ត្រូវធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិនៃចំណែក ១ ភាគ ១៥ នៃដីដែលមាននៅក្នុង

បញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធនៃអចលនវត្ថុ ទៅឱ្យដើមចោទ (B) ដោយមូលហេតុនៃការកាត់បន្ថយភាគបម្រុង នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០១០” ។

## ផ្នែកទី ៤

## ការបោះបង់សន្តតិកម្ម និង ការយល់ព្រមដោយមានកំរិត

**សំណួរ ១ :** ហេតុអ្វីបានជាមានរបបបោះបង់សន្តតិកម្ម ?

**ចំលើយ :** សន្តតិកម្ម ត្រូវបានបោះបង់ចោលដោយមានហេតុការណ៍ផ្សេងៗ។ នៅជប៉ុន ក្នុងករណីដែលមតកជន មានបំណុលច្រើនជាងទ្រព្យសកម្ម គេ ប្រើវិធីនេះដើម្បីជៀសវាងនូវការទទួលបន្តនូវបំណុលបែបនេះ។

ក៏ប៉ុន្តែ បើសិនជាបោះបង់សន្តតិកម្មទៅ ទ្រព្យសកម្ម ក៏មិនអាចទទួលបន្តបានដែរ ហេតុនេះហើយ ចំពោះសន្តតិជន ដែលរស់នៅជាមួយមតកជនលើអចលនវត្ថុ ដែលជាកម្មសិទ្ធិរបស់មតកជនត្រូវប្រយ័ត្ន។

**សំណួរ ២ :** តើការបោះបង់សន្តតិកម្ម ត្រូវធ្វើយ៉ាងដូចម្តេចដែរ ?

**ចំលើយ :** ដើម្បីបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំទៅតុលាការ (មាត្រា 1260, ច្បាប់នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង តារាងឧបសម្ព័ន្ធ ចំណុច 5)។

**សំណួរ ៣ :** តើមានកម្រិតពេលវេលាដែរឬទេ ?

**ចំលើយ :** ពេលដែល "អំឡុងពេល ៣ ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្ម ចំពោះខ្លួនបានចាប់ផ្តើម" ដែលជាពេលសម្រាប់ពិចារណាឱ្យបានហ្មត់ចត់បានកន្លងផុតទៅ (មាត្រា 1248 កថាខ័ណ្ឌទី 1) ត្រូវចាត់ទុកថា បានយល់ព្រមទាំងស្រុង (មាត្រា 1255 ចំណុច ខ.) ហេតុនេះហើយ លែងអាចបោះបង់ចោលបាន។ ក៏ប៉ុន្តែ អំឡុងពេលនេះ អាចបន្តបាន បើសិនជាបានដាក់ពាក្យសុំទៅតុលាការ ហើយតុលាការ បានទទួលស្គាល់ (1248 កថាខ័ណ្ឌទី1 វាក្យខ័ណ្ឌទី2)។

ម្យ៉ាងទៀត ក្នុងករណីដែលសន្តតិជន បានចាត់ចែងទ្រព្យសម្បត្តិទាំងអស់ ឬ មួយភាគជាដើម ក៏ត្រូវចាត់ទុកថា បានយល់ព្រមទាំងស្រុងដែរ ដូច្នេះ លែងអាចបោះបង់ចោលបានហើយ (មាត្រា 1255)។

**សំណួរ ៤ :** តើការបោះបង់សន្តតិកម្ម មានអានុភាពយ៉ាងណាដែរ ?

**ចំលើយ :** បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះ មិនមែនជាសន្តតិជនតាំងពីដំបូង (មាត្រា 1261)។ ជាលទ្ធផល បើសិនជាសន្តតិជនដែលមានលំដាប់ស្មើគ្នាបានបោះបង់សន្តតិកម្មទាំងអស់គ្នា សន្តតិជននៃលំដាប់បន្ទាប់ ត្រូវធ្វើសន្តតិកម្ម (ស្តីពីលំដាប់

សន្តតិកម្ម សូមមើលមាត្រា 1156, មាត្រា 1159, មាត្រា 1160)។ម្យ៉ាងទៀត ទោះជាបាន បោះបង់សន្តតិកម្មក៏ដោយ ក៏សន្តតិកម្មជំនួស (មាត្រា 1157) មិនកើតមានឡើងដែរ។

**សំណួរ ៥ :** តើអ្វីទៅការយល់ព្រមដោយមានកម្រិត ?

**ចំលើយ :** ការយល់ព្រមដោយមានកម្រិត គឺជាការយល់ព្រមដោយបម្រុងទុកនូវសំណាងកាតព្វកិច្ច និង អច្ច័យទានរបស់មតកជន បានត្រឹមកម្រិតនៃទ្រព្យសម្បត្តិសកម្ម ដែលខ្លួនបានទទួលតាមរយៈ សន្តតិកម្ម (មាត្រា 1256កថាខ័ណ្ឌទី1)។ នេះ គឺមានលក្ខណៈជាការទូទាត់បំណុល ដូច្នេះ ទាល់តែសន្តតិជនទាំងអស់គ្នា បានធ្វើរួមគ្នាទើបអាចធ្វើទៅបាន (មាត្រាដដែល កថាខ័ណ្ឌទី 2) ក៏ប៉ុន្តែ សន្តតិជនមួយចំនួន អាចបោះបង់សន្តតិកម្មបាន។

# ផ្នែកទី ៥

## ឧត្តិភាពនៃសន្តតិជន

**សំណួរ ១ :** ក្នុងករណីដែលពុំមានសន្តតិជន តើអ្នកណា គ្រប់គ្រងទ្រព្យសម្បត្តិសន្តតិកម្ម?

**ចំលើយ :** ទ្រព្យសម្បត្តិសន្តតិកម្ម ត្រូវបានចាត់ទុកជា នីតិបុគ្គល (មាត្រា 1290) ហើយ អ្នកគ្រប់គ្រងទ្រព្យសម្បត្តិសន្តតិកម្ម ដែលតុលាការបានជ្រើសតាំង ជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិនោះ។ ក៏ប៉ុន្តែ តុលាការ ពុំមានករណីយកិច្ចស្វែងរកទ្រព្យសម្បត្តិ ដែលពុំមានសន្តតិជននោះទេ គឺ បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់នៃលំនៅដ្ឋានចុងក្រោយរបស់មតកជន ឬ តំណាងអយ្យការ ដាក់ពាក្យសុំ (មាត្រា 1291 កថាខ័ណ្ឌទី1)។ នៅជប៉ុន តាមធម្មតា ម្ចាស់បំណុល ឬ អ្នកមាននិស្ស័យពិសេស ដែលនឹងពន្យល់ ក្នុង**សំណួរ ២** ជាអ្នកដាក់ពាក្យសុំ។

**សំណួរ ២ :** ក្នុងករណីដែលពុំមានសន្តតិជន តើចុងបញ្ចប់ ទ្រព្យសម្បត្តិសន្តតិកម្មនឹងធ្លាក់ទៅលើអ្នកណា ?

**ចំលើយ :** ក្រោយពីបានឆ្លងកាត់នីតិវិធីកំណត់ (មាត្រា 1291, មាត្រា 1292, មាត្រា 1296 ~ មាត្រា 1298) ហើយតាមរយៈការដាក់ពាក្យសុំពីសំណាក់ជន ដែលមានជីវភាពជាមួយនឹងមតកជន ឬ អ្នកថែទាំព្យាបាលមតកជន ឬ អ្នកមាននិស្ស័យពិសេសផ្សេងទៀត តុលាការ អាចចែកមួយផ្នែកនៃមត៌ក ដែលនៅសេសសល់ក្រោយការជម្រះ (មិនត្រូវលើសពាក់កណ្តាលទេ) ទៅឱ្យជននោះបាន (មាត្រា 1299)។

លើសពីនេះ ទ្រព្យដែលនៅសល់ (បើសិនជាការដាក់ពាក្យសុំពីសំណាក់ជនមាននិស្ស័យពិសេស មិនបានធ្វើឡើងក្នុងអំឡុងពេលដែលបានកំណត់ដោយមាត្រា 1299 ទេ ទ្រព្យសន្តតិកម្មទាំងអស់ ) ត្រូវធ្លាក់ទៅលើរតនាគារជាតិ (មាត្រា 1300)។

# ជំពូកទី ១០

# ច្បាប់នីតិវិធីដែលត្រូវអនុវត្តចំពោះរឿងក្តីគ្រួសារ

## ផ្នែកទី ១

## ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

### ១. តួនាទី និង វិសាលភាពនៃការអនុវត្ត ( មាត្រា ១, មាត្រា ២, មាត្រា ៣)

បណ្តឹង ដែលមានគោលបំណងបង្កើតនូវទំនាក់ទំនងឋានៈបុគ្គល ឬ បញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាពអ្វីមួយ ដូចជា រឿងក្តីសុំលែងលះ ជាដើម = ច្បាប់នីតិវិធីស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។ នៅក្នុងមាត្រា ៣ មានចែង អំពីករណីជាក់ស្តែង។

ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល គឺជា "ករណីពិសេសនៃក្រមនីតិវិធីរដ្ឋប្បវេណី"។ ហេតុនេះ ហើយ ចំណុច ដែលមិនបានចែងនៅក្នុងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលទេ ត្រូវអនុវត្តតាមបញ្ញត្តិនៃ ក្រមនីតិវិធីរដ្ឋប្បវេណី ដែលជាច្បាប់ទូទៅ លើកលែងតែករណីលើកលែងដែលមានចែងក្នុងមាត្រា ១៣។

ឧទាហរណ៍ : ការបញ្ជូន, បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

### ២. ចំណុចខុសគ្នានឹងបណ្តឹងរដ្ឋប្បវេណី

#### ២.១ ភាពខុសគ្នា

បើសិនជាប្រៀបធៀបទៅនឹងបណ្តឹងរដ្ឋប្បវេណីធម្មតា បណ្តឹងទាក់ទងនឹងឋានៈបុគ្គលនេះ មិនជាឱ្យទម្ងន់ ទៅលើគោលការណ៍ភាគីប៉ុន្មានទេ គឺមានបញ្ញត្តិជាច្រើន ដែលយកគោលជំហគោលការណ៍ឆន្ទានុសិទ្ធិទៅវិញ។

· ការមិនអនុវត្តគោលការណ៍នៃការទាញហេតុផល → តុលាការ អាចយកអង្គហេតុ ដែលភាគីមិនបាន អះអាងមកធ្វើជាមូលដ្ឋាននៃសាលក្រមបាន (មាត្រា ១៤), ការមិនអនុវត្តបញ្ញត្តិពាក់ព័ន្ធនឹងការសារភាព (មាត្រា ១៣), ការមិនអនុវត្តតាមបញ្ញត្តិស្តីពីការលើកចោលនូវមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់ យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ (មាត្រា ១៣)

· អានុភាពនៃសាលក្រម សាលដីកាស្ថាពរ មានទៅលើតតិយជន (មាត្រា ១៧)

· មិនអាចទទួលស្គាល់នូវការទាមទារ ឬ បោះបង់ចោលនូវការទាមទារ ឬ សះជាតាមផ្លូវបណ្តឹងបានទេ (មាត្រា ១៣ កថាខ័ណ្ឌទី ២) ← មិនអនុញ្ញាតឱ្យភាគីចាត់ចែង ដោយឆន្ទានុសិទ្ធិរបស់ខ្លួនទេ។ ក៏ប៉ុន្តែ ពុំមានការ កម្រិត នូវការដកពាក្យបណ្តឹងទេ។

· អាចចាត់ចែងរក្សាការពារដោយឆន្ទានុសិទ្ធិបាន (មាត្រា ២១)

· អាចអះអាងអង្គហេតុដោយតំណាងអយ្យការបាន ( មាត្រា ៤) ។ ក្នុងច្បាប់ជប៉ុន ក៏មានបញ្ញត្តិដូចគ្នាដែរ ក៏ប៉ុន្តែពុំដែលឃើញតំណាងអយ្យការ ចូលមកអះអាងដោយផ្អែកលើមាត្រានេះទេ។ ក៏ប៉ុន្តែ ក្នុងករណី ដែលជាបណ្តឹងសុំឱ្យទទួលស្គាល់ក្រោយពេលទទួលមរណភាព ជាអាទិ៍ ដែលចុងចម្លើយ បានទទួលមរណភាព ពេលនោះតំណាងអយ្យការ នឹងក្លាយជាចុងចម្លើយ ( មាត្រា ៧ កថាខ័ណ្ឌទី ៣) ។

## ២.២ បញ្ហាផ្សេង ៗ

· បញ្ញត្តិស្តីពីសមត្ថកិច្ច ( មាត្រា ៥) ។ សូមប្រយ័ត្នអំពីសមត្ថកិច្ចផ្តាច់មុខ។ម្យ៉ាងទៀត ស្តីពីបណ្តឹងសុំលែងលះ ព្រមទាំងបណ្តឹងសុំអោយបញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាពបិតុភាព ត្រូវអនុវត្តតាមមាត្រា ១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

· ជាគោលការណ៍ ការទាញហេតុផលដោយផ្ទាល់មាត់ មិនត្រូវធ្វើជាសាធារណៈឡើយ ( មាត្រា ១៦)

· សូមមើលមាត្រាដទៃទៀត

## ២.៣ ការដោះស្រាយតាមរយៈការជជែកគ្នា - ស្ថានភាពនៅជប៉ុន

នៅកម្ពុជា ត្រូវអនុវត្តច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ចំពោះបណ្តឹងសុំលែងលះ ហេតុនេះហើយ មិនអាចសះជាតាមផ្លូវបណ្តឹងបានឡើយ ក៏អាចដោយស្រាយតាមរយៈការជជែកគ្នាបាន។ ការជជែកគ្នា នៅក្នុងនេះ មិនមែនត្រឹមតែជជែក ដើម្បីផ្សះផ្សាទំនាក់ទំនងជាប្តីប្រពន្ធប៉ុណ្ណោះទេ ទោះបីជាការលែងលះនោះ មិនអាចចៀសវាងបានក៏ដោយ ក៏អាចជជែកគ្នារកដំណោះស្រាយនៃវិវាទស្តីពីការបែងចែកទ្រព្យសម្បត្តិ ឬ វិវាទពាក់ព័ន្ធនឹងបញ្ហាកូន ជាដើមផងដែរ។ ម្យ៉ាងទៀត ដើម្បីធ្វើឱ្យលទ្ធផលនៃការជជែកនោះ មានអានុភាពតាមផ្លូវច្បាប់ តុលាការ អាចចេញសាលក្រម ដែលមានខ្លឹមសារស្របនឹងលទ្ធផលនៃការជជែកនោះបាន បើសិនជាពុំមានបញ្ហាទេ។

នៅជប៉ុន ស្តីពីវិវាទគ្រួសារ ដូចជាការសុំលែងលះ ជាអាទិ៍ គេ បានជ្រើសរើសគោលការណ៍ធ្វើសន្ធានកម្មជាមុន មានន័យថា រាល់រឿងក្តីពាក់ព័ន្ធនឹងគ្រួសារ ត្រូវឆ្លងកាត់តាមសន្ធានកម្មអំពីបញ្ហាគ្រួសារ នៅតុលាការគ្រួសារជាមុនសិន មុននឹងដាក់ពាក្យបណ្តឹង។ សន្ធានកម្មស្តីពីបញ្ហាគ្រួសារនេះ ត្រូវដឹកនាំដោយគណកម្មការសន្ធានកម្ម ដែលមានចៅក្រមមួយរូប និង សន្ធានការីពីររូបជាសមាជិក។ ក៏ប៉ុន្តែ ភាគច្រើន ចៅក្រមអវត្តមាន នៅពេលធ្វើសន្ធានកម្ម ទុកឱ្យសន្ធានការីពីរនាក់ ជាអ្នកដឹកនាំនីតិវិធីសន្ធានកម្មនោះ។

នៅពេលធ្វើសន្ធានកម្មស្តីពីការលែងលះ បើសិនជា អាចធ្វើឱ្យប្តីប្រពន្ធនោះ មានទំនាក់ទំនងសុខស្រួលវិញជាការល្អ ក៏ប៉ុន្តែទោះជាក្នុងករណីដែលពិបាកផ្សះផ្សាក៏ដោយ ក៏អាចជជែកអំពីអំណាចមេបា ឬ អំពីការប្រាស្រ័យទាក់ទងជាមួយនឹងកូន ជាដើម នៅក្នុងនីតិវិធីសន្ធានកម្មនេះបានដែរ។ ម្យ៉ាងទៀត ទោះជាសន្ធានកម្មនេះ មិនបាន

ជោគជ័យ  ហើយ គេ បានដាក់ពាក្យបណ្តឹងក៏ដោយ ជាទូទៅ ចៅក្រមដែលទទួលបន្ទុកលើរឿងក្តីនោះ ច្រើនតែណែនាំឱ្យជជែកគ្នាដើម្បីដោះស្រាយ  ហើយភាគច្រើន បានទទួលលទ្ធផលល្អ។

# ផ្នែកទី ២

# ច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

## ១. រឿងក្តីដែលត្រូវអនុវត្ត

ប្រភេទនៃរឿងក្តី ដែលត្រូវអនុវត្តច្បាប់នេះ មានបញ្ជាក់នៅក្នុងតារាងទី ១ ដែលបានលើកឡើងនៅក្នុង មាត្រា ១។

ភាគច្រើន គឺជារឿងក្តីពាក់ព័ន្ធនឹងច្បាប់គ្រួសារ។ ស្តីពីរឿងក្តីសុំលែងលះ ដែលពុំមានការព្រមព្រៀង គឺជាបណ្តឹងទាក់ទងនឹងឋានៈបុគ្គល រីឯការលែងលះគ្នាដោយមានការព្រមព្រៀង (ក្រមរដ្ឋប្បវេណី មាត្រា ៩៧៩) វិញ ត្រូវអនុវត្តច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីដែលមិនមែនជាបណ្តឹង។

ម្យ៉ាងទៀត ស្តីពីរឿងក្តីពាក់ព័ន្ធនឹងការបែងចែកទ្រព្យសម្បត្តិ ឬ សោហ៊ុយគ្រប់គ្រងថែរក្សាកូន ក៏ត្រូវអនុវត្តច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីដែលមិនមែនជាបណ្តឹងដែរ តែនៅក្នុងបណ្តឹងសុំលែងលះ ក៏អាចដាក់ពាក្យសុំការចាត់ចែង បន្ទាប់បន្សំបានដែរ (ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មាត្រា ២២)។

ចំពោះការបែងចែកមតិក ក៏ត្រូវអនុវត្តច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងដែរ។

## ២. លក្ខណៈពិសេសនៃនីតិវិធី

· មិនមែនជាគោលការណ៍ភាគីទេ គឺជាគោលការណ៍ឆន្ទានុសិទ្ធិ ហើយមានលក្ខណៈជាអាណាព្យាបាល

ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ, ការស្រាវជ្រាវអង្គហេតុ និង ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ (មាត្រា ២៧)

· បើសិនជាប្រៀបធៀបនឹងនីតិវិធីបណ្តឹង នីតិវិធីនេះ មិនជាប្រិតប្រៀងដូចនីតិវិធីបណ្តឹងទេ

ការទាញហេតុផល ដោយផ្ទាល់មាត់ដោយឆន្ទានុសិទ្ធិ (មាត្រា ២៦), អាចធ្វើការស្រាវជ្រាវអង្គហេតុបានដោយមិនចាំបាច់ធ្វើជាលក្ខណៈពិនិត្យភស្តុតាង (មាត្រា ២៧ កថាខ័ណ្ឌទី ២)។ បើសិនជាមិនមែនជាការទាញហេតុផលដោយផ្ទាល់មាត់ទេ ក៏មិនចាំបាច់ធ្វើជាសាធារណៈទេ។

· ម្យ៉ាងវិញទៀត មានការអនុវត្តតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីយ៉ាងទូលំទូលាយ (មាត្រា ៣៤)។

## ៣. ការដោះស្រាយវិវាទតាមរយៈការថ្លៃតគ្នា

នៅក្នុងច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ពុំមានបញ្ញត្តិចែងអំពីការផ្សះផ្សា ឬ ចែងឱ្យអនុវត្តតាមបញ្ញត្តិពាក់ព័ន្ធនឹងការផ្សះផ្សាទេ ហេតុនេះហើយ អាចបកស្រាយបានថា មិនអាចបញ្ចប់រឿងក្តីដោយការសះជាបានឡើយ។ ក៏ប៉ុន្តែ ទោះបីជាមានការបកស្រាយបែបនេះក៏ដោយ ដូចដែលបានពន្យល់រួចហើយ

នៅក្នុងបណ្តឹង ទាក់ទងនឹងឋានៈបុគ្គល ក្នុងករណីដែលភាគីមានការព្រមព្រៀង ហើយពុំមានបញ្ហាទេ តុលាការត្រូវចេញសាលក្រម ឬ សាលដីកា តាមខ្លឹមសារនៃការព្រមព្រៀងនោះ ដើម្បីអាចទទួលបាននូវដំណោះស្រាយមួយដែលមានអានុភាពតាមផ្លូវច្បាប់។

ក្នុងចំណោមរឿងក្តី ដែលត្រូវអនុវត្តច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីដែលមិនមែនជាបណ្តឹង មានរឿងក្តី ដែលមិនអាចដោះស្រាយតាមរយៈការជជែកគ្នាបាន ដូចជារឿងក្តីពាក់ព័ន្ធនឹងអាណាព្យាបាល ជាដើម។ ក៏ប៉ុន្តែ ដូចជាការបែងចែកទ្រព្យសម្បត្តិ សោហ៊ុយគ្រប់គ្រងថែរក្សាកូន ការប្រាស្រ័យទាក់ទងនឹងកូន ជាដើម គឺជារឿងក្តីដែលគប្បីដោះស្រាយតាមរយៈការជជែកគ្នាដែរ។ ស្តីពីរឿងក្តីប្រភេទនេះ ទោះបីជាបានដាក់ពាក្យមកតុលាការហើយក៏ដោយ គប្បី ពិចារណារកដំណោះស្រាយតាមរយៈការជជែកគ្នាជាការល្អ។

# ផ្នែកទី ៣

# សមត្ថកិច្ចនៃតុលាការអន្តរជាតិ

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឬ ច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឬ ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ពុំមានបញ្ញត្តិណាមួយ ដែលចែងពាក់ព័ន្ធនឹងសមត្ថកិច្ចតុលាការអន្តរជាតិទេ។

## ១. រឿងក្តីសុំលែងលះ

យោងតាមមាត្រា ៨១ កថាខណ្ឌទី ៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ដែលត្រូវអនុវត្តដដែលក្រោយពេលអនុវត្តក្រមរដ្ឋប្បវេណីថ្មី ប្រសិនបើដើមចោទ មានអាស័យដ្ឋាននៅកម្ពុជា តុលាការកម្ពុជា មានសមត្ថកិច្ចលើបណ្តឹងនោះ។

រីឯនៅជប៉ុនវិញ យោងតាមករណីយុត្តិសាស្ត្ររបស់តុលាការកំពូល "ជាគោលការណ៍ បើសិនជាចុងចម្លើយមានអាស័យដ្ឋាននៅជប៉ុន តុលាការជប៉ុន មានសមត្ថកិច្ចលើបណ្តឹង" ក៏ប៉ុន្តែក្នុងករណីដែល "ដើមចោទ ត្រូវបានចុងចម្លើយ បោះបង់ចោល ហើយមិនដឹងថាចុងចម្លើយនៅឯណា ឬ ក្នុងករណីប្រហែលគ្នា" ឬ ក៏ទោះជាចុងចម្លើយមានអាស័យដ្ឋាន (ឬអាស័យដ្ឋានចុងក្រោយ) នៅក្រៅប្រទេសក៏ដោយ ឱ្យតែដើមចោទមានអាស័យដ្ឋាននៅជប៉ុន តុលាការជប៉ុន មានសមត្ថកិច្ចលើបណ្តឹងនោះ។ ម្យ៉ាងទៀត បើសិនជាចុងចម្លើយបានដាក់ពាក្យបណ្តឹងតប ជាទូទៅ តុលាការជប៉ុន មានសមត្ថកិច្ចលើបណ្តឹងនោះ។

## ២. រឿងក្តីបែងចែកមតិក

ដោយសារតែពុំមានបញ្ញត្តិណាមួយចែងច្បាស់លាស់ ដូច្នេះត្រូវប្រគល់ឱ្យតុលាការធ្វើការបកស្រាយ។

នៅជប៉ុន ជាទូទៅ ឱ្យតែមតកជន មានអាស័យដ្ឋានចុងក្រោយ ឬ ឱ្យតែមតិកនោះ ស្ថិតនៅក្នុងប្រទេសជប៉ុន តុលាការជប៉ុន មានសមត្ថកិច្ចលើបណ្តឹងនោះ។

## ៣. ច្បាប់ដែលត្រូវអនុវត្តតាម

នៅកម្ពុជា ពុំមានច្បាប់ណាមួយ ដែលបានចែងជាទូទៅ អំពីច្បាប់ដែលត្រូវយកមកអនុវត្តតាមនៅឡើយទេ។

### ៣.១ រឿងក្តីសុំលែងលះគ្នា

ត្រូវអនុវត្តតាមមាត្រាពី ៧៩ ដល់ ៨១ នៃច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ ដែលត្រូវអនុវត្តដដែលក្រោយពេលអនុវត្តក្រមរដ្ឋប្បវេណីថ្មី។ ស្តីពីការបែងចែកទ្រព្យសម្បត្តិ ជាដើម ដែលជាបណ្តឹងបន្ទាប់បន្សំនៃបណ្តឹងសុំលែងលះគ្នា ក៏ដូចគ្នាដែរ។ យោងតាមបញ្ញត្តិទាំងនោះ ស្តីពីបណ្តឹងសុំលែងលះ មិនចាំបាច់អនុវត្តតាមច្បាប់បរទេសទេ។

រីឯនៅជប៉ុនវិញ នៅក្នុង "ច្បាប់ទូទៅក្នុងការអនុវត្តច្បាប់" មានចែងដូចតទៅ :

- ក្រោយអាពាហ៍ពិពាហ៍ ត្រូវអនុវត្តច្បាប់នៃប្រទេសរបស់ភាគី ចំពោះភាគីម្នាក់ៗ
- ស្តីពីវិធីរៀបអាពាហ៍ពិពាហ៍ ត្រូវអនុវត្តតាមច្បាប់នៃទីកន្លែងដែលបានរៀបអាពាហ៍ពិពាហ៍
- អានុភាពនៃការរៀបអាពាហ៍ពិពាហ៍ គឺ បើសិនជាច្បាប់នៃប្រទេសខាងប្តីប្រពន្ធ ជាច្បាប់តែមួយ ត្រូវអនុវត្តតាមច្បាប់នោះ ហើយបើសិនជាពុំមានច្បាប់ពាក់ព័ន្ធទេ ត្រូវអនុវត្តតាមច្បាប់នៃកន្លែង ដែលមានអាស័យដ្ឋានរបស់ប្តី ប្រពន្ធ ហើយបើសិនជាពុំមានច្បាប់ទាំងពីរនេះទេ ត្រូវអនុវត្តតាមច្បាប់ ដែលពាក់ព័ន្ធជិតស្និទ្ធិជាងគេនឹងប្តីប្រពន្ធ។
- ស្តីពីរបបទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ឬ ស្តីពីការលែងលះគ្នា ត្រូវអនុវត្តតាមបញ្ញត្តិដូចគ្នា នឹងអានុភាពនៃការរៀបអាពាហ៍ពិពាហ៍ដែរ។

## ៣.២ រឿងក្តីបែងចែកមត៌ក

ដោយសារតែពុំមានបញ្ញត្តិចែងច្បាស់លាស់ ត្រូវប្រគល់ឱ្យតុលាការធ្វើការបកស្រាយ។

ជាទូទៅ មានការប្រឆាំងគ្នា រវាងគោលការណ៍សន្តតិកម្មបែងចែកផ្សេងគ្នា និង គោលការណ៍សន្តតិកម្មរួមគ្នា។ ចំពោះគោលការណ៍សន្តតិកម្មបែងចែកផ្សេងគ្នា ស្តីពីសន្តតិកម្មនៃអចលនវត្ថុ ត្រូវអនុវត្តតាមច្បាប់នៃប្រទេសដែលមានទីតាំងអចលនវត្ថុនោះ រីឯស្តីពីសន្តតិកម្មនៃចលនវត្ថុវិញ ត្រូវអនុវត្តតាមច្បាប់ ដែលពាក់ព័ន្ធនឹងមតកជន (ច្បាប់ប្រទេសសាមីខ្លួន ឬ ច្បាប់នៅលំនៅដ្ឋាន)។ ចំពោះគោលការណ៍សន្តតិកម្មរួមគ្នា ត្រូវអនុវត្តច្បាប់ ដែលពាក់ព័ន្ធនឹងមតកជន (ច្បាប់ប្រទេសសាមីខ្លួន ឬ ច្បាប់នៅលំនៅដ្ឋាន) លើទ្រព្យសម្បត្តិទាំងអស់។ ប្រព័ន្ធច្បាប់អាមេរិក អង់គ្លេស ជាដើម និង ប្រទេសដែលមានប្រព័ន្ធច្បាប់ទិ្វបមួយចំនួន ដែលបានជ្រើសរើសគោលការណ៍ទូទាត់សម្រាប់សន្តតិកម្ម បានជ្រើសរើសគោលការណ៍សន្តតិកម្មបែងចែកផ្សេងគ្នា រីឯ ប្រទេស ដែលមានប្រព័ន្ធច្បាប់ទិ្វប ភាគច្រើន បានជ្រើសរើសគោលការណ៍សន្តតិកម្មរួមគ្នា។ នៅជប៉ុន ក្នុង "ច្បាប់ទូទៅស្តីពីការអនុវត្តច្បាប់" គេ បានជ្រើសរើសយកគោលការណ៍សន្តតិកម្មរួម មានន័យថា ត្រូវអនុវត្តតាមច្បាប់នៃប្រទេសរបស់មតកជន។